**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ
# សណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌដូនពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សុធា សមស័ក្តិ**

**ហេង សុគន្ធ**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលរៀន ២០១៥

ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ
# សណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌដូនពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ: **សុធា សមស័ក្តិ**
**ហេង សុគន្ធ**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលរៀន ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **សុធា សមស័ក្តិ** និង ខ្ញុំបាទ **ហេង សុគន្ធ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៥-២០១៩៖

ជាបឋមយើងខ្ញុំទាំងពីរ មានកិត្តិយសសូមសេចក្តីអនុញ្ញាត ដើម្បីបានសម្តែងនូវគារវកិច្ចគោរព ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ អ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបាន ប្រឹងប្រែងប្រកបដោយព្រហ្មវិហារធម៌ចិញ្ចឹមបីបាច់ ថែរក្សា លះបង់អស់កម្លាំងកាយចិត្ត លះបង់ ធនធាន សេចក្តីស្រលាញ់ភាពកក់ក្តៅសព្វបែបយ៉ាង បណ្តុះទឹកចិត្តកតញ្ញូតាធម៌ចំពោះគ្រប់ អ្នកមានគុណ និងបានខិតខំជម្រុញអោយកូនបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់ ដើម្បីឱ្យកូនក្លាយ ខ្លួនជាពលរដ្ឋល្អ។

សូមគោរពអរគុណដល់ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងសាស្ត្រាចារ្យ** ទាំងអស់ ដែលបានខិតខំប្រឹងប្រែង និងលទ្ធភាពគ្រប់បែបយ៉ាងក្នុងការដឹកនាំ ក្នុង គោលបំណង បណ្តុះបណ្តាល មូលធនផ្នែកបញ្ញា ធនធានមនុស្សកម្ពុជាឲ្យ មានចំណេះដឹង បទពិសោធន៍ និងមានសមត្ថភាពខ្ពស់ ដើម្បីក្លាយជាសសរទ្រូងស្របតាម កាលានុវត្តភាព នៃការ អភិវឌ្ឍន៍របស់ប្រទេសជាតិ ។

សូមគោរពអរគុណដល់ **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលបានដឹកនាំ កែលម្អ និងចង្អុលបង្ហាញ តម្រង់ទិស ព្រមទាំងពន្យល់ពីវិធីសាស្ត្រល្អៗ ផ្តល់យោបល់ល្អៗទាក់ទង នឹងប្រធានបទសារណា របស់ខ្ញុំបាទ រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃតាំងពីដើមរហូតដល់ បញ្ចប់ការសិក្សាស្រាវជ្រាវមួយនេះ។

ជាចុងក្រោយ ខ្ញុំបាទមាន កិត្តិយស សូមសេចក្តីអនុញ្ញាត គោរពជូនពរដល់ អ្នកមានគុណទាំង អស់ សូមមេត្តាទទួលយកដោយក្តីអនុគ្រោះបំផុត នូវភក្តីភាពគោរពស្រឡាញ់ ក្នុងភាពសុចរិត ដែលជាគុណតម្លៃដ៏ឧត្តុងឧត្តមនៃសេចក្តីថ្លៃថ្នូរ ភាពថ្កុំថ្កើង កិត្តិគុណដ៏ខ្ពង់ខ្ពស់ និងកតញ្ញូតាធម៌។

ជាទីបញ្ចប់សូមគោរពជូនពរ លោកអ្នកមានគុណទាំងអស់ សូមទទួលបាននូវភាពជោគជ័យ គ្រប់ភារកិច្ច និង កម្លាំងពលំមាំមួនខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាវាងវៃ អាយុយឺនយូរ រកទទួល ទានមានបាន គ្រប់ៗគ្នាព្រមទាំងជួបនូវ ពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីខ្ញុំបាទ បានសិក្សាថ្នាក់បរិញ្ញាបត្រ ក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ អស់រយៈពេល ៣ឆ្នាំ កន្លងទៅនេះ ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើនទាំង ផ្នែកទ្រឹស្តី និងការអនុវត្តន៍នៅក្នុងផ្នែកនេះ។ ស្ថិតនៅក្នុងដំណាក់កាលនេះគឺជាឆ្នាំទី៤ របស់យើងខ្ញុំទាំងពីរ ដោយផ្អែកទៅតាម ចំណេះដឹងនៃការសិក្សាទាំងអស់នេះហើយដែលជាកត្តាលីករជំរុញឱ្យខ្ញុំបាទមានឱកាស និងមានលទ្ធភាពបានសរសេរសារណាបញ្ចប់ការសិក្សាមួយសម្រាប់ ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយ។ ហើយនេះជាឱកាសដ៏មានតម្លៃមួយដែលអាចស្វង់អំពីចំណេះដឹងរបស់យើងខ្ញុំទាំងពីរដែលមានពីមុនមក និងសិក្សាស្រាវជ្រាវបន្ថែម។ ហេតុនេះទើបខ្ញុំបាទទាំងពីរបានជ្រើសរើសយកប្រធានមួយដែលទាក់ទងនឹង នីតិនគរូបនីយកម្ម និងសំណង់ដែលស្តីអំពី " **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌដូនពេញ** " មកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សា។

កម្មវត្ថុសំខាន់មួយទៀតនោះ គឺចង់ឱ្យ និស្សិតជំនាន់ក្រោយ និងសាធារណជន បានយល់ដឹងអំពីបញ្ហានៃការរៀបចំសណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពដ៏ស្រស់បំព្រង មានបរិស្ថានរស់នៅល្អគ្មានការរំខាន និងការបំពុលផ្សេងៗ ព្រមទាំងវិធានការក្នុងការដោះស្រាយមួយចំនួនដែលអាចកើតមានឡើងក្នុងការរៀបចំ។ លើសពីនេះទៅទៀត ខ្ញុំបាទទាំងពីរមាន គោលបំណងចង់បង្ហាញអំពី សក្តានុពលនៃការអភិវឌ្ឍន៍ ដែលមាននៅក្នុង ខណ្ឌដូនពេញ រាជធានីភ្នំពេញផងដែរ។ ម៉្យាងវិញទៀតក៏ដើម្បីឱ្យសាធារណជនគ្រប់រូប មានការយល់ដឹងអំពីការអភិវឌ្ឍន៍ក្នុងខណ្ឌនេះ និងអាចជួយសម្រួលដល់ប្អូនៗនិស្សិតជំនាន់ក្រោយក្នុងការសិក្សា និងយកមកធ្វើជាឯកសារពិគ្រោះបានផងដែរ។

មុននឹងបញ្ចប់ ដោយសេចក្តីគួរឬពុំគប្បីយ៉ាងណានោះ ខ្ញុំបាទទាំងពីរសូមគោរពទទួលយកនូវរាល់កំហុសឆ្គាំឆ្គងណាមួយដោយ ចេតនា អចេតនាក្តី ឬនៅមានភាពខ្វះចន្លោះត្រង់កន្លែងណាមួយសូមមេត្តាខន្តី អភ័យទោស ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទទាំងពីរ ហើយ យើងខ្ញុំនឹងរង់ចាំ ទទួលនូវមតិរិះគន់ កែលម្អ រាល់ចំនុចខ្វះខាតទាំងឡាយ ក្នុងន័យស្ថាបនា ដើម្បីឱ្យការស្រាជ្រាវមួយនេះមានអត្ថន័យ គ្រប់គ្រាន់បន្ថែមទៀត។

ជាទីបញ្ចប់ ខ្ញុំបាទទាំងពីរ សូមគោរពជូនពរដល់មិត្តនិស្សិត មិត្តអ្នកអាន ទាំងអស់ សូមទទួលបានជោគជ័យគ្រប់ភារកិច្ច និង កម្លាំងពលំមាំមួនខ្លាំងក្លា ប្រាជ្ញាវាងវៃ អាយុយឺនយូរ រកទទួលទានមានបាន គ្រប់ៗគ្នា ព្រមទាំងជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ការរៀបចំសណ្តាប់ធ្នាប់របស់ខណ្ឌដូនពេញ

**១.១. ទិដ្ឋភាពទូទៅ** ........ ៤

**១.១.១. មូលហេតុនាំឱ្យមានការរៀបចំខណ្ឌដូនពេញ** ........ ៧

១.១.១.១. បញ្ហាកំណើនប្រជាជន ........ ៨

១.១.១.២. បញ្ហាចរាចរណ៍ ........ ៩

១.១.១.៣. បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់ ........ ៩

**១.១.២. រចនាសម្ព័ន្ធរបស់ខណ្ឌដូនពេញ** ........ ១០

១.១.២.១. ក្រុមប្រឹក្សាខណ្ឌ ........ ១០

១.១.២.២. គណៈអភិបាលខណ្ឌ ........ ១១

**១.២. បច្ចុប្បន្នភាពនៃការរៀបចំខណ្ឌដូនពេញ** ........ ១៥

**១.២.១. ការអភិវឌ្ឍន៍ផ្នែកសំណង់ លំនៅដ្ឋានក្នុងខណ្ឌដូនពេញ** ........ ១៥

១.២.១.១. លំនៅដ្ឋាន ........ ១៦

១.២.១.២. សំណង់អគារសហកម្មសិទ្ធ ........ ១៦

១.២.១.៣. សំណង់អគារផ្សេងៗ ........ ១៧

**១.២.២. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌដូនពេញ** ........ ១៩

១.២.២.១. គមនាគមន៍ផ្លូវថ្នល់ ........ ១៩

១.២.២.២. ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ........ ២២

## ជំពូកទី២
## ការរៀបចំសោភ័ណភាព និងបរិស្ថានក្នុងខណ្ឌដូនពេញ

**២.១. សោភ័ណភាពទូទៅក្នុងខណ្ឌដូនពេញ** ........ ២៤

**២.១.១.សោភ័ណភាពពេលថ្ងៃ** ........ ២៥

**២.១.២.សោភ័ណភាពពេលយប់** ........ ២៦

**២.២. បរិស្ថានក្នុងខណ្ឌដូនពេញ** ........ ២៧

**២.២.១. មូលហេតុដែលនាំឱ្យមានការបំពុលបរិស្ថានក្នុងខណ្ឌដូនពេញ** ................ ២៧
២.១.១.១. ការបំពុលទឹក ........................................................................ ២៨
២.១.១.២. ការបំពុលខ្យល់ ..................................................................... ៣០
២.១.១.៣. ការបំពុលដោយសម្លេង ............................................................ ៣២
២.១.១.៤. ការបំពុលដី ......................................................................... ៣២
២.១.១.៥. ការបំពុលដោយសំណល់រឹង និងរាវ ............................................. ៣៣
**២.២.២. វិធានការដោះស្រាយក្នុងការបំពុលទាំង ៥** ........................................ ៣៥
២.២.២.១. វិធានការដោះស្រាយការបំពុលទឹក .............................................. ៣៧
២.២.២.២. វិធានការដោះស្រាយការបំពុលខ្យល់ ............................................ ៣៨
២.២.២.៣. វិធានការដោះស្រាយការបំពុលដោយសម្លេង ................................... ៣៩
២.២.២.៤. វិធានការដោះស្រាយការបំពុលដី ................................................. ៣៩
២.២.២.៥. វិធានការដោះស្រាយការបំពុលដោយសំណល់រឹង និងរាវ ....................... ៤០
**សេចក្ដីសន្និដ្ឋាន** ............................................................................ ៤២
**អនុសាសន៍** .................................................................................. ៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា៖

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសដែលទើបតែចាកផុតពីភ្លើងសង្គ្រាម និងទទួលបាននូវសុខសន្តិភាពពេញលេញ ប្រមាណជាជាង ៩០ឆ្នាំ។ បន្ទាប់ពីការបញ្ចប់សង្គ្រាមតាមរយៈនយោបាយ ឈ្នះ-ឈ្នះ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺសង្កេតឃើញថាមានការអភិវឌ្ឍន៍រីកលូតលាស់លើគ្រប់វិស័យទាំង វិស័យរដ្ឋ និងវិស័យឯកជន។ ជាពិសេសគឺមានការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគមនាគមន៍ មន្ទីរពេទ្យ សាលារៀន វត្តអារាម គ្រឹះស្ថានស្ថាប័នរដ្ឋ និងឯកជន ព្រមទាំងសំណង់លំនៅដ្ឋានទំនើបៗ កើតមានឡើងជាបន្តបន្ទាប់ ក្នុងដំណាក់កាលប្រមាណជាជាង ១០ ឆ្នាំចុងក្រោយនេះ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយដីធ្លី និងលំនៅឋាន និងមានការអភិវឌ្ឍន៍តាមរយៈប្លង់គោលនៃការរៀបចំរាជធានីភ្នំពេញ អោយកាន់តែមានលក្ខណៈល្អប្រសើរឡើងក្នុងការបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ។

ស្របពេលដែលប្រទេសកម្ពុជា ស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការអភិវឌ្ឍន៍នោះ រាជរដ្ឋាភិបាលបានគិតគូរយ៉ាងខ្លាំងផ្តោតសំខាន់ទៅលើ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពបរិស្ថានរស់នៅល្អរបស់ប្រជាជន គ្មានការរំខានដោយការបំពុលផ្សេងៗ មានសណ្តាប់ធ្នាប់ល្អ សន្តិសុខ សុវត្ថិភាពរស់នៅទាំងសុវត្ថិភាពចំណីអាហារ និងសម្ភារៈ ជាពិសេសមិនមានការបំពារបំពានដោយអំពីចោរកម្មផ្សេងៗទៀ។ ដោយគិតឃើញពីកត្តាអស់ទាំងនេះ ទើបយើងខ្ញុំសម្រេចជ្រើសរើសសរសេរពី ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពរបស់ខណ្ឌដូនពេញ ហើយខណ្ឌនេះ ជាតំបន់មួយនៅក្នុង រាជធានីភ្នំពេញជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ៖

ដើម្បីធ្វើការសិក្សាឱ្យមានលក្ខណៈស៊ីជម្រៅ និងមានភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទសារណាខាងលើ យើងខ្ញុំបានលើកឡើងនូវចំណោទបញ្ហាមួយចំនួន មកធ្វើការបកស្រាយ ដែលបញ្ហាទាំងនោះរួមមាន៖ តើបុព្វហេតុអ្វីខ្លះដែលនាំឱ្យមានការរៀបចំខណ្ឌដូនពេញ? តើគួរធ្វើយ៉ាងដូចម្តេច ដើម្បីរៀបចំខណ្ឌដូនពេញឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព? និងបច្ចុប្បន្នភាពការអភិវឌ្ឍន៍លើវិស័យសំណង់លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ សោភ័ណភាពបរិស្ថានរស់នៅល្អគ្មានបំពុលផ្សេងៗ និងវិធានការដោះស្រាយនៃការបំពុលទាំងនោះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ៖

គោលបំណង ក្នុងការកំណត់យកប្រធានបទដែលទាក់ទងនឹង នីតិនគរូបនីយកម្ម ស្ដីពី "**ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌដូនពេញ**" យកមកសរសេរជាសារណាបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ គឺចង់បង្ហាញឱ្យឃើញពី សក្ដានុពល របស់ខណ្ឌដូនពេញ ពីព្រោះខណ្ឌនេះ ត្រូវបានគេចាត់ទុកថាជាខណ្ឌមួយដ៏មានប្រជាប្រិយភាពបំផុត ហើយវាជាតំបន់ពាណិជ្ជកម្មចំកណ្ដាលទីក្រុងភ្នំពេញដែលជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនោះ តំបន់នេះគឺ បណ្ដុំទៅដោយស្ថាបត្យកម្មប្រណិតៗ ផ្សារ ហាងលក់ទំនិញ ជាច្រើនដែលផ្ដល់ភាពងាយស្រួលក្នុងការរស់នៅ និងបំពេញនូវរាល់តម្រូវការជាច្រើនដូចជា ភោជនីយដ្ឋាន កន្លែងកម្សាន្តផងដែរ។

លើសពីនេះទៅទៀត គោលបំណងនៃការបង្កើតស្នាដៃស្រាវជ្រាវនេះឡើង គឺមានបំណងក្នុងការជួយជម្រុញឱ្យមាន ការអភិវឌ្ឍន៍ ការរៀបចំអោយមានសណ្ដាប់ធ្នាប់ល្អ និងសោភ័ណភាពរស់នៅស្រស់បំព្រងនៅក្នុងខណ្ឌដូនពេញ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ៖

រាល់ការសិក្សាស្រាវជ្រាវទាំងអស់ គឺសុទ្ធសឹងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ចំណែកការសិក្សាស្រាវជ្រាវដែលទាក់ទងនឹង " **ការរៀបចំខណ្ឌដូនពេញឱ្យមានសណ្ដាប់ធ្នាប់ និងសោភ័ណភាព** " គឺយើងខ្ញុំចង់បកស្រាយ និងបង្ហាញអំពីយន្តការ ដែលទាក់ទងនឹងការរៀបចំសណ្ដាប់ធ្នាប់ សោភ័ណភាពក្នុងខណ្ឌមួយនេះតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ៖

ការសិក្សាស្រាវជ្រាវទៅលើអត្ថបទនេះ គឺមានសារៈសំខាន់ណាស់ដល់មិត្តនិស្សិត និងមិត្តអ្នកអាន អ្នកស្រាវជ្រាវ សាធារណៈជនទាំងអស់ឱ្យបានយល់ដឹងកាន់តែស៊ីជម្រៅអំពីការរៀបចំផែនការយុទ្ធសាស្ត្រក្នុង ការអភិវឌ្ឍន៍នៅក្នុងទីក្រុង ដើម្បីធ្វើយ៉ាងណាឱ្យ ខណ្ឌដូនពេញមានសណ្ដាប់ធ្នាប់ និងសោភ័ណភាព។ និងចូលរួមចំណែកក្នុងការជម្រុញឱ្យការអភិវឌ្ឍន៍ថ្មីៗបន្ថែមទៀត។

## ៦. វិធីសាស្ត្រស្រាវជ្រាវ៖

ការសិក្សាស្រាវជ្រាវចំពោះប្រធានបទនេះគឺ យើងខ្ញុំបានស្វែងរកឯកសារដែលពាក់ព័ន្ធនានានៅក្នុងបណ្ណាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សាលាខណ្ឌដូនពេញ តាមរយៈប្រព័ន្ធអ៊ីនធឺណែត គេហទំព័រផ្សេងៗ ដោយក្នុងនេះយើងខ្ញុំបាន ប្រមូលផ្តុំឯកសារទាំងនោះយកមកវិភាគ និងសរសេរជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖**

សារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទនេះត្រូវបានបែងចែកចេញជា ២ ជំពូកគឺៈ

- **ជំពូកទី១ "ការរៀបចំសណ្តាប់ធ្នាប់របស់ខណ្ឌដូនពេញ"** ៖ នៅក្នុងជំពូកនេះខ្ញុំបាទនឹង បែងចែកជាពីរចំនុចបន្ថែមទៀត ដោយចំនុចទី១ និយាយអំពីទិដ្ឋភាពទូទៅនៃ ការរៀបចំ ខណ្ឌដូនពេញ និងចំនុចទី២ បង្ហាញអំពីបច្ចុប្បន្នភាពនៃការរៀបចំខណ្ឌដូនពេញ
- **ជំពូកទី២ "ការរៀបចំសោភ័ណភាព និងបរិស្ថានក្នុងខណ្ឌដូនពេញ"** ៖ នៅក្នុងជំពូក នេះខ្ញុំបាទនឹងបែងចែកជាពីរចំនុចបន្ថែមទៀត ដោយចំនុចទី១ និយាយអំពី ការរៀបចំ សោភ័ណភាពដែលមានក្នុង ខណ្ឌដូនពេញ និងចំនុចទី២ បង្ហាញអំពី បរិស្ថានស្អាតដោយ គ្មានការបំពុលផ្សេងៗក្នុង ខណ្ឌដូនពេញ។

# ជំពូកទី១
# ការរៀបចំសណ្ដាប់ធ្នាប់
# របស់ខណ្ឌដូនពេញ

# ជំពូកទី១
# ការរៀបចំសណ្តាប់ធ្នាប់របស់ខណ្ឌដូនពេញ

ជាដំបូងមុននឹងឈានចូលទៅដល់ការនិយាយរៀបរាប់អំពីការរៀបចំ និងការអភិវឌ្ឍន៍នានា នៅក្នុងខណ្ឌដូនពេញ ខ្ញុំបាទសូមធ្វើការអធិប្បាយបន្តិចអំពី ប្រវត្តិនៃការរៀបចំក្រុងដំបូងគេបង្អស់ នៅលើសកលលោកជាមុនសិន។ ទីក្រុងដំបូងគេនៅលើសកលលោកនោះ គឺជាទីក្រុង Faiyum នៅ ប្រទេសអេហ្ស៊ីប (Egypt) ដែលមានអាយុកាលប្រមាណជា ៤០០០ឆ្នាំមុនគ្រិស្តសករាជ។ ហើយ ទីក្រុង នេះមានទីតាំងនៅចំកណ្តាលប្រទេសអេហ្ស៊ីប (Egypt) មានចម្ងាយប្រមាណជា ១០០ គីឡូម៉ែត្រ ពី ភាគខាងត្បូងឆៀងខាងលិចនៃទីក្រុង Cario ។

ចំណែកឯការរៀបចំក្រុងវិញ ទីក្រុង Faiyum គឺមានសមិទ្ធិផលមួយចំនួនគួរឱ្យកត់សម្គាល់។ នៅក្នុងការសិក្សាស្រាវជ្រាវ របស់ប្រវត្តិវិទូបង្ហាញឱ្យឃើញថា ទីក្រុង Faiyum មានការរៀបចំឱ្យមាន លក្ខណៈល្អប្រសើរ។ បើយោងទៅតាមការស្រាវជ្រាវ គេបានរកឃើញនូវវត្ថុតាងសេសសល់មួយ ចំនួនដែលអាចកំណត់បានថា នៅសម័យនោះគឺមានការស្ថាបនា ស្ពាន ប្រព័ន្ធធារាសាស្ត្រ ផ្សារ កន្លែងងូតទឹក វិហារសាសនាជាដើម ដើម្បីផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។[1]

## ១.១. និយមន័យទូទៅ

ដើម្បីឱ្យមានភាពងាយស្រួលដល់ការបកស្រាយ និងមានភាពងាយស្រួលក្នុងការយល់ដល់ អត្ថន័យនៃប្រធានបទស្រាវជ្រាវខាងលើ យើងខ្ញុំសូមការអនុញ្ញាតដើម្បីបានបង្ហាញនូវ ពាក្យគន្លឹះ មួយចំនួនជាមុនសិន។ ពាក្យគន្លឹះទាំងនោះរួមមាន៖ ក្រុង សណ្តាប់ធ្នាប់ និងសោភ័ណភាព។

**ក្រុង ៖** សំដៅទៅលើទីកន្លែងដែលមិនមានសកម្មភាពកសិកម្ម។ លក្ខណៈវិនិច្ឆ័យផ្សេង ទៀតអាចរួមបញ្ចូល៖ ចំនួនប្រជាជន ទីធ្លាទំនេរ ដង់ស៊ីតេប្រជាជន និងចរន្តសេដ្ឋកិច្ច[2]។ ក្រុងអាច មានសំដៅទៅលើ នគរ ទីក្រុង រាជធានី បុរី[3]។

**សណ្តាប់ធ្នាប់ ៖** សំដៅទៅលើធាតុ៣ ៖ សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ[4]។

**សោភ័ណភាព ៖** យោងតាមវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត សំដៅលើ៖ ល្អ, ហ្មត់ហ្មង។ ហើយសោភ័ណភាពមានពីរគឺ ៖ សោភ័ណភាពពេលថ្ងៃ និងសោភ័ណភាពពេលយប់។ សោភ័ណភាពពេលថ្ងៃ សំដៅលើការកសាង ហេដ្ឋារចនាសម្ព័ន្ធគ្រប់បែបយ៉ាងរួមមាន ផ្លូវ ថ្នល់ អគារតូច.ធំ ទាំងរដ្ឋ និងឯកជន ភ្លើងសញ្ញា ស្លាកសញ្ញាចរាចរណ៍ ស្ពានអាកាស ផ្លូវក្រោមដី។ល។

[1] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា ទំព័រទី១ ដល់ទី៤

[2] Long, 1998

[3] វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជជួនណាត

[4] នីតិរដ្ឋបាលទូទៅ, ឯកឧត្តម បណ្ឌិត ថេង ច័ន្ទសង្វារ

ព្រមទាំងការធ្វើដំណើរតាមដងផ្លូវ នៃយានយន្ត គ្រប់ប្រភេទ មានសណ្ដាប់ធ្នាប់ល្អ។ ចំណែកឯសោភ័ណភាពពេលយប់វិញ គឺសំដៅដល់ ការបំពាក់ភ្លើងបំភ្លឺនានាក្នុងទីក្រុង ការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ នៅតាមទីសាធារណៈ និងតាមសំណង់ អគារតូច.ធំ។

➢ **ប្រវត្តិរាជធានីភ្នំពេញ៖**

រាជធានីភ្នំពេញ ត្រូវបានរកឃើញ និងបង្កើតឡើងដោយលោកយាយពេញ នៅក្នុងឆ្នាំ១៣៧២ ហើយបានក្លាយទៅជារាជធានីរបស់ព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ ១៨៦៩ រហូតមកដល់សព្វថ្ងៃនេះ។ រាជធានីភ្នំពេញ មានការរីកចម្រើនយ៉ាងខ្លាំងនៅមុនរបបប្រល័យពូជសាសន៍ ខ្មែរក្រហម។ ប៉ុន្តែគួរឱ្យសោកស្ដាយ ការរីកចម្រើននេះមិនបានមានភាពស្ថិតស្ថេរ រយៈពេលយូរអង្វែងនោះទេ។ លុះមកដល់ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជា ត្រូវបានធ្លាក់ចូលក្នុង របបដ៏ខ្មៅងងឹតពោលគឺ របបប្រល័យពូជសាសន៍ខ្មែរក្រហម។ ស្ថិតនៅក្នុងសម័យនោះ ទីក្រុងភ្នំពេញ ត្រូវប្រែប្រួលទាំងស្រុង។ ប្រជាជនដែលរស់នៅក្នុងទីក្រុង ត្រូវបានទាហានខ្មែរក្រហមជំលៀសបណ្ដេញចេញទៅរស់នៅតាមបណ្ដាខេត្តនានា ធ្វើឱ្យទីក្រុងដែលធ្លាប់តែសំបូរសប្បាយ មានភាពអ៊ូអរ ប្រែក្លាយទៅជាទីក្រុងខ្មោចដែលគ្មានមនុស្សរស់នៅ។ ទីក្រុងភ្នំពេញទាំងមូល ដែលធ្លាប់មាន មនុស្សច្រើនកុះករ ត្រូវជំនួសដោយទាហានបំពាក់ដោយអាវុធគ្រប់ដៃ។ រថយន្ត ម៉ូតូ និងកង់ដែលធ្លាប់ធ្វើដំណើរនៅក្នុងទីក្រុងនោះ ត្រូវបានជំនួសដោយរថក្រោះទៅវិញ។ ក៏ប៉ុន្តែមិនបានយូរប៉ុន្មាន របបនេះបានបញ្ចប់ទៅវិញនៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩ ជាថ្ងៃដែលទីក្រុងភ្នំពេញត្រូវបានដណ្ដើមបានមកវិញទាំងស្រុងពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងជាថ្ងៃដែលទីក្រុងភ្នំពេញ បានចាប់កំណើតឡើងវិញសារជាថ្មី។

បន្ទាប់ពីរបបប្រល័យពូជសាសន៍រលំរលាយទៅ ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងមានភាពលំបាកជាខ្លាំង ដោយសារតែទីក្រុងភ្នំពេញ ត្រូវបានបំផ្លាញខ្ទេចខ្ទីគ្មានសេសសល់អ្វីទាំងអស់។ គេសង្កេតឃើញថា ការរស់នៅក្នុងទីក្រុងនាពេលនោះ ប្រជាពលរដ្ឋត្រូវទ្រាំរស់នៅក្នុងស្ថានភាពដ៏លំបាកជាច្រើនដូចជា ខ្វះខាតភ្លើងអគ្គិសនី បញ្ហាទឹកស្អាត កង្វះនូវថ្នាំសង្កូវ មន្ទីរពេទ្យ និងបញ្ហាសន្តិសុខសណ្ដាប់ធ្នាប់។ល។ លុះមកដល់ក្រោយឆ្នាំ ១៩៨០ ស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ គឺមានលក្ខណៈល្អប្រសើរឡើងវិញជាបណ្ដើរៗ។ ដោយសារមានការអភិវឌ្ឍន៍ រីកចម្រើនឥតឈប់ឈរ មកដល់ពេលបច្ចុប្បន្ននេះរាជធានីភ្នំពេញមានការកែសម្រួលព្រំប្រទល់ចំនួន ៤ដំណាក់កាលធំៗមកហើយ។ ការកែសម្រួលព្រំប្រទល់ទាំង ៤ដំណាក់កាលនោះមានដូចជា[5]៖

[5] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/ ដកស្រង់នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៩

- លើកទី១៖ គឺការបញ្ចូលស្រុកដង្កោ
- លើកទី២៖ ការបង្កើតខណ្ឌឫស្សីកែវ
- លើកទី៣៖ ការបញ្ចូល៨ភូមិ របស់ឃុំកន្ទោក មកក្នុងដែនដីរដ្ឋបាលរាជធានីភ្នំពេញ
- លើកទី៤៖ ការបញ្ចូល២០ឃុំ របស់ស្រុក៥ (ពញាឮ, មុខកំពូល, កៀនស្វាយ, កណ្ដាលស្ទឹង, អង្គស្នួល) នៃខេត្តកណ្ដាល មកក្នុងដែនដីរដ្ឋបាលរាជធានីភ្នំពេញ។

យោងតាម គេហទំព័រសាលារាជធានីភ្នំពេញ នាពេលបច្ចុប្បន្ននេះរាជធានីភ្នំពេញមានផ្ទៃដីសរុបចំនួន ៦៩២,៤៦ គីឡូម៉ែត្រក្រឡា។ ចំពោះប្រជាជន នៅក្នុងរាជធានីភ្នំពេញវិញមានចំនួនសរុប ១.៤៧០.៣០៣ នាក់ (ឆ្នាំ២០១៨) ក្នុងនោះស្ត្រីមានចំនួន ៩៦០.០៨១ នាក់ ដែលស្មើនឹង ៣០៥.៧៦៧ គ្រួសារ។ ជាមួយគ្នានេះដែរ រាជធានីភ្នំពេញមានដង់ស៊ីតេប្រជាជនរស់នៅ មានចំនួនស្មើនឹង ២.២១៣ នាក់នៅក្នុងមួយគីឡូម៉ែត្រការ៉េ។ រីឯដែនដីនៅក្នុងរាជធានីភ្នំពេញវិញ ត្រូវបានបែងចែកចេញជា ១៤ ខណ្ឌ។[6]

ខណ្ឌទាំង ១៤ នៅក្នុងរាជធានីភ្នំពេញនោះមានដូចជា៖

- ខណ្ឌដូនពេញ
- ខណ្ឌទួលគោក
- ខណ្ឌ៧មករា
- ខណ្ឌដង្កោ
- ខណ្ឌមានជ័យ
- ខណ្ឌឫស្សីកែវ
- ខណ្ឌពោធិសែនជ័យ
- ខណ្ឌសែនសុខ
- ខណ្ឌចំការមន
- ខណ្ឌច្បារអំពៅ[7] (ថ្មី)
- ខណ្ឌជ្រោយចង្វារ[8] (ថ្មី)
- ខណ្ឌព្រែកព្នៅ[9] (ថ្មី)

---

[6] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៩

[7] អនុក្រឹត្យលេខ ៥៤៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៣ ស្ដីពី ការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ

[8] អនុក្រឹត្យលេខ ៥៧៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១៣ ស្ដីពី ការបង្កើតខណ្ឌជ្រោយចង្វារ នៃរាជធានីភ្នំពេញ

[9] អនុក្រឹត្យលេខ ៥៨៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១៣ ស្ដីពី ការបង្កើតខណ្ឌព្រែកព្នៅ នៃរាជធានីភ្នំពេញ

- ខណ្ឌបឹងកេងកង[10] (ថ្មី)
- ខណ្ឌកំបូល[11] (ថ្មី)

ដោយសារតែការរៀបរាប់អំពី រាជធានីភ្នំពេញទាំងមូល មានលក្ខណៈទូលំទូលាយពេក ដូចនេះ នៅក្នុងអត្ថបទសារណាបញ្ចប់ការសិក្សាយើងខ្ញុំ សូមធ្វើការកម្រិតនូវ ដែនកំណត់ និយាយរៀបរាប់តែ អំពីខណ្ឌដូនពេញ មួយតែប៉ុណ្ណោះ។

### ១.១.១. មូលហេតុដែលនាំឱ្យមានការរៀបចំខណ្ឌដូនពេញ

ដូចដែលបានដឹងហើយថា បន្ទាប់ពីការបញ្ចប់សង្គ្រាមតាមរយៈ នយោបាយ ឈ្នះ-ឈ្នះ របស់រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា គឺមានការអភិវឌ្ឍន៍រីកលូតលាស់លើគ្រប់វិស័យទាំងវិស័យរដ្ឋ និងវិស័យឯកជន។ ជាពិសេស ការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគមនាគមន៍ មន្ទីរពេទ្យ សាលារៀន វត្តអារាម គ្រឹះស្ថាន ស្ថាប័ន រដ្ឋ និងឯកជន ព្រមទាំងសំណង់លំនៅដ្ឋានទំនើបៗ។ ជាមួយគ្នានេះដែរ ខណ្ឌដូនពេញ គឺជាខណ្ឌដែលត្រូវបាន គេចាត់ទុកថាជាខណ្ឌមួយដ៏មានប្រជាប្រិយភាពបំផុតហើយវាជា តំបន់វប្បធម៌ចម្រុះ និងពាណិជ្ជកម្មនៅចំកណ្ដាល ទីក្រុងភ្នំពេញដែលជាបេះដូងនៃ ព្រះរាជាណាចក្រកម្ពុជា និងជាខណ្ឌដ៏ចំណាស់មួយក្នុងចំណោមខណ្ឌទាំង ១៤ ក្នុងរាជធានីភ្នំពេញ។

ខណ្ឌដូនពេញ មានទីតាំងស្ថិតនៅជាប់តំបន់ដងទន្លេ ដែលអាចមើលឃើញទេសភាពដ៏ស្រស់ស្អាតរបស់ដងទន្លេសាប នៅខាងមុខព្រះបរមរាជវាំង និងផ្ដល់ខ្យល់អាកាសស្រស់ស្រាយនៅតាមដងទន្លេ។ ចំពោះខណ្ឌដូនពេញនេះដែរ មានផ្ទៃក្រឡាសរុបចំនួន ៧,៤៤ គីឡូម៉ែត្រការ៉េ មានប្រជាជនរស់នៅចំនួន ១២២,៥៦០ នាក់ (ឆ្នាំ២០១០) ត្រូវបាន បែងចែកចេញជា ១១ សង្កាត់ និង ១៣៤ ភូមិ ដែលមានព្រំប្រទល់ ខាងកើត ទល់នឹង ដងទន្លេសាប ខាងលិច ទល់នឹង ខណ្ឌ ៧ មករា និងខណ្ឌទួលគោក ខាងជើង ទល់នឹង ខណ្ឌឬស្សីកែវ និងខាងត្បូង ទល់នឹង ខណ្ឌចំការមន ។

បច្ចុប្បន្នសង្កាត់ទាំង ១១ នៅក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញមានៈ

- សង្កាត់ផ្សារថ្មីទី១
- សង្កាត់ផ្សារថ្មីទី២
- សង្កាត់ផ្សារថ្មីទី៣
- សង្កាត់បឹងរាំង
- សង្កាត់ផ្សារកណ្ដាលទី១
- សង្កាត់ផ្សារកណ្ដាលទី២

[10] អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៩ ស្ដីពី ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ
[11] អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ២០១៩ ស្ដីពី ការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ

- សង្កាត់ចតុមុខ
- សង្កាត់ជ័យជំនះ
- សង្កាត់ផ្សារចាស់
- សង្កាត់ស្រះចក
- សង្កាត់វត្តភ្នំ[12]។

នៅក្នុងខណ្ឌដូនពេញគឺ មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ដែលបង្កឱ្យមានលក្ខណៈងាយស្រួលដល់ ប្រជាពលរដ្ឋក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ បន្ថែមពីនេះទៅទៀត តាមទិន្នន័យរបស់គេហទំព័រសាលារាជធានីភ្នំពេញ បានបង្ហាញឱ្យឃើញថានៅក្នុង ខណ្ឌដូនពេញមានអត្រាប្រជាជនក្រីក្របានថយចុះពី ៥,៣៦% នៅក្នុងឆ្នាំ ២០០៥ មកនៅសល់តិចតួចបំផុតគួរឱ្យកត់សម្គាល់ នៅក្នុងឆ្នាំ ២០១០។ តាមទិន្នន័យខាងលើនេះ សបញ្ជាក់ឱ្យ ឃើញថាក្នុងរយៈពេល ៥ឆ្នាំ អត្រានៃប្រជាជនក្រីក្របានថយចុះប្រមាណជាជាង ៥% ដែលខណ្ឌដូនពេញ គឺមានការអភិវឌ្ឍន៍ក្នុងល្បឿនលឿនមួយដែល គួរឱ្យកត់សម្គាល់។

ទោះជាយ៉ាងណាក៏ដោយ ខណ្ឌដូនពេញ គឺត្រូវតែមានការអភិវឌ្ឍន៍ថ្មីៗជាបន្តបន្ទាប់បន្ថែមទៀត។ មានកត្តាជាច្រើន ដែលជាកត្តាជម្រុញឱ្យមានការអភិវឌ្ឍន៍ខណ្ឌនេះទៀតនោះគឺមាន៖

### ១.១.១.១. បញ្ហាកំណើនប្រជាជន

បញ្ហាកំណើនប្រជាជន ក្នុងទីក្រុងមានសមាសភាពចំនួន ៣ សំខាន់ៗ ដោយក្នុងនោះមាន៖ កំណើនប្រជាជនក្នុងទីក្រុងជាលក្ខណៈធម្មជាតិ, កំណើនប្រជាជនដោយសារមានការចំណាកស្រុកមកពីជនបទ និងបញ្ហាកំណើតប្រជាជនដោយសារតែមានការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មីដែលពីមុនមកតំបន់នោះជាទីជនបទប៉ុណ្ណោះ។[13]

បញ្ហាកំណើនប្រជាជន គឺជាបញ្ហាចំបងមួយ និងអាចចាត់ទុកបានជាបញ្ហាសំខាន់ដែលបង្កើតឱ្យមានបញ្ហាផ្សេងៗ ជាច្រើនផ្សេងទៀត។ ដូចដែលបានរៀបរាប់ខាងលើប្រជាជននៅក្នុងរាជធានីភ្នំពេញ មានចំនួនសរុប ១.៤៧០.៣០៣ នាក់ ហើយមានអត្រាកើនឡើងនៃប្រជាជនប្រមាណជាជាង ១,៤៦% ជារៀងរាល់ឆ្នាំ។[14] ជាក់ស្តែង ចំនួនប្រជាជនដែលរស់នៅក្នុងខណ្ឌដូនពេញ តម្រូវការរបស់ប្រជាជន ក៏មានកើនឡើងជាលំដាប់ផងដែរ។ ដោយសារតែកំណើនប្រជាជនកើនឡើងច្រើន

---

[12] គេហទំព័រ https://sopheaksrey.wordpress.com/2017/02/28/khan-in-phnompne-2017/ ដកស្រង់នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៩

[13] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ ២០១៩, ទំព័រទី៦

[14] គេហទំព័រ http://worldpopulationreview.com/countries/cambodia-population/ ដកស្រង់នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៩

ដែលជាហេតុនាំឱ្យមានការអភិវឌ្ឍន៍ និងរៀបចំសណ្តាប់ធ្នាប់ខណ្ឌ។ ដើម្បីដោះស្រាយបញ្ហា និងបំពេញនូវតម្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋដែលកំពុងជួបប្រទះជាក់ស្តែង។

### ១.១.១.២. បញ្ហាចរាចរណ៍

បញ្ហាចរាចរណ៍ គឺជាបញ្ហាមួយសំខាន់ដែលបង្កឡើងតាមរយៈ កំណើនប្រជាជនកើនឡើងលឿន។ ដោយសារតែចំនួនប្រជាជនចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ បណ្តាលឱ្យស្ថានភាពចរាចរណ៍កាន់តែមានភាពមមារញឹក និងមានលក្ខណៈចង្អៀតកាន់ខ្លាំងឡើងៗ។ ជាក់ស្តែងនៅក្នុងរាជធានីភ្នំពេញមាន រថយន្តធុនតូចចំនួន ៩៤,៧៨២ គ្រឿង, រថយន្តធុនធំចំនួន ៨,២១៣ គ្រឿង ទោចក្រយានយន្តចំនួន ៥៦២,៦២៣ គ្រឿង, ត្រីចក្រយានយន្តចំនួន ១,១៣៧ គ្រឿង និង ទោចក្រយានយន្តសណ្តោងរ៉ុម៉កចំនួន ៣,៣៣៦ គ្រឿង។[15]

ផ្អែកតាមទិន្នន័យរបស់គេហទំព័ររបស់ សាលារាជធានីភ្នំពេញ យានយន្តសរុបនៅក្នុងរាជធានីភ្នំពេញមានចំនួន ៦៧០,០៩១ គ្រឿង។ ដោយសារតែមានការកើនឡើងចំពោះ យានយន្តយ៉ាងច្រើនដូចដែលបានបង្ហាញ ខាងលើនេះទើបជាមូលហេតុជម្រុញឱ្យមាន ការរៀបចំប្រព័ន្ធគមនាគមន៍ និងមានការអភិវឌ្ឍន៍ទីក្រុង ក៏ដូចជាក្នុងខណ្ឌ។

### ១.១.១.៣. បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់

បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺជាបញ្ហាមួយដ៏សំខាន់ដែលអាចកើតឡើងតាមរយៈ ភាពអសន្តិសុខ និងសំណង់អនាធិបតេយ្យនៅក្នុងសង្គមក៏ជាកត្តាមួយដែលជម្រុញឱ្យ មានការអភិវឌ្ឍន៍ និងរៀបចំក្រុង។ ដោយសារតែភាពអនាធិបតេយ្យនេះបានធ្វើឱ្យមានផលប៉ះពាល់ ទៅដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងទីក្រុង។ ចំពោះបញ្ហានេះដែរ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដើម្បីជាការធានាដល់សុវត្ថិភាពសន្តិសុខសណ្តាប់ធ្នាប់ របស់ប្រជាជនមិនឱ្យមានអំពើចោរកម្ម លួច ឆក់ ប្លន់, គ្មានក្មេងទំនើងគ្រប់ប្រភេទ, គ្មានល្បែងស៊ីសងគ្រប់ប្រភេទ, គ្មានអំពើហិង្សា, គ្មានបទល្មើសគ្រប់ប្រភេទ, គ្មានការ ជួញដូរកុមារ ពេស្យាចារ ការជួញដូរមនុស្ស និងគ្មានការជួញដូរគ្រឿងញៀន ចែកចាយគ្រឿងញៀន។[16] បញ្ហាដូចដែលបានបង្ហាញខាងលើនេះ គឺមូលហេតុដែលជម្រុញឱ្យមានការរៀបចំសណ្តាប់ធ្នាប់ ដើម្បីធានាដល់សន្តិសុខ សុវត្ថិភាព នៃការរស់នៅប្រជាពលរដ្ឋរស់នៅក្នុងខណ្ឌដូនពេញផងដែរ។

---

[15] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៩

[16] ផែនការណែនាំ លេខ ០២០ ផក ស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព

### ១.១.២. រចនាសម្ព័ន្ធរបស់ខណ្ឌដូនពេញ

រចនាសម្ព័ន្ធរបស់ខណ្ឌដូនពេញ ដោយអនុលោមតាមប្រកាសលេខ ៣៨៤ ប្រក ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០០ ស្តីពី តួនាទីភារកិច្ច របៀបរបបការងារ រចនាសម្ព័ន្ធ នៃសាលាស្រុក ខណ្ឌ និង ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧ ឆ្នាំ ២០០៨ ខណ្ឌដូនពេញ មានរចនាសម្ព័ន្ធរដ្ឋបាលដូចជា ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សាគណៈអភិបាល ការិយាល័យជំនាញ នាយករដ្ឋបាល និងការិយាល័យជំនាញផ្សេងៗទៀត។

#### ១.១.២.១. ក្រុមប្រឹក្សាខណ្ឌ

ក្រុមប្រឹក្សាខណ្ឌ បង្កើតឡើងដោយការបោះឆ្នោតអនុលោមតាម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាបុគ្គលសាធាណៈជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[17]

ជាក់ស្តែងសមាជិកក្រុមប្រឹក្សាខណ្ឌដូនពេញ សម្រាប់អាណត្តិទី៣ បច្ចុប្បន្ននេះមានចំនួន ១៩ នាក់ ស្ត្រីមានចំនួន ៥នាក់ អនុលោមតាម អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពី ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុងប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់ អាណត្តិទី៣ ។

ជាមួយគ្នានេះ ក្រុមប្រឹក្សាខណ្ឌដូនពេញមានតួនាទីពីរយ៉ាង៖ តួនាទីសំខាន់ទីមួយគឺ ក្រុមប្រឹក្សាត្រូវធ្វើអ្វីដែលចាំបាច់ដើម្បីសម្រេចនូវគោលបំណងរបស់ខ្លួនក្នុងការបង្កើត ការជម្រុញ និងធ្វើឱ្យមានចីរភាពដល់ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅក្នុងដែនដីរបស់ខ្លួន។ រីឯតួនាទីសំខាន់មួយ ទៀតនោះគឺ ក្រុមប្រឹក្សាខណ្ឌដូនពេញអនុវត្តន៍មុខងារ ដែលត្រូវបានផ្ទេរមកឱ្យក្រុមប្រឹក្សាក្រោមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ នៅក្នុងការបំពេញតួនាទីជាទូទៅរបស់ខ្លួន ក្រុមប្រឹក្សាមានសិទ្ធិអំណាចចំនួនពីរគឺ អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

បន្ថែមពីនេះ នៅក្នុងការបំពេញតួនាទី និងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សាខណ្ឌដូនពេញក៏ដូចជាក្រុមប្រឹក្សាដទៃទៀតមានគណនេយ្យភាពលើគោលនយោបាយ សេចក្តីសម្រេចសកម្មភាព និងការប្រើប្រាស់ធនធានសាធារណៈរបស់ខ្លួន។ ក្រុមប្រឹក្សាខណ្ឌដូនពេញ ត្រូវមានការឆ្លើយតបទៅនឹងតម្រូវការ និងអនុវត្តន៍សកម្មភាពដើម្បីជាផលប្រយោជន៍ ដ៏ប្រសើរបំផុតរបស់ ប្រជា-

[17] អនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

ពលរដ្ឋ។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាខណ្ឌអនុវត្តន៍នូវអំណាចបញ្ញត្តិរបស់ខ្លួនតាមរយៈការធ្វើ ដីកា[18]។ ហើយក្រុមប្រឹក្សាខណ្ឌដូនពេញមាន សិទ្ធិដាក់ចេញដីកាលើការងារណាដែលស្ថិតនៅក្នុងវិសាលភាពនៃតួនាទីភារកិច្ច និងមុខងាររបស់ខ្លួន។ ចំពោះចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជារាស្ត្រ និងកត្តាភូមិសាស្ត្រផងដែរ។[19]

### ១.១.២.២. គណៈអភិបាលខណ្ឌ

ជាទូទៅនៅតាមខណ្ឌនីមួយៗត្រូវមាន គណៈអភិបាលខណ្ឌមួយ ដែលក្នុងនោះរួមមាន អភិបាលខណ្ឌចំនួន ១ រូប (មួយ) និងអភិបាលរងខណ្ឌមួយចំនួន ដែលត្រូវបានតែងតាំងឡើងស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គួរបញ្ជាក់ផងដែរថា អភិបាលខណ្ឌ និងអភិបាលរងខណ្ឌនោះមិនមែនជាសមាជិកក្រុមប្រឹក្សាខណ្ឌឡើយ។

អភិបាលខណ្ឌ គឺត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតនៅក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់របស់ក្រសួងមហាផ្ទៃ មានឋានន្តរសក្តិចាប់ពី អនុមន្ត្រីឡើងទៅ និងមានអាយុយ៉ាងតិច ៣០ ឆ្នាំ និងមានបទពិសោធន៍ការងាររដ្ឋបាលសាធារណៈយ៉ាងតិច ៥ ឆ្នាំ។[20] រីឯ អភិបាលរងខណ្ឌវិញ គឺត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតនៅក្នុងក្របខណ្ឌមន្ត្រីរបស់ក្រសួងមហាផ្ទៃ និងមានឋានន្តរសក្តិចាប់ពី នាយកក្រមការ ហើយមានអាយុយ៉ាងតិច ២០ ឆ្នាំ និងមានបទពិសោធន៍ការងាររដ្ឋបាលសាធារណៈយ៉ាងតិច ៣ ឆ្នាំ។[21]

អភិបាលខណ្ឌដូនពេញ គឺមានតួនាទីសំខាន់បីយ៉ាង ដែលត្រូវបានប្រគល់ឱ្យដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានដូចជា៖

តួនាទីដំបូងបង្អស់របស់អភិបាលខណ្ឌដូនពេញ គឺជាប្រធានគណៈអភិបាល។ ដូច្នេះគាត់ត្រូវបម្រើ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាខណ្ឌ។ ចំណែកឯតួនាទីទីពីរនោះ គឺជាអ្នកតំណាងឱ្យក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យ សម្របសម្រួល និងដឹកនាំការិយាល័យខ្សែបណ្តោយនានា ដែលដំណើរការនៅក្នុងដែនដីរបស់ខ្លួន។ ដូច្នេះ នៅក្នុងតួនាទីនេះដែរអភិបាលខណ្ឌត្រូវបម្រើ និងទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល និងចំពោះក្រសួងស្ថាប័នដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។[22] បន្ថែមពីនេះទៅទៀត តួនាទីទីបី គឺជាតំណាងឱ្យក្រសួង និងស្ថាប័នរបស់

---

[18] ដីកា គឺជាវិធានផ្អែកផ្លូវច្បាប់ ដែលបានអនុម័តដោយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ហើយត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចទាំងមូលក្នុងមូលដ្ឋានខណ្ឌរបស់ខ្លួន។

[19] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, មាត្រា ១៨

[20] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, មាត្រា ១៤៨

[21] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, មាត្រា ១៤៨

[22] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, មាត្រា ១៥៤

រាជរដ្ឋាភិបាលលើការងារទំនាក់ទំនង សន្តិសុខសណ្តាប់ធ្នាប់សង្គម សណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្សនៅក្នុងដែនដីរបស់ខ្លួន។

ជាមួយគ្នានេះដែរ អភិបាលខណ្ឌដូនពេញក៏មានតួនាទីយ៉ាងសំខាន់នៅក្នុងរដ្ឋបាលឯកភាព ដោយមានគោលបំណងសម្រេចឱ្យបាននូវការ អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅក្នុងមូលដ្ឋាន ប្រកបដោយតម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។[23]

ជាការពិតណាស់ ក្នុងសាលាខណ្ឌ អភិបាលនៃគណៈអភិបាលខណ្ឌត្រូវមានភារកិច្ចទទួលបន្ទុកដូចជាៈ

- ដឹកនាំការងាររួម
- ដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ
- ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ចំណែកឯ អភិបាលរងប៉ុន្មានរូបទៀត ត្រូវមាន ភារកិច្ចទទួលបន្ទុកទៅលើការិយាល័យជំនាញផ្សេងទៀតមានដូចជាៈ

- ការិយាល័យផែនការ និងអភិវឌ្ឍន៍
- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យ ច្រកចេញ.ចូល តែមួយ
- ការិយាល័យ អន្តរវិស័យ។

[23] សៀវភៅ នីតិរដ្ឋបាលទូទៅ, អនុបណ្ឌិត ហៀង សាង បោះពុម្ពឆ្នាំ ២០១៥, ទំព័រទី៨០ ដល់៨២

## រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល




- **ការិយាល័យផែនការ និងអភិវឌ្ឍន៍ៈ**
  - ការងារផែនការ
  - អនុវត្តន៍គម្រោង និងកម្មវិធីអភិវឌ្ឍន៍
  - សម្របសម្រួល ការគាំទ្រកិច្ចសហប្រតិបត្តិការការអភិវឌ្ឍន៍
  - ត្រួតពិនិត្យ វាយតម្លៃ។
- **ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ៖**
  - ការងាររដ្ឋបាល សរុប និងបុគ្គលិក
  - ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន
  - ព័ត៌មាន
  - ការងារហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិ
  - ការងារលេខាធិការក្រុមប្រឹក្សា។

- **ការិយាល័យអន្តរវិស័យ ៖**
  - ការងារដីធ្លី និងសំណង់
  - ការងារសណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស
  - ការងារសេដ្ឋកិច្ច សង្គមកិច្ច
  - ការងារដោះស្រាយវិវាទនៅមូលដ្ឋាន។
- **ការិយាល័យច្រក ចេញ.ចូល តែមួយ ៖**
  - ការងារនីត្យានុកូលកម្ម
  - វិស័យវប្បធម៌ និងវិចិត្រសិល្បៈ
  - វិស័យអប់រំ យុវជន និងកីឡា
  - វិស័យទេសចរណ៍
  - វិស័យកសិកម្ម
  - ការងារអត្រានុកូលដ្ឋាន
  - វិស័យសំណង់
  - វិស័យឧស្សាហកម្ម រ៉ែ និងថាមពល
  - វិស័យពាណិជ្ជកម្ម
  - វិស័យសាធារណការ និងដឹកជញ្ជូន
  - វិស័យសុខាភិបាល
  - វិស័យសុរិយោដី។
- **អង្គភាពលទ្ធកម្ម៖**
  - ការងារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ
  - ការងារផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
  - សេចក្តីព្រាងកិច្ចសន្យាដោយអនុលោមតាមបទដ្ឋាន និងគំរូកិច្ចសន្យា
  - តាមដានការទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ អ្នកទទួលការ ឬទីប្រឹក្សា
  - រៀបចំរបាយការណ៍ស្តីពីការអនុវត្តន៍កិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

## ១.២. បច្ចុប្បន្នភាពនៃការរៀបចំខណ្ឌដូនពេញ

ខណ្ឌដូនពេញ គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង ១៤ របស់រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅចំកណ្តាលរាជធានីតែម្តង។ ជាងនេះទៅទៀត ក្នុងខណ្ឌដូនពេញ គឺជាខណ្ឌមួយសំបូរទៅដោយសំណង់អាគាររតនភណ្ឌល្បីៗ សំណង់អគារទំនើបខ្ពស់ៗ លំនៅដ្ឋាន សណ្ឋាគារ សួនច្បារ មជ្ឈមណ្ឌលកម្សាន្ត មជ្ឈមណ្ឌលពាណិជ្ជកម្ម ផ្សារទំនើបជាច្រើន ព្រមទាំងមានដងវិថីតូចធំ ខ្វាត់ខ្វែង ដែលផ្តល់ភាពងាយស្រួលសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលនៅក្នុងតំបន់នេះ និងអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកចូលទស្សនា និងទិញទំនិញគ្រប់ប្រភេទ។ ក្រៅពីនេះ ភាគខាងកើតនៃខណ្ឌដូនពេញ ដែលស្ថិតនៅជាប់អ័ក្សទន្លេសាប វាជាទីតាំងល្អបំផុតសម្រាប់ ការរស់នៅរបស់ប្រជាពលរដ្ឋក្នុង ការលំហែកម្សាន្ត ស្រូបយកខ្យល់អាកាសស្រស់ស្រាយតាមដងទន្លេ ហើយខណ្ឌនេះជាទិសដៅលេខ១ សម្រាប់ភ្ញៀវទេសចរណ៍ក្នុងទីក្រុងភ្នំពេញ គឺជាកន្លែងកម្សាន្តដ៏ធំរបស់រាជធានីភ្នំពេញ។ នៅក្នុងតំបន់នេះដែរ ភ្ញៀវទេសចរណ៍ប្រើប្រាស់សេវាកម្មទេសចរណ៍បាន យ៉ាងងាយស្រួល ដែលមានដូចជា ទីតាំងលក់សំបុត្ររថយន្តក្រុងទិសដៅចេញពីរាជធានីភ្នំពេញទៅតាមបណ្តាខេត្តនានា ទីតាំងលក់សំបុត្រទេសចរណ៍តាមនាវាទស្សនាទីក្រុងពេលរាត្រី ផ្សាររាត្រីជាដើម។ល។[24] មិនតែប៉ុណ្ណោះ នៅក្នុងខណ្ឌនេះ មានសំណង់អគារតូចធំរបស់ស្ថាប័នរដ្ឋ និងឯកជន សាលារៀន មន្ទីរពេទ្យ ជាច្រើនដែលបោះ ទីតាំងនៅក្នុងសង្កាត់ទាំង ១១ នៃខណ្ឌដូនពេញ ទាំងនេះបានបង្ក លក្ខណៈងាយស្រួលដល់ ការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខណ្ឌ ដែលជាការឆ្លើយតបនូវ តម្រូវការជាក់ស្តែងនៅក្នុងនេះមានដូចជាសេវាសាធារណៈ សេវាសុខាភិបាល និងសេវាផ្សេងៗទៀតសម្រាប់បម្រើជូនប្រជាពលរដ្ឋ។

### ១.២.១. ការអភិវឌ្ឍន៍ផ្នែកសំណង់ លំនៅដ្ឋានក្នុងខណ្ឌដូនពេញ

នាពេលបច្ចុប្បន្ននេះ នៅក្នុងខណ្ឌដូនពេញ សង្កេតឃើញថាមានការអភិវឌ្ឍន៍រីកលូតលាស់ផ្នែកសំណង់ជាច្រើនដែរគួរឱ្យកត់សម្គាល់។ ប៉ុន្តែបើធ្វើការប្រៀបធៀបទៅនឹងខណ្ឌ ដទៃទៀត ការអភិវឌ្ឍន៍ផ្នែកសំណង់នេះមានលក្ខណៈតិចតួចជាងគេនៅឡើយទេ។ តែទោះបីជា យ៉ាងណាបើធ្វើការប្រៀបធៀបការអភិវឌ្ឍន៍នៅក្នុងខណ្ឌកាលពីសម័យមុន គឺឃើញថាក្នុងបច្ចុប្បន្នភាពមានការអភិវឌ្ឍន៍រីកចម្រើនខ្លាំង។ ជាក់ស្តែងការអភិវឌ្ឍន៍នៅក្នុងខណ្ឌដូនពេញ មានការអភិវឌ្ឍន៍ទៅលើសំណង់ស្ទើរគ្រប់វិស័យទាំងសំណង់លំនៅដ្ឋាន សំណង់អគារសហកម្មសិទ្ធិ សំណង់អគារសម្រាប់ធ្វើអាជីវកម្ម និងសំណង់អគារផ្សេងៗទៀត។

សំណង់ទាំងនោះរួមមានដូចជាៈ

[24] គេហទំព័រ https://www.realestate.com.kh/km/news/daun-penh-district-phnom-penh/ ដកស្រង់នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៩

### ១.២.១.១. លំនៅដ្ឋាន

ចំពោះសំណង់លំនៅដ្ឋាន នៅក្នុងខណ្ឌដូនពេញវិញ គឺភាគច្រើនសុទ្ធសឹងតែសំណង់ផ្ទះល្វែង និងផ្ទះដែលត្រូវបានបន្សល់ទុកតាំងពី សម័យអាណានិគមបារាំងមកម្ល៉េះ ហើយមានផ្ទះដីឡូត៍តិចតួចបំផុត។ ជាមួយគ្នានេះ សំណង់លំនៅដ្ឋាន ជាចំណុចមួយដែលអាជ្ញាធរត្រូវពិនិត្យ និងការពារសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈប្រកបដោយគុណភាពខ្ពស់ និងត្រូវដឹងពីផលប៉ះពាល់ក្នុងការជួសជុល ឬការកែសម្រួលនៅតាមបណ្តាសំណង់នានា ព្រមជាមួយនឹងការចេញនូវលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ អគារលំនៅដ្ឋាន អគារសាធារណៈ ដែលធ្វើការសាងសង់ខុសលក្ខណៈក្បួនច្បាប់បច្ចេកទេសនៃការសាងសង់។[25] ជាការពិតណាស់ លំនៅដ្ឋាន និងការតាំងទីលំនៅថ្មីជាបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ទីក្រុង ដែល តម្រូវឱ្យមានការចូលរួមពីវិស័យនានាទាំងថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិក្នុងការកសាងផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី ការងារសំណង់ ស្ថាបត្យកម្ម វិស្វកម្ម ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ការស្វែងរកហិរញ្ញប្បទាន និងប្រភពធនធានការវាយតម្លៃ អំពីផលប៉ះពាល់បរិស្ថាន និងសង្គម។ បន្ថែមពីនេះទៀត គោលនយោបាយលំនៅដ្ឋាន ត្រូវសង្កត់ធ្ងន់លើយុទ្ធសាស្ត្រគាំទ្រ ដូចជាការចូលរួមសម្រេចរបស់សហគមន៍មូលដ្ឋាន និងការផ្តល់នូវ ហិរញ្ញប្បទានសម្រាប់ជួសជុល ឬសាងសង់លំនៅដ្ឋាន ការសាងសង់លំនៅដ្ឋានថ្មីដើម្បីដោះស្រាយ តម្រូវការចំពោះមុខ ការកំណត់មូលដ្ឋានសម្រាប់ការរៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី នៅទីក្រុង ទីប្រជុំជន ទីជនបទ ការរៀបចំប្រភេទផ្សេងៗនៃលំនៅដ្ឋានស្របតាមតម្រូវការរបស់ ប្រជាពលរដ្ឋ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ និងការកំណត់វាយតម្លៃសេវានៃ ការអនុញ្ញាតសាងសង់។ល។[26]

នៅក្នុងខណ្ឌដូនពេញ រាល់សំណង់លំនៅដ្ឋានស្ទើរតែទាំងអស់ គឺត្រូវបានសាងសង់ឡើងដោយគោរពបានត្រឹមត្រូវតាម ច្បាប់សាងសង់ដែលបានកំណត់ ដូចជាប្លង់ជួរតម្រង់ និងប្លង់កម្ពស់ជាដើម។ ដូច្នេះអាចបញ្ជាក់ឃើញថាមិនសូវមានសំណង់ណាដែលសាងសង់ បំពានច្បាប់នោះទេ។ ដោយសារតែការគោរពច្បាប់បានត្រឹមត្រូវ ទើបធ្វើឱ្យខណ្ឌដូនពេញ មានសោភ័ណភាព និងមានសណ្តាប់ធ្នាប់ល្អ គួរឱ្យទាក់ទាញ។

### ១.២.១.២. សំណង់អគារសហកម្មសិទ្ធិ

ចំណែកឯ សំណង់អគារសហកម្មសិទ្ធិដែលមានលក្ខណៈទំនើបធំៗ នៅក្នុងខណ្ឌដូនពេញមានភាគច្រើន នៅក្នុងសង្កាត់ស្រះចក សង្កាត់វត្តភ្នំ សង្កាត់ផ្សារថ្មីទី១ សង្កាត់ផ្សារថ្មីទី២ សង្កាត់ផ្សារថ្មីទី៣ និងសង្កាត់បឹងរាំង សំណង់អគារសហកម្មសិទ្ធិមានការរីកលូតលាស់ខ្លាំងគួរឱ្យ

[25] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា ទំព័រទី៦៦ ដល់ទី៦៨

[26] គោលនយោបាយជាតិ ស្តីពី លំនៅដ្ឋាន ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ យកចេញពីចំណុចទី៥ ផែនការសកម្មភាព

កត់សម្គាល់ ពីព្រោះទីតាំងតំបន់ខាងលើនេះ មានលក្ខណៈអំណោយផលដល់ការប្រកបអាជីវកម្ម និងជាទីតាំងនៃ មជ្ឈមណ្ឌលពាណិជ្ជកម្មចម្រុះ សំបូរទៅដោយសំណង់អគារការិយាល័យធ្វើការឯកជន បន្ទប់អគារសម្រាប់ជួលស្នាក់នៅរយៈពេលខ្លី និងរយៈពេលវែង អគារពាណិជ្ជកម្មផងដែរ។ ដោយឡែកនៅក្នុង សង្កាត់ផ្សារចាស់ សង្កាត់ផ្សារកណ្ដាលទី១ សង្កាត់ផ្សារកណ្ដាលទី២ សង្កាត់ជ័យជំនះ និងសង្កាត់ចតុមុខ សង្កេតឃើញថាមិនសូវមានសាងសង់សំណង់អគារសហកម្មសិទ្ធិនោះទេ ពីព្រោះទីតាំងតំបន់ខាងលើនេះ មានលក្ខណៈមិនអំណោយផលខ្លាំងចំពោះអគារធំៗ ដោយហេតុថាតំបន់នេះសំបូរទៅដោយវប្បធម៌ចម្រុះ និងនៅក្បែរដងទន្លេ ហើយជាពិសេស នៅក្បែរព្រះបរមរាជវាំង។ បន្ថែមពីនេះ ក្នុងតំបន់សង្កាត់ទាំង ៥ ខាងលើ ភាគច្រើនសំបូរដោយសំណង់អគាររតនភណ្ឌចាស់ៗ កាលណាបើគេសាងសង់អគារធំៗនោះ អាចនឹងបណ្ដាលឱ្យបាត់បង់ ជំនោរខ្យល់បក់ពីទន្លេសាបចូលមកក្នុងទីក្រុង ជាពិសេសទីតាំងក្បែរព្រះបរមរាជវាំង គេមិនអនុញ្ញាតឱ្យសាងសង់អគារខ្ពស់នោះទេ។ ពីព្រោះស្ថិតនៅក្នុងតំបន់ដែល ប្លង់គោលអភិវឌ្ឍន៍រាជធានីហាមឃាត់ និងវាអាចប៉ះពាល់ដល់សោភ័ណភាពនៃព្រះបរមរាជវាំងផងដែរ។

### ១.២.១.៣. សំណង់អគារផ្សេងៗ

បន្ថែមពីប្រភេទសំណង់ដែលបានរៀបរាប់ខាងលើ ខណ្ឌដូនពេញបច្ចុប្បន្នក៏មាននូវប្រភេទសំណង់ផ្សេងៗទៀតជាច្រើន។ ដែលសំណង់អស់ទាំងនោះមានដូចជា គ្រឹះស្ថានសិក្សា មន្ទីរពេទ្យដែលបម្រើទាំងគ្រប់វិស័យ រួមមាន ស្ថាប័នរដ្ឋ និងឯកជន ស្ថានទូត ផ្សារប្រភេទប្រពៃណី ផ្សារទំនើប សណ្ឋាគារ វត្តអារាម សំណង់រតនភណ្ឌផ្សេងៗដទៃទៀត ក៏មានជាច្រើនគួរឱ្យកត់សម្គាល់។

ចំពោះគ្រឹះស្ថានសិក្សាទាំងរដ្ឋ និងឯកជនមានដូចជាៈ

- **គ្រឹះស្ថានសិក្សារដ្ឋៈ** សាលាបឋមសិក្សាដូនពេញ, សាលាបឋមសិក្សា និងអនុវិទ្យាល័យចតុមុខ, សាលាបឋមសិក្សាព្រះនរោត្តម, សាលាបឋមសិក្សាកុលាបទី១, អនុវិទ្យាល័យ និងវិទ្យាល័យ ហ៊ុន សែន ប៊ុន រ៉ានី វត្តភ្នំ, អនុវិទ្យាល័យ និងវិទ្យាល័យវត្តកោះ, អនុវិទ្យាល័យ និងវិទ្យាល័យព្រះស៊ីសុវត្ថិ, សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យអនុវត្ត, វិទ្យាស្ថានជាតិប៉ាស្ទ័រ, សាកលវិទ្យាល័យជាតិគ្រប់គ្រង, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, វិទ្យាស្ថានជាតិអប់រំ, ពុទ្ធិកៈសាកលវិទ្យាល័យព្រះសីហនុរាជ, សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។
- **គ្រឹះស្ថានសិក្សាឯកជនៈ** វិទ្យាស្ថាន អ៊ី.អិល.ធី, សាលារៀនសុវណ្ណភូមិ, មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការបណ្ដុះបណ្ដាល(ACE), សាលាអន្តរជាតិ អាយ.ស៊ី.អេស, សាលាអន្តរជាតិ ផ្លេនីត, សាលាអន្តរជាតិ ហ្សរ៉េសហៀល, សាលារៀនវ៉េស្ទឡាញន៍,

សាលា ហ្វ៊តព្រីន អន្តរជាតិ, American Pacific International School, Institut Francais du Cambodge, CamEd Business School, សាកលវិទ្យាល័យបញ្ញាសាស្ត្រអន្តរជាតិ។

ចំណែកឯមន្ទីរពេទ្យរដ្ឋ និងឯកជនមានដូចជា៖

- **មន្ទីរពេទ្យរដ្ឋ៖** មន្ទីរពេទ្យកាល់ម៉ែត, មន្ទីរពេទ្យព្រះកេតុមាលា, មន្ទីរពេទ្យព្រះអង្គឌួង, មជ្ឈមណ្ឌលជាតិ គាំពារមាតា និងទារក(មន្ទីរពេទ្យជប៉ុន), មជ្ឈមណ្ឌលជាតិផ្តល់ឈាម, មណ្ឌលសុខភាពដូនពេញ។
- **មន្ទីរពេទ្យឯកជន៖** មន្ទីរពេទ្យសង់ត្រាល់, មន្ទីរព្យាបាលធ្មេញរំចង់, មន្ទីរព្យាបាលធ្មេញឈួន ម៉េង, មន្ទីរពេទ្យរ៉ាហ្វេលមេឌីល, មន្ទីរពេទ្យសូរិយា, មន្ទីរពេទ្យគន្ធបុប្ផាទី១ និងទី២, មន្ទីរពហុព្យាបាលឡាសង់តេ។

រីឯស្ថាប័នរដ្ឋ និងឯកជនមានដូចជា៖

- **ស្ថាប័នរដ្ឋ៖** សាលារាជធានីភ្នំពេញ, សាលាខណ្ឌដូនពេញ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងព័ត៌មាន, ក្រសួងយុត្តិធម៌, ក្រសួងធនធានទឹក, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងរ៉ែ និងថាមពល, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធម្មការ និងសាសនា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អង្គភាពប្រឆាំងអំពើពុករលួយ, សាខាពន្ធដាខណ្ឌដូនពេញ, ក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិកម្ពុជា, អគ្គិសនីកម្ពុជា, រដ្ឋាករទឹកស្វយ័តភ្នំពេញ, តុលាការកំពូល, សាលាឧទ្ធរណ៍។
- **ស្ថាប័នឯកជន៖** ធនាគារ អេ.ស៊ី.លី.ដា, ភីអិលស៊ី, ក្រុមហ៊ុនជាតិធានារ៉ាប់រងកាមិនកូ, អាគារ OCIC (វិមានកាណាឌីយ៉ា), ធនាគារវឌ្ឍនៈ, ប្រៃសណីយ៍កម្ពុជា។ល។

សំណង់វត្តអារាមមានដូចជា៖

- **វត្តអារាម៖** វត្តពិភទ្ធរង្សី (វត្តចិនដំដែក), វត្តព្រះពុទ្ធឃោសាចារ្យ, វត្តបុទុមវត្តី, វត្តកោះ, វត្តសារាវ័ន្តតេជោ, វត្តស្រះចក, វត្តភ្នំ, វត្តឧណ្ណាលោម។

ស្ថានទូតក្នុងខណ្ឌដូនពេញមានដូចជា៖

- **ស្ថានទូត៖** ស្ថានទូតសឹង្ហបុរី, ស្ថានទូតបារាំង, ស្ថានទូតអង់គ្លេស, ស្ថានទូតអាមេរិក, ស្ថានទូតកូរ៉េខាងជើង, ស្ថានទូតឥណ្ឌា។

សណ្ឋាគារប្រណិតៗនៅក្នុងខណ្ឌដូនពេញមានដូចជា៖

- **សណ្ឋាគារ៖** សណ្ឋាគារភ្នំពេញ, Raffles Hotel Le Royal (Le Phnom) , Rosewood Phnom Penh, Sunway Hotel Phnom Penh, Palace Gate Hotel & Resort, Hotel Cambodiana, Lumiere Hotel, Himawari។

ចំពោះផ្សារដែលមានទីតាំងនៅក្នុងខណ្ឌដូនពេញមានដូចជា៖

- **ផ្សារប្រភេទប្រពៃណី៖** ផ្សារធំថ្មី, ផ្សារចាស់, ផ្សារកណ្តាល, ផ្សារស៊ីលិប, ផ្សារតាប៉ាង, ផ្សាររាត្រី។
- **ផ្សារទំនើប៖** ផ្សារទំនើបសូរិយា, ផ្សារទំនើបអ៊ិចឆេងស្វ៊ែរ(Exchange Square), ផ្សារទំនើបផេនសុល។

បន្ថែមពីនេះចំពោះសំណង់រតនភណ្ឌមានដូចជា៖

- **សំណង់រតនភណ្ឌ៖** ព្រះបរមរាជវាំង, វត្តភ្នំ, ស្ថានីយរាជាយស្ម័យយាន, សាលារាជធានីភ្នំពេញ, រតនាគារជាតិ, ការិយាល័យអង្គការយូណេស្កូ, សណ្ឋាគារឡឺរ៉ូយ៉ាល់, បណ្ណាល័យជាតិ, ក្រសួងយុត្តិធម៌, ក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិកម្ពុជា, តុលាកាកំពូល, វិមានឯករាជ្យ, សារមន្ទីរជាតិ, អតីតក្រសួងប្រៃសណីយ៍ សព្វថ្ងៃជាគ្រឹះស្ថានប្រៃសណីយ៍កម្ពុជា, សួនច្បារវិមានឯករាជ្យ, សួនច្បារមុខព្រះបរមរាជវាំង, ព្រះអង្គដងកើ, សួនច្បារវត្តបុទុមវត្តី, វាលព្រះមេរុ, សាលសន្និសីទចតុមុខ។

### ១.២.២. ការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌដូនពេញ

ក្នុងពេលបច្ចុប្បន្ននេះ ខណ្ឌដូនពេញ មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ដែលមានដូចជា ការកសាងប្រព័ន្ធគមនាគមន៍ផ្លូវថ្នល់ ប្រព័ន្ធបង្ហូរលូទឹកកខ្វក់ ដែលបង្កឱ្យមានលក្ខណ:ងាយស្រួលដល់ប្រជាពលរដ្ឋរស់នៅប្រចាំថ្ងៃ។ ការកសាងទាំងអស់នេះ គឺសុទ្ធតែមានសារ:សំខាន់ទាំងអស់ដែលផ្តល់ឱ្យ ខណ្ឌដូនពេញ មានសោភ័ណភាព និងកាត់បន្ថយការកកស្ទះចរាចរណ៍ និងកាត់បន្ថយការកកស្ទះលូផ្សេងៗ។

#### ១.២.២.១. ការអភិវឌ្ឍន៍ផ្នែកគមនាគមន៍ផ្លូវថ្នល់

ចំពោះការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ផ្លូវថ្នល់ នៅក្នុងខណ្ឌដូនពេញ មានវិថីតូច.ធំជាច្រើន ដែលបានស្ថាបនាឡើងជាប្រភេទ ផ្លូវកៅស៊ូ AC ផ្លូវកៅស៊ូ DBST និងផ្លូវបេតុងមានប្រវែងសរុប ៤៣,៨១០ ម៉ែត្រ។ ក្នុងនោះដែរមានមហាវិថីធំៗចំនួនបី តិរវិថីចំនួនមួយ និងវិថីចំនួនមួយគឺមហាវិថីព្រះនរោត្តម, មហាវិថីព្រះមុន្នីវង្ស, មហាវិថីព្រះសីហនុ, តិរវិថីព្រះស៊ីសុវត្ថិ និងវិថីសុធារស។ នៅក្នុងពេលបច្ចុប្បន្ននេះខណ្ឌដូនពេញ មានផ្លូវអ៊ុតកៅស៊ូ AC ប្រវែង ២៩,៨០០ ម៉ែត្រ

ផ្លូវអ៊ុតកៅស៊ូ DBST ប្រវែង ១២,៧៣០ ម៉ែត្រ និងផ្លូវបេតុង ប្រវែង ១,៦៤៩ ម៉ែត្រ សាងសង់ឡើង ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងមានថវិកាបដិភាគមួយចំនួនពីប្រជាពលរដ្ឋនៅក្នុង មូលដ្ឋានផងដែរ។[27]

ជាមួយគ្នានេះដែរ រាល់ការសាងសង់នៅលើដីសម្រាប់អភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាពិសេសនៅលើដីចំណីផ្លូវជាលក្ខណៈអចិន្ត្រៃយ៍ត្រូវបានហាមឃាត់។[28] ការប្រើប្រាស់ដីចំណីផ្លូវ គឺ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដូចនេះត្រូវហាមឃាត់ចំពោះ ការធ្វើរបងនៅលើចំណីផ្លូវ ការសាងសង់លំនៅដ្ឋាននៅលើចំណីផ្លូវ និងហាមមិនឱ្យមានការជីករាំង តាមប្រឡាយលូ នានាដែលបណ្តាលឱ្យរាំងស្ទះចរន្តទឹក។ បន្ថែមពីនេះ ចំពោះចំណីផ្លូវ គឺអាចយក ទៅប្រើប្រាស់សម្រាប់បម្រើសកម្មភាពក្នុងគោលបំណងចំនួន បួន មានដូចជា៖

- ទី១៖ បម្រើដល់ការធ្វើចរាចរណ៍ដោយថ្មើរជើង។
- ទី២៖ បម្រើសកម្មភាព ដូចជា សកម្មភាពវប្បធម៌ កីឡា ការតាំងពិព័រណ៍ និងពិធីបុណ្យ ផ្សេងទៀត នៅលើដងផ្លូវ ប៉ុន្តែត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ទៅតាម កម្រិតនៃពិធី និងតាមភាពចាំបាច់។
- ទី៣៖ បម្រើសកម្មភាពជីកកប់បណ្តាញក្រោមដី ដូចជា បណ្តាញទឹកស្អាត ប្រព័ន្ធលូ ខ្សែ បញ្ជូនអគ្គិសនី បំពុងទុយោ ខ្សែកាបអុបទិចគ្រប់ប្រភេទ និងបរិក្ខារក្រោមដីផ្សេងៗ ទៀត។
- ទី៤៖ បម្រើសកម្មភាពសាងសង់ ក្នុងគម្រោងចាំបាច់មួយចំនួន ដូចជា បរិក្ខារបម្រើឱ្យ វិស័យការពារជាតិ សន្តិសុខជាតិ បរិក្ខារបម្រើឱ្យការគ្រប់គ្រង ឬការសាងសង់ផ្លូវ និង បរិក្ខារសំណង់សេវាសាធារណៈផ្សេងៗទៀត តាមការចាំបាច់។[29]

ចំណែកឯ ការប្រើប្រាស់ចំណីផ្លូវជាទីតាំងផ្ញើកង់ម៉ូតូ មិនត្រូវឱ្យលើសពី ១/៣ (មួយភាគបី) នៃ ចំណីផ្លូវឡើយ។ ចំពោះការធ្វើរោងបុណ្យ រោងអាពាហ៍ពិពាហ៍ និងរោងកម្មវិធីផ្សេងៗ ដោយគិត ចាប់ ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ តទៅ រដ្ឋបាលរាជធានីភ្នំពេញ តម្រូវឱ្យប្រជាពលរដ្ឋដែលរស់នៅ ក្នុងខណ្ឌទាំង១៤ ត្រូវរកទីតាំងឯកជន វត្តអារាម-ព្រះវិហារ ឬទីតាំងសមស្របណាមួយជំនួសការប្រើ

[27] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់នៅ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៩

[28] ច្បាប់ស្តីពីផ្លូវថ្នល់, លេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៣, មាត្រា១២

[29] សេចក្តីណែនាំ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុង ភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ ០១៣/១៨ សណន ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៨, ទំព័រទី១

ប្រាស់ចំណីផ្លូវ ឬផ្លូវ ហើយការធ្វើរោងបុណ្យ រោងអាពាហ៍ពិពាហ៍ និងរោងកម្មវិធីផ្សេងជាលក្ខណៈឯកជន នៅលើចំណីផ្លូវ ឬនៅលើផ្លូវក្នុងរាជធានីភ្នំពេញ គឺមិនអនុញ្ញាតឡើយ។[30]

ក្នុងពេលថ្មីៗនេះ ដើម្បីរក្សាបាននូវសោភ័ណភាពសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ រដ្ឋបាលខណ្ឌដូនពេញ បានចេញសេចក្តីជូនដំណឹងដល់ម្ចាស់អាជីវកម្ម ស្ថាប័នរដ្ឋ ឯកជន នៅតាម បណ្តោយមហាវិថីព្រះនរោត្តម ដែលបានកំពុងចតរថយន្ត ម៉ូតូ នៅលើចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង រដ្ឋបាលខណ្ឌដូនពេញ សម្រេចដាក់ចេញជាគោលការណ៍ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានការចតរថយន្ត ម៉ូតូ គ្រប់ប្រភេទនៅលើចិញ្ចើមផ្លូវសាធារណៈ និងផ្លូវសម្រាប់អ្នកថ្មើរជើង (ដែលចំណែកគំនូសពណ៌លឿងមកដល់ ជញ្ជាំងផ្ទះប្រជាពលរដ្ឋ ឬរបងស្ថាប័នរដ្ឋ ឯកជន គឺទុកសម្រាប់ជនពិការ ក៏ដូចជារទេះជនពិការធ្វើដំណើរឆ្លងកាត់ និងមួយផ្នែកទៀតពីគំនូសពណ៌លឿងមកដល់ចិញ្ចើមផ្លូវត្រូវរក្សាទុក សម្រាប់ប្រជាពលរដ្ឋ ធ្វើដំណើរឆ្លងកាត់)។

២. នៅខាងមុខទីតាំងអាជីវកម្មរបស់ខ្លួន ត្រូវមានចំណតផ្ទាល់ខ្លួន ដែលមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈឡើយ។

៣. នៅមុខទីតាំងអាជីវកម្មរបស់ខ្លួន រួមទាំងស្ថាប័នរដ្ឋ ឯកជន ត្រូវសំអាតអនាម័យ ឱ្យបានស្អាតជានិច្ច ដើម្បីចូលរួមចំណែកការពារបរិស្ថាន សម្រាប់រាជធានីភ្នំពេញយើង។

៤. ម្ចាស់ទីតាំងស្ថាប័នរដ្ឋ ឯកជន អាចសុំចតរថយន្ត ម៉ូតូ របស់ខ្លួន តាមគំនូសទីតាំង ដែលមន្ទីរសាធារណការរាជធានីភ្នំពេញបានកំណត់។

៥. ក្នុងករណី លោក-លោកស្រី នៅតែមិនអនុវត្តតាមសេចក្តីជូនដំណឹង ក៏ដូចជាការណែនាំរបស់រដ្ឋបាលខណ្ឌដូនពេញទេ នោះរដ្ឋបាលខណ្ឌនឹងចាត់វិធានការ រដ្ឋបាលដោយ ស្ទូចយករថយន្ត ម៉ូតូ មករក្សាទុក នៅរដ្ឋបាលខណ្ឌរយៈពេល ១៥ថ្ងៃ ទើបដោះស្រាយជូន។[31]

លើសពីនេះ នៅតាមបណ្តោយមហាវិថីធំៗចំនួន ពីរគឺ មហាវិថីព្រះមុន្នីវង្ស និងមហាវិថីព្រះសីហនុ គឺមានដាក់នូវរបាំងបែងចែកទ្រូងផ្លូវដែលជាយុទ្ធសាស្ត្រមួយ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ និងបានចូលរួមចំណែកក្នុងការកាត់បន្ថយនូវគ្រោះថ្នាក់ចរាចរណ៍ផងដែរ។ តាមការសង្កេតមើលពីប្រសិទ្ធភាពនៃរបាំងពុះចែកទ្រូងផ្លូវនេះ ក៏ឃើញថាទទួលបានប្រសិទ្ធភាពខ្ពស់ ដោយបញ្ហាកកស្ទះចរាចរណ៍ត្រូវបានកាត់បន្ថយជាលំដាប់។

[30] សេចក្តីណែនាំ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ ០១៣/១៨ សណន ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៨, ទំព័រទី៣

[31] សេចក្តីជូនដំណឹង ស្តីពី ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈតាមបណ្តោយមហាវិថីព្រះនរោត្តម, លេខ ២២០/១៩ សជណ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៩

ក្រៅពីការអភិវឌ្ឍន៍ ទៅលើគំរោងធំៗ ការអភិវឌ្ឍន៍នៅលើចំណុចតូចៗ ក៏មានច្រើនគួរឱ្យកត់សម្គាល់ផងដែរ។ ដូចជា ផ្លូវថ្នល់ដែលខូចខាតត្រូវបានជួសជុលកែលម្អដោយការចាក់បំពេញ និងអ៊ុតឡើងវិញជៀសវាងការស្រុតខូចជាដើម។

### ១.២.២.២. ប្រព័ន្ធលូបង្ហូរទឹកកខ្វក់

បន្ថែមពីការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ផ្លូវថ្នល់ នៅក្នុងខណ្ឌដូនពេញ បានរៀបចំប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ដើម្បីកាត់បន្ថយការកកស្ទះលូដែលអាចបណ្តាលឱ្យជន់លិចផ្លូវ ក៏ដូចជាតំបន់មួយចំនួននៅក្នុងខណ្ឌដូនពេញ។ ដែលពីកាលពីប្រមាណឆ្នាំមុន ភាគច្រើន ជន់លិច នៅតំបន់បឹងកក់ ក្នុងសង្កាត់ស្រះចក, បរិវេណផ្សារកណ្តាល ស្ថិតនៅក្នុងសង្កាត់ ផ្សារកណ្តាលទី១ និងជន់លិច នៅតំបន់ក្រោយព្រះបរមរាជវាំង ដែលស្ថិតនៅក្នុងសង្កាត់ចតុមុខ។ ប៉ុន្តែមកដល់ពេលបច្ចុប្បន្ននេះ តំបន់ដែលធ្លាប់ជន់លិចខ្លាំងនោះត្រូវបាន ស្តារឡើងវិញ ដោយមានការរៀបចំប្រព័ន្ធលូ និងបានដាក់បំពុងលូទំហំធំជាង បំពុងលូចាស់ ដែលអាចរំដោះទឹកដែលជន់លិចបានក្នុងរយៈពេលខ្លី។

នៅក្នុងពេលថ្មីៗនេះ ដើម្បីធ្វើការរំដោះទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូក្នុង រាជធានីភ្នំពេញ ក៏ដូចជាខណ្ឌដូនពេញ រដ្ឋាភិបាល ជប៉ុន បានសម្រេចផ្តល់ជំនួយឥតសំណង ជំហានទី៤ ដល់សាលារាជធានីភ្នំពេញ ដែលមានទំហំទឹកប្រាក់ចំនួនប្រមាណ ៣០លានដុល្លា។ ដែលគម្រោងហិរញ្ញប្បទានរបស់ប្រទេសជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ចាប់ផ្តើមនៅខែ មករា ឆ្នាំ ២០១៩ ហើយគម្រោងនឹងបញ្ចប់នៅខែ តុលា ឆ្នាំ ២០២១។ គម្រោងនេះមានចំណុចសំខាន់ៗដូចជា មានការដាក់បណ្តាញលូមេ, ការសាងសង់អាងស្តុកទឹកក្រោមដី, សាងសង់ស្ថានីយ៍បូមទឹក, ការតម្លើងរបាមេកានិចស្វ័យប្រវត្តិ ដើម្បីប្រមូលសំរាមនៅមុខផ្លូវបង្ហូរទឹក នៃស្ថានីយ៍បូមទឹកជាដើម។ ចំពោះការអនុវត្តន៍ការដ្ឋាននៃគម្រោងនេះ មានដូចខាងក្រោម៖

១. ដាក់បណ្តាញលូមេ នៅក្នុងភូមិសាស្ត្រខណ្ឌទួលគោក ប្រវែង ៨.២ គីឡូម៉ែត្រ

២. ដាក់បណ្តាញលូមេ នៅក្នុងភូមិសាស្ត្រខណ្ឌដូនពេញ ប្រវែង ៤.៤ គីឡូម៉ែត្រ

៣. សាងសង់អាងស្តុកទឹកក្រោមដី និងសាងសង់ស្ថានីយ៍បូមទឹក នៅសួនច្បារមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ។

៤. តម្លើងរបាមេកានិចស្វ័យប្រវត្តិ ដើម្បីប្រមូលសំរាមនៅមុខផ្លូវបង្ហូរទឹកនៅស្ថានីយ៍បូមទឹកចតុមុខ, ព្រះគន្លង់១, ព្រះគន្លង់២ និងផ្សារចាស់។

៥. ផ្តល់រថយន្តបូមទឹកចល័ត ចំនួន ២គ្រឿង។[32]

[32] គេហទំព័រនៃក្រសួងសាធារណការ និងដឹកជញ្ជូន http://www.mpwt.gov.kh/kh/post/5863 ដកស្រង់នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៩

បន្ថែមពីនេះ ពាក់ព័ន្ធនឹងគម្រោងខាងលើ អ្នកនាំពាក្យរដ្ឋបាលរាជធានីភ្នំពេញបានបង្ហាញឱ្យដឹងដែរថា គម្រោងជំហានទី៤ នៃការការពារទឹកជំនន់ និងការកែលម្អប្រព័ន្ធប្រឡាយលូនេះបានផ្តោតទៅលើការងារសំខាន់ៗ មួយចំនួនដូចជា ការងាររំដោះទឹក ដែលការងាររំដោះទឹកនេះមានគោលបំណងធំ រៀបចំផ្នែកខាងជើងវត្តភ្នំ នៅក្នុងតំបន់ផ្លូវលេខ ៤៧ ដោយចាប់ពីវត្តភ្នំរហូតទៅដល់រង្វង់មូលគួចកាណុង មានផ្ទៃដីប្រមាណជា ៧០ ហិកតា ដែលនឹងត្រូវរៀបចំ គិតគូរឱ្យមានស្ថានីយ៍បូមទឹកមួយកន្លែង ជាស្ថានីយ៍ទី៥ ស្របតាមដងទន្លេ មានទីតាំងនៅទល់មុខសួនច្បារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ ស្ថានីយ៍បូមទឹកនេះ មានអាងស្តុកទឹកក្រោមដីដែលមានសមត្ថភាពអាចស្តុកទឹកបានប្រមាណ ៦.០០០ ម៉ែត្រគូប មុននឹងធ្វើការទម្លាក់ពីអាងស្តុក ចូលទៅទន្លេ។ ជាមួយគ្នានេះ នឹងមានការតម្លើងជាម៉ាស៊ីនចាប់យកសំរាមដោយស្វ័យប្រវត្តិ ដែលកិច្ចការនេះជាចំណែកមួយនៃគម្រោងជំហានទី៤ ហើយគម្រោងនេះ នឹងយកទៅបំពាក់នៅគ្រប់ស្ថានីយ៍ទាំង៤ ដែលនៅជាប់ដងទន្លេ គឺស្ថានីយ៍បូមទឹកផ្សារចាស់ ស្ថានីយ៍បូមទឹកព្រះគន្លង់ ស្ថានីយ៍បូមទឹកផ្សារកណ្តាល និងស្ថានីយ៍បូមទឹកចតុមុខ។ ក្នុងគម្រោងនឹងមានការរៀបចំដាក់ប្រព័ន្ធបណ្តាញលូ ក្នុងទំហំ ចន្លោះ ២ ម៉ែត្រ ទៅ ២,៥០ ម៉ែត្រផងដែរ។[33]

---

[33] គេហទំព័រ http://www.phnompenhreporter.com/article/46828 ដកស្រង់នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៩

# ជំពូកទី២
# សោភ័ណភាព និងបរិស្ថាន
# ក្នុងខណ្ឌដូនពេញ

# ជំពូកទី២
# ការរៀបចំសោភ័ណភាព និងបរិស្ថានក្នុងខណ្ឌដូនពេញ

## ២.១ សោភ័ណ្ឌភាពក្នុងខណ្ឌដូនពេញ

ខណ្ឌដូនពេញ មានទីតាំងស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញតែម្តង។ ខណ្ឌដូនពេញត្រូវបានគេចាត់ថ្នាក់ថាជាខណ្ឌមួយដែលពោរពេញទៅដោយតំបន់រដ្ឋបាល តំបន់ពាណិជ្ជកម្ម សំណង់បេតិកភណ្ឌ វប្បធម៌ចម្រុះ និងភាពសម្បូរបែបផ្សេងៗគ្នា ក្នុងនោះដែរវាក៏មានសំណង់ស្នាដៃទំនើបៗមានដូចជា ភោជនីយដ្ឋាន បារ សណ្ឋាគារ អគារពាណិជ្ជកម្ម ខុនដូ និងកន្លែងផ្សេងៗទៀតជាច្រើនដែលវាជាកន្លែងដ៏មានសកម្មភាពខ្លាំងក្លាមួយ។ ជាងនេះទៅទៀតខណ្ឌដូនពេញស្ថិតនៅជាប់តំបន់ដងទន្លេដែលអាចមើលឃើញទេសភាពដ៏ស្រស់ត្រកាល នៃដងទន្លេសាប និងជ្រោយខាងកើតនៃដងទន្លេដែលជាកន្លែងគួរជាទីគយគន់ ដែលធ្វើឱ្យជីវិតរស់នៅរបស់ប្រជាជននៅតាមបណ្តោយដងទន្លេមានភាពរីករាយស្រស់ស្រាយ។[34] នៅតាមមាត់ទន្លេក៏មានផ្សារ ភោជនីយដ្ឋាន និងកន្លែងកំសាន្តផ្សេងៗ ជាច្រើនទៀតផងដែរ។ ទាក់ទងទៅនឹងទេសចរណ៍វិញតំបន់ដងទន្លេ និងតំបន់បេតិកភណ្ឌដែលស្ថិតក្នុងខណ្ឌដូនពេញ គឺជាទិសដៅលេខ១ សម្រាប់ភ្ញៀវទេសចរណ៍ដែលចូលមកលេងកំសាន្តក្នុងរាជធានីភ្នំពេញ ហើយក៏ជាកន្លែងកម្សាន្តដ៏ធំរបស់ប្រទេសកម្ពុជា។

ជាងនេះទៅទៀត ខណ្ឌដូនពេញមានកន្លែងជាច្រើនសម្រាប់ដើរកម្សាន្តដូចជា ផ្សារធំថ្មី គឺជាផ្សារបេតិកភណ្ឌដែលមានអាយុកាលចំណាស់ជាងគេ ក្នុងនោះមានលក់វត្ថុអនុស្សាវរីយ៍ ផលិតផលសិប្បកម្ម សម្លៀកបំពាក់ គ្រឿងអលង្ការ និងសម្ភារៈដទៃទៀតយ៉ាងសម្បូរបែប។ ផ្សារទំនើបសូរិយាគឺជាផ្សារទំនើបដំបូងគេបង្អស់ដែលមានវត្តមាននៅរាជធានីភ្នំពេញ ដែលទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកចូលមើលកម្សាន្ត ដែលមានទីតាំងក្បែរនឹងផ្សារធំថ្មី។ សារមន្ទីរជាតិដែលជាកន្លែងសម្រាប់ភ្ញៀវទេសចរណ៍ចូលមកទស្សនាស្វែងយល់ពីវប្បធម៌ អរិយធម៌ និងទំនៀមទម្លាប់ដែលបុព្វបុរសបានបន្សល់ទុកមកតាំងពីយូរលង់ណាស់មកហើយ។ ព្រះបរមរាជវាំង ដែលជាកន្លែងដ៏សំខាន់ជាងគេមួយនៅក្នុងរាជធានីភ្នំពេញដែលភ្ញៀវទេសចរណ៍គ្រប់រូបមិនអាចរំលងបាន ក្នុងនេះដែរបង្ហាញឱ្យឃើញពីប្រវត្តិសាស្ត្រកម្ពុជាពី មួយសម័យកាល ទៅមួយសម័យកាល ឱ្យយល់ដឹងអំពីរបៀបរបបរស់នៅរបស់ក្សត្រ និងរចនាបថខ្មែរដែលមានបន្សល់ទុកក្នុងព្រះបរមរាជវាំង។ ហើយវត្តឧណ្ណាលោមជាអារាមមួយដែលមានអាយុកាលយូរជាងគេក្នុងតំបន់ខណ្ឌដូនពេញ ក្នុងអារាមនេះភ្ញៀវទេសចណ៍អាចចូលទស្សនាបាននូវព្រះវិហារ រូបបដិមា ជំនឿសាសនា របៀបក្នុងការប្រតិបត្តិខ្លួនក្នុងព្រះពុទ្ធ

---

[34] គេហទំព័រ https://www.realestate.com.kh/km/news/daun-penh-district-phnom-penh/ ដកស្រង់នៅ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៩

សាសនា ក៏ដូចជាបានឃើញពីសំណង់បុរាណចាស់ៗដែលបានបន្សល់ទុកមកជាយូរលង់ណាស់មកហើយ។ រមណីយដ្ឋានវត្តភ្នំ ដែលជាកន្លែងប្រវត្តិសាស្ត្រតំណាងឱ្យរាជធានីភ្នំពេញទាំងមូល ព្រមទាំងសួនច្បារកន្លែងកម្សាន្ត តំបន់ពាណិជ្ជកម្ម សំណង់ផ្ទះ និងអគារចាស់ៗដែលសល់ពីសម័យអាណានិគមនិយមបារាំង សំណង់អគារសង់ថ្មីយ៉ាងស្កឹមស្កៃ ផ្សារទំនើបអន្តរជាតិ។ល។

### ២.១.១. សោភ័ណភាពពេលថ្ងៃ

ដោយយោងទៅតាមសៀវភៅ នីតិនគរូបនីយវិទ្យា និងសំណង់របស់ " លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា " បានឱ្យនិយមន័យសោភ័ណភាពពេលថ្ងៃថា គឺសំដៅទៅដល់សំណង់អគារលំនៅដ្ឋាន ស្ពានអាកាស ផ្លូវថ្នល់ ផ្ទះល្វែង បុរី ស្ពានក្រោមដី ប្រព័ន្ធលូ សួនច្បារ បង្គោលភ្លើង ស្លាកសញ្ញាចរាចរណ៍ យានជំនិះគ្រប់ប្រភេទ សរុបមកគឺអ្វីៗដែលកើតមានឡើងនៅលើដី។[35] ប្រសិនបើក្រឡេកមកមើលទិដ្ឋភាពក្នុងខណ្ឌដូនពេញនេះវិញ សង្កេតឃើញថានៅតាមដងផ្លូវមានដាំដើមឈើស្រស់បំព្រងគួរជាទីចាប់អារម្មណ៍ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក៏រៀបចំបានយ៉ាងល្អម៉ត់ចត់ ដោយរៀបចំឱ្យមានភ្លើងសញ្ញា ស្លាកសញ្ញា គំនូសសញ្ញាចរាចរណ៍ បង្គោលភ្លើងបំភ្លឺផ្លូវ កាម៉េរាសុវត្ថិភាពតាមដងផ្លូវ ការរៀបចំដាក់ឱ្យមានលូទំហំធំក៏ដូចជាប្រព័ន្ធបង្ហូរទឹកឱ្យបានឆាប់រហ័ស ចៀសវាងមានការជន់លិចផ្លូវរយៈពេលយូរដែលបង្កការរំខាន់ដល់ដល់ធ្វើដំណើរ។ ហើយមានការរៀបចំសួនច្បារបានយ៉ាងស្រស់ស្អាត និងបង្កភាពងាយស្រួលដល់ប្រជាជនអាចដើរកំសាន្ត និងហាត់ប្រាណបានយ៉ាងសប្បាយរីករាយក្រោយបញ្ចប់ការងារអស់រយៈពេលពេញមួយថ្ងៃ។

ពិសេសជាងនេះទៅទៀត ហេដ្ឋារចនាសម្ព័ន្ធខណ្ឌដូនពេញបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សោភ័ណភាពក្នុងខណ្ឌឱ្យកាន់តែមានភាពទាក់ទាញ និងដើម្បីប្រកួតប្រជែង ជាមួយនឹងខណ្ឌដទៃទៀត។ បើងាកមកមើលអំពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធ គឺអភិបាលនៃគណៈអភិបាលត្រូវតែត្រួតពិនិត្យមើលចំពោះការកសាងសំណង់នានាដូចជាៈ សហគ្រាស ស្ថានីយប្រេងឥន្ធនៈ ឃ្លាំងទំនិញ សំណង់លំនៅដ្ឋាន អគារពាណិជ្ជកម្ម ផ្ទះល្វែង មន្ទីរពេទ្យ សាលារៀនជាដើម ដោយត្រូវតែគោរពតាមស្តង់ដារ និងបទដ្ឋានដែលច្បាប់បានកំណត់។ ចំពោះការរៀបចំចរាចរណ៍ឱ្យមានសោភ័ណភាព ពិតណាស់គឺត្រូវមានការចូលរួមចំណែកពីសំណាក់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ និងកត្តាមួយចំនួនផ្សេងទៀតដូចជា៖

- **កត្តាប្រជាជន** ៖ កត្តានេះត្រូវបានសង្កេតឃើញថាមានភាគច្រើនជាងគេ ដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត និងការធ្វេសប្រហែសមិនយកចិត្តទុកដាក់នៅក្នុងការបើកបរនៅមានចំនួនច្រើន។ ដូច្នេះថ្នាក់ដឹកនាំត្រូវតែសហការជាមួយ

[35] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា ទំព័រ១

អង្គភាពពាក់ព័ន្ធនានា ដើម្បីធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលណែនាំដល់ប្រជាពលរដ្ឋ នៅក្នុងតំបន់ឱ្យយល់ដឹងអំពីច្បាប់ចរាចរណ៍ និងមានសីលធម៌ខ្ពស់ក្នុងការបើកបរ ដើម្បីកាត់បន្ថយបញ្ហាគ្រោះថ្នាក់ចរាចរណ៍ និងធ្វើឱ្យមានសណ្តាប់ធ្នាប់សោភ័ណភាពល្អ ។

- **កត្តាផ្លូវ** ៖ ផ្លូវគឺជាផ្នែកមួយដែលចូលរួមចំណែកក្នុងការធ្វើឱ្យមានសោភ័ណភាពផងដែរ។ ការបែងចែកផ្លូវឱ្យមានជាចំណីផ្លូវសម្រាប់ថ្មើជើងផ្សេង សម្រាប់យានយន្តផ្សេង គឺជាអ្វីដែលសំខាន់ក្នុងការលើក សោភ័ណភាពក្នុងតំបន់ឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។ ថ្នាក់ដឹកនាំត្រូវធ្វើយ៉ាងណាចាត់វិធានការ ចំពោះការដែលយកចំណីផ្លូវមកប្រកបរបរអាជីវកម្ម និងចតយានយន្តគ្រប់ប្រភេទ លើផ្លូវដែលនាំឱ្យបាត់នូវសោភ័ណភាព។
- **កត្តាយានជំនិះ** ៖ បញ្ហាយានជំនិះចាស់ៗ ឬយានជំនិះកែច្នៃគ្រប់ប្រភេទដែលចរាចរណ៍នៅលើដងផ្លូវ ជាកត្តាមួយដែលនាំឱ្យបាត់នូវសោភ័ណភាព និងអាចបង្កជាគ្រោះថ្នាក់ផ្សេងៗជាយថាហេតុទៀតផង។ ហេតុនេះថ្នាក់ដឹកនាំគួរចាត់វិធានការតឹងរ៉ឹងចំពោះបញ្ហាបច្ចេកទេសយានយន្តគ្រប់ប្រភេទ ជាពិសេសយានយន្តកែច្នៃ ។

### ២.១.២. សោភ័ណភាពពេលយប់

សោភ័ណភាពពេលថ្ងៃ គឺជាអ្វីដែលយើងមិនអាចខ្វះបាននោះទេពីព្រោះជាតម្រូវការចាំបាច់បំផុតសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ។ ការយកចិត្តទុកដាក់ អភិវឌ្ឍន៍សោភ័ណភាពពេលថ្ងៃតែមួយមុខក៏មិនអាចទាក់ទាញយកបេះដូងរបស់ប្រជាជន និងភ្ញៀវទេសចរណ៍ដែលមកដើរលេងកម្សាន្តបានដែរ។ ដូច្នេះសោភ័ណភាពពេលថ្ងៃ និងពេលយប់គឺត្រូវតែដើរទន្ទឹមគ្នាដែលមិនអាចខ្វះមួយណា បាន បើនិយាយពីសោភ័ណភាពពេលយប់វិញ គឺអាចនឹកឃើញទៅដល់ភ្លើងពណ៌ចម្រុះ ដែលភ្លឺចិញ្ចែងចិញ្ចាច ហាក់បីដូចជារស់នៅតំបន់មួយផ្សេងដែលខុសពីអ្វីដែលយើងបានឃើញនៅពេលថ្ងៃ។ នៅទីនេះ សោភ័ណភាពពេលយប់គឺ សំដៅទៅដល់ភាពដ៏ស្រស់ឆើតឆាយ នៃខណ្ឌដូនពេញ ដែលបានរៀបចំឱ្យមានការបំពាក់បង្គោលភ្លើងបំភ្លឺនៅ តាមដងវិថីនានាគ្រប់កន្លែង ការច្នៃប្រឌិតដាក់ភ្លើងពណ៌ចម្រុះនៅតាមដើមឈើដែលនៅអមសងខាងផ្លូវ។ ការដាក់ភ្លើងបំភ្លឺនៅតាមសួនច្បារកម្សាន្ត ដែលអំណោយផលដល់ប្រជាជន ដែលចង់មកលំហែកាយ ក៏ដូចជាធ្វើលំហាត់ប្រាណនៅពេលល្ងាចក្រោយពេលបំពេញការងារអស់រយៈពេលមួយថ្ងៃកន្លងទៅ។

ជាមួយគ្នានេះ ការបំពាក់ភ្លើងពណ៌នៅតាមសំណង់អគារខ្ពស់ៗ និងការបំពាក់អេក្រង់ខ្នាតយក្ស ដែលហាក់បីដូចជាសំណង់អគារទាំងនោះហោះត្រដែតនៅលើអាកាស។ នៅក្នុងខណ្ឌដូនពេញ ការដែលរៀបចំឱ្យមានការបំពាក់ភ្លើងបំភ្លឺ និងភ្លើងចម្រុះពណ៌មិនត្រឹមតែផ្តោតសំខាន់លើ

ភាពស្រស់ស្អាតនោះទេ តែផ្ទុយទៅវិញគឺចៀសវាងកើតមានករណី ចោរកម្ម ចាប់ជំរិត ការប្រព្រឹត្តិអំពើអនាចារ ក៏ដូចជាការសេពគ្រឿងញៀននៅតាមទីសាធារណៈ ដែលមិនមានការបំពាក់នូវភ្លើងបំភ្លឺឱ្យបានគ្រប់គ្រាន់ ដែលជាហេតុនាំឱ្យមានភាពអសកម្មក្នុងការខណ្ឌ។

បន្ថែមពីនេះទៅទៀត រដ្ឋបាលខណ្ឌដូនពេញ ក៏បានរៀបចំឱ្យមានភ្លើងនៅតាមផ្លូវដើរតូចៗសម្រាប់ចូលទៅក្នុង គេហដ្ឋានរបស់ប្រជាជន ដែលជាចំណុចដែលថ្នាក់ដឹកនាំបានគិតយ៉ាងម៉ត់ចត់ពីសុខសុវត្ថិភាព ទាំងផ្លូវកាយ និងផ្លូវចិត្តរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុង ខណ្ឌដូនពេញទាំងមូល ចៀសវាងពីការបង្កឱ្យមានភាពភ័យខ្លាចក្នុងការបំពេញការងារ អាជីវកម្មប្រចាំថ្ងៃ។

## ២.២. បរិស្ថានក្នុងខណ្ឌដូនពេញ

ចំពោះសោភ័ណភាព បរិស្ថាន និងអនាម័យ ជាកត្តាមួយដែលគួរទទួលបាននូវការរៀបចំ និងយកចិត្តទុកដាក់ឱ្យបានល្អប្រសើរ ដើម្បីលើកកម្ពស់ទីក្រុងស្អាត ក្នុងគោលបំណងផ្តល់ផាសុខភាពសុខុមាលភាពជូន ភ្ញៀវទេសចរណ៍ជាតិ, អន្តរជាតិ មកទស្សនា និងផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ក៏ដូចជាភ្ញៀវដែលបានចូលមកកំសាន្ត និងស្នាក់នៅផងដែរ។ នៅក្នុងពិភពលោក ទាំងប្រទេសដែលអភិវឌ្ឍន៍ និងប្រទេសដែលកំពុងនឹងអភិវឌ្ឍន៍ គឺសុទ្ធសឹងតែយកចិត្តទុកដាក់ លើកកម្ពស់សោភ័ណភាព អ្វីដែលជាពិសេសជាងនេះទៅទៀតគឺ អនាម័យល្អ និងបរិស្ថានល្អក្នុងទីក្រុងដោយមិនមានការរំខានពីបញ្ហានានា ក៏ដូចជាការបំពុលផ្សេងៗដែលកើតមានឡើងពីធម្មជាតិ និងមនុស្ស។ យ៉ាងណាមិញខណ្ឌដូនពេញក៏បានផ្តោតសំខាន់លើការយកចិត្តទុកដាក់ទៅលើបញ្ហា សោភ័ណភាព បរិស្ថាន និងអនាម័យឱ្យកាន់តែល្អប្រសើរជាងមុនតាមរយៈផែនការអនុវត្តន៍ និងការដាក់ចេញនូវផែនការណ៍ផ្សេងៗដើម្បីកែលម្អ សោភ័ណភាព បរិស្ថាន និងអនាម័យក្នុងខណ្ឌឱ្យកាន់តែមានភាពទាក់ទាញ និងឈានមុខគេជាងមុនក្នុងចំណោមខណ្ឌទាំង ១៤ ក្នុងព្រះរាជាណាចក្រកម្ពុជា។

### ២.២.១. មូលហេតុដែលនាំឱ្យមានការបំពុលបរិស្ថានក្នុងខណ្ឌដូនពេញ

បញ្ហានៃការបំពុលបរិស្ថាន គឺជាការព្រួយបារម្ភចម្បងមួយដែលប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំនានាកំពុងជួបប្រទះ។ ទន្ទឹមនឹងការអភិវឌ្ឍន៍ច្បាស់ណាស់បញ្ហាផ្សេងៗទៀតនឹងកើតឡើងជាមួយគ្នាដែរ ហើយក្នុងចំណោមបញ្ហាទាំងនោះ បរិស្ថានគឺទទួលរងការគំរាមកំហែង និងប៉ះពាល់ខ្លាំងជាងគេបំផុត។ ជាក់ស្តែងក្នុងខណ្ឌដូនពេញ គឺកំពុងមានការអភិវឌ្ឍន៍ ដូច្នេះការបំពុលគឺមិនអាចចៀសផុតបានឡើយ គ្រាន់តែទំហំនៃការបំពុលទាំងនោះមានកម្រិតណា។ ដោយឡែកដើម្បីឱ្យយល់កាន់តែស៊ីជ្រៅយើងគួរសិក្សាពាក្យគន្លឹះសំខាន់ៗមួយចំនួនជាមុនសិន។

- **ការបំពុល** ៖ គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យពុល ។[36]
- **សំណល់រឹង** ៖ គឺសំដៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬកំទេចកំទី ដែលលែងត្រូវបាន ប្រើប្រាស់ ហើយត្រូវគេបោះចោល មានបំណងបោះចោល ឬត្រូវតែបោះចោល។[37]
- **សំណល់រាវ** ៖ គឺសំដៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបាន ធ្វើប្រព្រឹត្តកម្មក្តី។[38]
- **ប្រភពបំពុល** ៖ គឺសំដៅទៅលើទីតាំងទាំងឡាយណា រួមទាំងលំនៅស្ថាន និងអគារ រដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬ ចូលទៅក្នុងបណ្តាញលូ សាធារណៈ។

ជាទូទៅមូលហេតុ ដែលនាំឱ្យមានការបំពុលបរិស្ថានគឺកើតមានឡើងច្រើនករណីដូចជា ការបំពុលទឹក ដី ខ្យល់ សម្លេង និងសំណង់រឹង រាវ។

#### ២.១.១.១. ការបំពុលទឹក

ទឹក គឺជាប្រភពយ៉ាងសំខាន់ដែលមិនអាចខ្វះបានសម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ ក៏ដូចជា រុក្ខជាតិនានា។ ម្យ៉ាងវិញទៀតទឹក គឺជាប្រភពចំណែកមួយដែលជម្រុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យ ជឿនលឿនក្នុងវិស័យ ឧស្សាហកម្ម កសិកម្ម ទេសចរណ៍ គមនាគមន៍។ល។ ក៏ប៉ុន្តែការលេចចេញនូវ ឥទ្ធិពលអវិជ្ជមានទៅលើគុណភាព បរិស្ថានបានបង្កឱ្យមានផលវិបាកដល់ជីវិតមនុស្ស សត្វ ដោយ សារការប៉ះពាល់ សារធាតុគីមីរាប់សែនប្រភេទរួមទាំង កាកសំណល់ដែលផ្ទុកជាតិពុលផ្សេងៗ ជាច្រើន។

ការបំពុលទឹក គឺជាសកម្មភាពទាំងឡាយដែលធ្វើឱ្យទឹកប្រើប្រាស់ខុសពីលក្ខណៈដើម។ ការបំពុលទឹកអាចជះឥទ្ធិពលអាក្រក់ដល់សោភ័ណភាពបរិស្ថាន អាស្រ័យទៅតាមកម្រិតនៃការបំពុល ភាគច្រើនមាននៅតាមទឹកន្លែងសំខាន់មួយចំនួនដូចជា រមណីយដ្ឋាន ទីក្រុង ទឹកម្សាន្ត និង ទីសាធារណៈជាដើម។[39] ការបំពុលទឹកអាចកើតឡើងតាមរយៈកត្តា២ធំៗគឺ៖

---

[36] វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជជួនណាត

[37] អនុក្រឹត្យ ស្តីពីការគ្រប់គ្រង សំណល់រឹង, លេខ ៣៦ អនក្រ/បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ មាត្រា ៣

[38] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យ ការបំពុលទឹក, លេខ ២៧ អនក្រ/បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា ៣

[39] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ដកស្រង់ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៩

➢ **កត្តាមនុស្ស**

បរិស្ថានជាអ្វីៗដែលនៅជុំវិញខ្លួនយើង ហេតុនេះដើម្បីអភិវឌ្ឍន៍ការរស់នៅប្រចាំថ្ងៃ បំពេញតម្រូវការអ្នកប្រើប្រាស់ ការប្រើសារធាតុគីមីនានា ធ្វើអោយមនុស្សបានបំផ្លាញបរិស្ថានជាពិសេសប្រភពទឹកនេះតែម្តង។ ដោយយើងសង្កេតឃើញថាមានមូលហេតុជាច្រើន ដែលកើតចេញពីសកម្មភាព របស់មនុស្សបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រភពទឹករួមមានដូចជា៖

- **ការបង្ហូរទឹកកខ្វក់** ៖ មិនត្រឹមតែការបង្ហូរទឹកកខ្វក់ចេញពីរោងចក្រ សហគ្រាស ដែលជាប្រភពនាំឱ្យមានការបំពុលទឹកនោះទេ ប៉ុន្តែក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ យើងក៏ចូលរួមចំណែក ក្នុងការបំពុលដោយប្រយោលផងដែរ។ ទឹកកខ្វក់ទាំងនោះកើតឡើងពីការប្រើប្រាស់របស់យើងដូចជា ការបញ្ចេញទឹកកខ្វក់ពីបន្ទប់ទឹក ផ្ទះបាយ ដែលទឹកកខ្វក់ទាំងនោះត្រូវបានបង្ហូរចូលទៅក្នុងប្រភពទឹក ដូចជា បឹង ទន្លេ។ ការបង្ហូរទឹកកខ្វក់ចូលទៅក្នុងប្រភពទឹកគឺជាការបំពុលដែលនាំឱ្យមានផលប៉ះពាល់ខ្លាំង ជាពិសេសនៅរដូវប្រាំង ព្រោះរដូវប្រាំងប្រភពទឹករាក់ ដូចនេះនៅពេលដែលមានការបង្ហូរទឹកកខ្វក់ចូលទៅ នោះនាំឱ្យបរិមាណទឹកទន្លេ មិនគ្រប់គ្រាន់ក្នុងការបន្សាបទឹកកខ្វក់ ដែលហូរចូលជាហេតុនាំឱ្យ ការបំពុលទឹកមានការប៉ះពាល់ខ្លាំងដល់ សុខភាពប្រជាជន។[40] ជាពិសេសបងប្អូន ដែលរស់នៅតាមដងទន្លេសាប ដែលពួកគាត់ស្នាក់នៅលើទឹក បន្ទោរបង់ ប្រើប្រាស់ ទឹកទន្លេជាហេតុនាំឱ្យមានការបំពុលទឹកដោយផ្ទាល់។
- **វិស័យទេសចរណ៍** ៖ ការធ្វើដំណើរតាមទូក កប៉ាល់ នាវាទេសចរណ៍នានាដែលឆ្លងកាត់ប្រភពទឹក បានបង្ហូរកាកសំណល់ ក៏ដូចជាទឹកកខ្វក់ដែលកើតចេញពីការបន្ទោរបង់ ចូលទៅក្នុងទឹកដោយ មិនបានធ្វើប្រព្រឹត្តកម្ម។ វាក៏ជាផ្នែកមួយដែលនាំឱ្យមានការបំពុលទឹកផងដែរ។
- **សម្រាម** ៖ មានមតិភាគច្រើនបានគិតថា សម្រាមគឺមិនសូវមានការប៉ះពាល់ដល់ការបំពុលទឹកប៉ុន្មានទេ ប៉ុន្តែផ្ទុយទៅវិញសម្រាម គឺមានផលប៉ះពាល់ខ្លាំងទៅដល់ប្រភពទឹក។ នៅពេលដែលសម្រាមទាំងនោះធ្លាក់ចូល ឬក៏នៅពេលដែលមានភ្លៀងធ្លាក់ នោះទឹកដែលហូរចេញពី គំនរសម្រាមបានធ្លាក់ចូលទៅក្នុងប្រភពទឹក គឺជាបញ្ហាធំដែលបង្កឱ្យកើតជាបាក់តេរី និងសារជាតិពុលយ៉ាងខ្លាំងដល់សុខភាព អ្នកដែលប្រើប្រាស់។[41]
- **រោងចក្រ សហគ្រាស សិប្បកម្ម** ៖ ក្នុងសង្វាក់ផលិតកម្ម រោងចក្រ សហគ្រាស សិប្បកម្មមួយចំនួនដែលមានទីតាំងជាប់នឹងដងទន្លេបានធ្វើបញ្ចេញ កាកសំណល់ដែលមាន

[40] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ដកស្រង់ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៩

[41] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យ ការបំពុលទឹក, លេខ ២៧ អនក្រ/បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា ៩

គ្រោះថ្នាក់ទៅដល់បរិស្ថាន។ ដោយឡែកការបញ្ចេញកាកសំណល់ដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្ម មិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្មនោះទេ ហើយប្រសិនបើកាកសំណល់ទាំងនោះត្រូវបានបង្ហូរចូលទៅក្នុងទឹក នោះគឺជាប្រភពចម្បងដែលនាំឱ្យមានការបំពុលទឹក ជាពិសេសគឺ ការបូមខ្សាច់ដែលនាំឱ្យទឹកមានភាពកខ្វក់ខ្លាំង។

- **<u>កត្តាធម្មជាតិ</u>**

អាកាសធាតុ ក៏ជាកត្តាបំពុលបរិស្ថានទឹកផងដែរ គឺតាមរយៈទឹកភ្លៀង ព្យុះ។ល។ ដែលសារធាតុនីត្រូសែនដែលមានផ្ទុកនៅក្នុងទឹកភ្លៀង គឺបានបំពុលទឹកនៅពេលដែលទឹកភ្លៀងទាំងនោះបានហូរចូលទៅក្នុង ប្រភពទឹកហើយអាចនឹងបង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗចំពោះ សុខភាពអ្នកប្រើប្រាស់។ សារធាតុនេះក៏បានបំផ្លាញរុក្ខជាតិព្រមទាំង ជីវៈចម្រុះដែលរស់នៅក្នុងទឹកផងដែរ។[42]

### ២.១.១.២. ការបំពុលខ្យល់

បរិយាកាស គឺជាប្រព័ន្ធធម្មជាតិយ៉ាងរឹងមាំដែលទ្រទ្រង់រាល់ជីវិតមនុស្ស សត្វនានា នៅលើផែនដី។ ការបំផ្លាញស្រទាប់អូហ្សូន គឺជាការបំផ្លាញនាំងការពារផែនដីពីកាំរស្មីអ៊ុលត្រាវីយ៉ូឡេ ដែលបង្កផលវិបាកដល់ជីវិតលើផែនដី។ ការបំពុលខ្យល់គឺជាការបង្កើតឡើងដោយ សារធាតុគីមី ឬជីវៈសរីរាង្គដែលបំផ្លាញ ឬបណ្តាលឱ្យមានផលប៉ះពាល់ដល់មនុស្ស ឬភាវៈមានជីវិតទាំងឡាយ និងបំផ្លាញដល់បរិស្ថានក្នុងបរិយាកាស។ សរុបមកវិញការបំពុលខ្យល់ត្រូវបានចាត់ទុកថាជាការគំរាមកំហែងដល់មនុស្ស និងឋានប្រព័ន្ធនានានៅលើផែនដី។[43]

បន្ថែមពីនេះ នៅក្នុងបរិយាកាសគេរកឃើញមានភ្នាក់ងារបំពុលរាប់រយប្រភេទ ប៉ុន្តែមានតែសារធាតុបំពុលចំនួន ៥ ប៉ុណ្ណោះដែលត្រូវបានប្រទេសមួយចំនួនតាមដានអង្កេតជាប្រចាំ និងត្រូវបានគេប្រើជាសញ្ញាចង្អុលបង្ហាញពីគុណភាពនៃខ្យល់។ សារធាតុទាំងនោះមានដូចជា កាបូនម៉ូណូអុកស៊ីត ស្ពាន់ធ័រឌីអុកស៊ីត អាសូតអុកស៊ីត អូសូន និងភាគល្អិតអណ្តែតវិលវល់ដែលបញ្ចេញពីរោងចក្រ យានយន្ត ឬមធ្យោបាយដឹកជញ្ជូន ចំហេះអុស ធ្យូង ការបាចជី ការដុតកាកសំណល់ ធូលីដីជាដើម។ នៅពេលដែលកំហាប់របស់ឧស្ម័នទាំងនេះនៅក្នុងខ្យល់កើនឡើងលើសពីកម្រិតកំណត់ណាមួយនោះ ខ្យល់ត្រូវរងការបំពុល ហើយផ្តល់គ្រោះថ្នាក់ដល់ការដកដង្ហើម។[44] ការបំពុលខ្យល់នៅក្នុងខណ្ឌដូនពេញ ក៏ដូចជានៅរាជធានីភ្នំពេញទាំងមូលគឺបណ្តាលមកពីមូលហេតុមួយចំនួនដូចជា៖

- **ការបំពុលចេញពីយានយន្តគ្រប់ប្រភេទ** ៖ ដោយសារតែចំនួនប្រជាជននៅក្នុងទីក្រុងមានចំនួនច្រើន ដូចនេះតំរូវការនៃការប្រើប្រាស់ យានយន្តនៅក្នុងការធ្វើដំណើរក៏

---

[42] គេហទំព័រសុខភាពកម្ពុជា http://www.healthcambodia.com/p6241/ ដកស្រង់ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៩

[43] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ២០១៣, ទំព័រ ៣៨

[44] បរិស្ថានសៀវភៅជំនួយស្មារតី ២០០៥, ទំព័រ ២៣៩

មានច្រើន ដែលជាហេតុនាំឱ្យកម្រិតផ្សែងពុលដែលចេញពីយានយន្តទាំងនោះត្រូវបានបញ្ចេញទៅក្នុងបរិយាកាសដែលនាំឱ្យការបំពុលខ្យល់មានកម្រិតខ្ពស់។ លើសពីនេះទៅទៀតក៏សង្កេតឃើញថានៅក្នុងប្រទេសកម្ពុជា ភាគច្រើនប្រើប្រាស់នូវយានយន្តចាស់ៗដែលនាំ ចូលពីបរទេសដែលវាអាច បញ្ចេញផ្សែងពុលទៅក្នុងបរិយាកាសច្រើនជាងយានយន្តថ្មី។[45]

- **ផ្សែងពុលចេញពីឈាបនដ្ឋាន** ៖ យើងដឹងមកហើយថានៅកម្ពុជាយើងគោរពព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ក្នុងនោះដែរកម្ពុជាយើងមានទំនៀមទម្លាប់មួយក្នុងព្រះពុទ្ធសាសនា គឺការបូជាចំពោះអ្នកដែលបានស្លាប់ទៅ។ ជាទូទៅការបូជានោះធ្វើឡើងនៅវត្តអារាមដែលជាទីកន្លែងប្រារព្ធពិធីសាសនាផ្សេងៗ ហេតុនេះហើយផ្សែងដែលចេញពីការបូជាសព ពិតជាបង្កនូវផលប៉ះពាល់ដល់ផ្លូវដង្ហើមយ៉ាងធ្ងន់ធ្ងរចំពោះប្រជាជនដែលរស់នៅជុំវិញតំបន់នោះ ជាពិសេសគឺធ្វើឱ្យមានមេរោគនៅក្នុងខ្យល់។ ងាកមកមើលក្នុងខណ្ឌដូនពេញ ទីតាំងវត្តឧណ្ណាលោមជាកន្លែងបូជាសពមួយដែលស្ថិតនៅចំកណ្ដាលក្រុងតែម្ដង។ ប៉ុន្តែដោយមានការស្នើសុំពីប្រជាពលរដ្ឋដែលរស់នៅជុំវិញនោះ មានការប៉ះពាល់ខ្លាំង បច្ចុប្បន្នអាជ្ញាធរបានសម្រេចលុបចោលការបូជាសពនៅក្នុងរាជធានីភ្នំពេញក្រោមហេតុផល ខ្លាចប៉ះពាល់បរិស្ថាន ទេសចរណ៍ និងសុខុមាលភាពប្រជាពលរដ្ឋ។[46]
- **ការបំពុលដោយធូលីដី** ៖ គឺជាមូលហេតុដែលគួរឱ្យកត់សម្គាល់មួយដែលបង្កឱ្យមានការបំពុលខ្យល់។ ភាគច្រើនធូលីដីនៅក្នុងក្រុងបណ្ដាលមកពីការរៀបចំ ឬគ្រប់គ្រងគ្រឿងសំណង់ផ្សេងៗនៅពេលដឹកជញ្ជូនមិនបានត្រឹមត្រូវដូចជាការដឹកខ្សាច់ ដី ស៊ីម៉ង់ជាដើម ហើយការដែលធ្វើឱ្យធ្លាក់ ឬបើុងតាមខ្យល់ជាហេតុបង្កឱ្យមានការបំពុលខ្យល់។ ម្យ៉ាងទៀតការទុកដាក់គ្រឿងសំណង់ផ្ទាល់នៅលើផ្លូវក៏ជាហេតុបង្កមួយនៃការបំពុលខ្យល់ ព្រោះវានឹងធ្វើឱ្យផ្លូវពោរពេញទៅដោយធូលី។
- **ការបំពុលដែលចេញពីចំហេះអូស.ធ្យូង** ៖ ការប្រើប្រាស់អូសធ្យូងជាប្រភពថាមពលចម្អិនអាហារគឺជាទំនៀមទម្លាប់មួយរបស់ប្រជាជនខ្មែរ។ ទោះជាអ្នករស់នៅរាជធានីភ្នំពេញក៏ដោយ ក៏ការប្រើប្រាស់អូស ធ្យូងនៅតែជាវិធីពេញនិយមក្នុងការចម្អិនអាហារ។[47] ការប្រើប្រាស់អូស ធ្យូងនេះគឺមានផលប៉ះពាល់ខ្លាំងណាស់ដល់បរិស្ថាន

---

[45] National Reporting Guidelines for CDS-14/15 Thematic Areas, Ministry of Environment, ទំព័រ ១

[46] គេហទំព័រ https://www.postkhmer.com/ ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩

[47] National Reporting Guidelines for CDS-14/15 Thematic Areas, Ministry of Environment, ទំព័រ ២

ពីព្រោះចំហេះនៅក្នុងអូស ធ្យូង បានបង្កើតនូវឧស្ម័នកាបូនិច និងឧស្ម័នកាបូណាត រួមទាំងឧស្ម័នពុលដ៏ច្រើនទៀតចូលទៅក្នុងបរិយាកាស ហើយឧស្ម័នពុលទាំងនោះគឺប៉ះពាល់ខ្លាំងណាស់ដល់គុណភាពខ្យល់។[48]

### ២.១.១.៣. ការបំពុលសម្លេង

ជាការពិតណាស់ ការបំពុលដោយសូរសម្លេង គឺជាបញ្ហាបរិស្ថានចម្បងនៅក្នុងទីក្រុងដែលប្រមូលផ្តុំដោយសម្លេងចរាចរណ៍ សម្លេងយន្តហោះ សម្លេងរថភ្លើង សម្លេងតន្ត្រី ឧបករណ៍បំពងសម្លេង និងសម្លេងដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្មជាដើម គឺសុទ្ធសឹងតែជាបណ្តុំនៃការបំពុលដោយសម្លេង។ បើទោះបីជាមនុស្សមួយចំនួនយល់ថា ការបំពុលដោយសម្លេងមិនសូវជាមានផលប៉ះពាល់ក៏ដោយ តែវាអាចជះឥទ្ធិពលអាក្រក់ខ្លាំងចំពោះ ជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នា។ អនុលោមតាម អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីអំពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ បានបង្ហាញថាមូលហេតុដែលនាំឱ្យមានការបំពុលដោយសម្លេងគឺមកពីប្រភពធំៗចំនួន ២ គឺ៖

- **ការបំពុលដោយប្រភពចល័ត** ៖ ការបំពុលដោយប្រភពចល័តនេះ គឺសំដៅទៅលើការបំពុលដោយសម្លេងចេញពីយានយន្តនៅលើផ្លូវសាធារណៈ។ ដោយសារតែចំនួនយានយន្តនៅក្នុងរាជធានីភ្នំពេញមានការកើនឡើងខ្លាំង ការបំពុលដោយសម្លេងក៏មានកើតឡើងដែរ។
- **ការបំពុលដោយប្រភពអចល័ត** ៖ ចំពោះប្រភពអចល័តវិញ សំដៅទៅលើប្រភពបំពុលដែលកើតចេញពីទីតាំងជាក់លាក់ណាមួយដែល មិនមានការបំលាស់ទីដូចប្រភពចល័តនោះទេ។ ប្រភពចល័តនេះអាចជារោងចក្រ កន្លែងកំសាន្ត ក្លឹបកំសាន្ត សហគ្រាស រោងចក្រ ការដ្ឋានសំណង់ជាដើម។ល។

### ២.១.១.៤. ការបំពុលដី

ការបំពុលដីជាបញ្ហាប្រឈមមួយដែលគួរមានការព្រួយបារម្ភក្នុងពេលបច្ចុប្បន្ន ថ្វីត្បិតតែវាមិនសូវជះឥទ្ធិពលដល់អ្នករស់នៅ កណ្តាលទីក្រុងប៉ុន្មានក៏ដោយ។ ប៉ុន្តែការបំពុលដីនៅតែជាបញ្ហាប្រឈមមួយចំពោះ អ្នកដែលរស់នៅប្រកបរបរកសិកម្មនៅតាមបណ្តាជាយៗក្រុង។ មូលហេតុនៃការបំពុលដីជាទូទៅគេឃើញមានកត្តាចំនួន ៣ រួមមាន៖

- **កត្តាកសិកម្ម** ៖ មូលហេតុនៃការបំពុលដីចំពោះវិស័យកសិកម្ម គឺភាគច្រើនទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលហួសកម្រិតសម្រាប់ការពារដំណាំ ឬការប្រើ

[48] មូលដ្ឋានគ្រឹះនៃបរិស្ថាន ដោយលោក ស្តាន់ វិន, ទំព័រ១៣៩

ប្រាស់សារធាតុពុលហួសកម្រិតដែលធ្វើឱ្យ សារធាតុពុលទាំងនោះស្ថិតនៅក្នុងដីបង្កឱ្យមានការពុល និងធ្វើឱ្យដីនោះពោរពេញទៅដោយសារធាតុពុលតែម្តង។ ដោយឡែកនៅក្នុងខណ្ឌដូនពេញទាំងមូលពុំមានដីដែលសម្រាប់ធ្វើកសិកម្មនោះទេ ហេតុនេះការបំពុលដីដោយ កត្តាកសិកម្មពុំមានផលប៉ះពាល់ អ្វីធ្ងន់ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឡើយ។

- **កត្តាមនុស្ស** ៖ សម្រាមគឺជាមូលហេតុមួយដែលបណ្តាលឱ្យមានការបំពុលដី នៅពេលដែលមនុស្សមិនបានយកចិត្តទុកដាក់ ក្នុងការវេចខ្ចប់សម្រាមឱ្យមានរបៀប ដោយបែងចែករវាងសម្រាមសរីរាង្គ និងសម្រាមកែច្នៃ។ នៅពេលដែលសម្រាមត្រូវគេគរទុកចោលនៅកន្លែងណាមួយ ដូចជានៅទីលានចាក់សម្រាមជាដើម គឺបណ្តាលឱ្យដីនៅតំបន់នោះបាត់បង់នូវជីវជាតិ សម្បូរទៅដោយមេរោគ និងបាក់តេរីគ្រប់ប្រភេទ ជាហេតុបង្កឱ្យមាននូវជាតិពុលនៅក្នុងដី។[49]
- **សំណល់ចេញពីរោងចក្រ សហគ្រាស សិប្បកម្ម** ៖ គឺធ្វើឱ្យមានផលប៉ះពាល់ដល់គុណភាពដីគួរឱ្យមានការព្រួយបារម្ភ ដែលភាគច្រើនគឺពាក់ព័ន្ធនឹងការបង្ហូរទឹកស្អុយ ឬទឹកដែលមានជាតិពុលផ្ទាល់ចូលទៅក្នុងដីតែម្តង ដែលបង្កឱ្យមានការពុលដី ជាពិសេសទីឧស្សាហកម្មធុនធ្ងន់ ដូចជារោងចក្រផលិតសារធាតុគីមី រោងចក្រផលិតលោហៈធាតុជាដើម។[50] ប៉ុន្តែជាភ័ព្វសំណាង នៅក្នុងខណ្ឌដូនពេញ ពុំមានរោងចក្រ ធនធ្ងន់ ដែលផលិតសារធាតុគីមី ឬលោហៈធាតុនោះទេ។ ដូច្នេះ ប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌដូនពេញមិនរងការប៉ះពាល់ពីការបំពុលដីដែលកើតចេញពីរោងចក្រទាំងនោះទេ។

### ២.១.១.៥. ការបំពុលដោយសំណល់រឹង និង រាវ

សំណល់មិនថាទោះជារឹង ឬរាវទេ គឺបណ្តាលមកពីមនុស្សមិនបានរៀបចំ ឬបែងចែកចំពោះសំណល់រឹង ឬរាវឱ្យបានត្រឹមត្រូវ ជាហេតុធ្វើឱ្យមានការបំពុល និងមានការកកស្ទះលូនៅពេលមានភ្លៀងធ្លាក់ទៀតផង។ ជារៀងរាល់ថ្ងៃ គឺមានសម្រាមជាច្រើនដែលត្រូវបានបោះចោល ទោះបីជាសម្រាមប្រភេទណាក៏ដោយ កាលដែលយើងទុកដាក់មិនបានត្រឹមត្រូវវាបង្កឱ្យមានមេរោគ ជាហេតុដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នករស់នៅប្រចាំថ្ងៃ។ ក្នុងនោះដែរ គេបានឱ្យនិយមន័យដោយឡែកពីគ្នាអំពីសំណល់ រឹង រាវនេះថា៖

- **សំណល់រឹង** ៖ គឺសំដៅដល់វត្ថុរឹង ឬសារធាតុរឹង កម្ទេចកម្ទីដែលលែងត្រូវការប្រើប្រាស់ ឬបោះបង់ចោល។

---

[49] ដកស្រង់ចេញពី www.youtube.com (land pollution) ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩

[50] គេហទំព័រ https://audiopse.blogspot.com/2017/02/blog-post_25.html!?m=1 ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩

- **សំណល់រាវ** ៖ គឺសំដៅដល់វត្ថុរាវដែលបញ្ចេញពីប្រភពបំពុល ដែលហូរចូលទៅក្នុងតំបន់សាធារណៈ ឬហូរចូលទៅក្នុងបណ្តាញលូ ទោះមិនបាន ឬបានធ្វើប្រព្រឹត្តកម្មក្តី។[51] អាចនិយាយម្យ៉ាងទៀតថាសំណល់រាវគឺសំដៅដល់វត្ថុរាវដែលជាសារធាតុរាវរួមផ្សំគ្នាជាមួយនឹងសារធាតុរឹងខ្លះ ដែលត្រូវបានបោះចោលជាប្រចាំថ្ងៃទៅតាមប្រព័ន្ធលូទឹកស្អុយផ្សេងៗ។[52]

ដោយឡែកនៅក្នុងខណ្ឌដូនពេញយើងឃើញថា នៅតាមដងផ្លូវ ក៏ដូចជានៅតាមមុខផ្ទះរបស់ប្រជាពលរដ្ឋ ឃើញថាកាកសំណល់ជាច្រើន ប្រភេទមិនត្រូវបានរៀបចំឱ្យមានរបៀបរៀបរយ និងមានលំដាប់នោះទេ។ ការគ្រប់គ្រងសំណល់រឹង រាវនៅតំបន់នេះនៅមានកម្រិតនៅឡើយ ហើយការដែលនៅតំបន់នេះ មិនមានការរៀបចំសំណល់រឹង រាវឱ្យមានសណ្តាប់ធ្នាប់គឺមកពីមូលហេតុចម្បង ២ យ៉ាង៖

- **បញ្ហាទី១** ៖ ប្រជាជនរស់នៅក្នុងតំបន់នេះបានទ្បាយលំគ្នានូវសំណល់រឹង និងរាវជាមួយគ្នាក្នុងថង់តែមួយ ដែលបណ្តាលឱ្យសំណល់ទាំង២ប្រភេទនេះក្លាយជាល្បាយ។ ពោលគឺការចោលសម្រាមពុំមានបែងចែកនូវប្រភេទច្បាស់លាស់ ហើយការប្រមូលផ្តុំចោលសំណល់ជាល្បាយនេះ ក៏អាចលាយលំជាមួយសំណល់ដែលមានលក្ខណៈជាសរីរាង្គ ដែលងាយនឹងរលួយធ្វើឱ្យ មានក្លិនស្អុយ និងបំពុលទៅដល់ដីដែលជា ទីតាំងចោលសម្រាម និងធ្វើឱ្យខូចសុខភាពរបស់ប្រជាពលរដ្ឋទៀតផង។
- **បញ្ហាទី២** ៖ ដែលបណ្តាលឱ្យមានការបំពុលក្នុងខណ្ឌដូនពេញ គឺបណ្តាលមកពីការខ្វះខាតនូវទីតាំងត្រឹមត្រូវក្នុងការចោលសម្រាម និងវិធីសាស្រ្តក្នុងការគ្រប់គ្រងសម្រាម។[53] ក្នុងតំបន់នេះផងដែរការទុកដាក់សម្រាម និងការប្រមូលសម្រាមគឺនៅមានកម្រិតជាខ្លាំង ដោយសារតែការចាក់សម្រាមត្រូវយកមកទុកនៅតាមដងផ្លូវ និងនៅមុខផ្ទះរៀងៗខ្លួន ដែលបណ្តាលឱ្យមានការកកស្ទះចរាចរណ៍ និងបង្កឱ្យមានក្លិនស្អុយដែលប៉ះពាល់ដល់ផ្លូវដង្ហើមទៀតផង។[54]

---

51 គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩

52 គេហទំព័រ https://seylanote.wordpress.com ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩

53 គេហទំព័រ http://www.maciejdakowicz.com/features/stung-meanchey-garbage-dump-phonm-penh-cambodia/ ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩

54 គេហទំព័រ http://www.phnompenhpost.com/scavengers-linger-long-dead-dump-site ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩

### ២.២.២. វិធានការដោះស្រាយក្នុងការបំពុលទាំង ៥

ជាទូទៅ រាល់ការបង្កឡើងឱ្យមានការបំពុលបរិស្ថាន ទោះជាកម្រិតណាក្តី វិធានការចាំបាច់នឹងត្រូវរៀបចំឡើង ដើម្បីធានាដល់គុណភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ និងស្ថេរភាពរបស់ប្រព័ន្ធជីវសាស្ត្រ ដោយសារការបំពុលបរិស្ថានធ្វើឱ្យ មានផលអវិជ្ជមានយ៉ាងច្រើនចំពោះបុគ្គលគ្រប់រូបក៏ដូចជាសង្គមទាំងមូល។ ម្យ៉ាងវិញទៀតក្នុងការបំពុលទាំង ៥ ខាងលើ សុទ្ធសឹងតែមានវិធានការក្នុងការដោះស្រាយ ព្រោះវាជាកត្តាមួយដ៏ចាំបាច់ ក្នុងការធានានូវនិរន្តភាពនៃបរិស្ថានស្អាត ហើយវិធានការទាំងនោះត្រូវរៀបចំ និងសិក្សាឱ្យបានម៉ត់ចត់ និងល្អិតល្អន់ជាទីបំផុតដោយថ្នាក់ដឹកនាំ និងក្រសួង អង្គការនានាដែលពាក់ព័ន្ធ ដើម្បីធានារក្សានូវការការពារឱ្យមានប្រសិទ្ធភាពខ្ពស់ជាទីបំផុត។[55] ការរស់នៅស្អាត ត្រូវបានក្រសួងអប់រំ យុវជននិងកីឡា ដាក់ឱ្យកូនខ្មែររៀន តាំងពីថ្នាក់មត្តេយ្យសិក្សារហូតមក។ ការរស់នៅដែលមានបរិស្ថាននៅជុំវិញខ្លួនល្អ មានខ្យល់អាកាសល្អបរិសុទ្ធ មានដើមឈើពណ៌បៃតងរីកដេរដាស គ្មានក្លិនស្អុយ និងគ្មានសំឡេងរំខានជាដើម គឺសុទ្ធសឹងជាក្តីស្រម៉ៃរបស់មនុស្សគ្រប់គ្នាប្រាថ្នាចង់បាន។

យុទ្ធនាការទីក្រុងស្អាត ត្រូវបានក្រសួងបរិស្ថាន និងក្រសួងទេសចរណ៍ បានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋជួយថែរក្សា និងដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ រហូតដល់បានបង្កើតនូវ ពាក្យស្លោកមួយឃ្លាថា "**ទីក្រុងស្អាត រមណីដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**"។ ប៉ុន្តែការផ្សព្វផ្សាយពាក្យស្លោកនេះ ហាក់នៅមិនទាន់មានប្រសិទ្ធិភាពនៅឡើយ ពោលគឺរាជធានីភ្នំពេញ នៅពោរពេញដោយគំនរសម្រាម ស្ទើរគ្រប់ទីកន្លែង។ នៅតាមផ្សារមួយចំនួនក្នុងខណ្ឌដូនពេញ គេបានឃើញថាសម្រាមព្រោងព្រាត ត្រូវបានគេយកទៅចាក់ចោល នៅមុខផ្សារដោយ បានជះក្លិនស្អុយដល់អ្នកធ្វើដំណើរតាមដងផ្លូវ និងប្រជាពលរដ្ឋដែលទៅទិញទំនិញ និងអ្នកដែលមានផ្ទះនៅជិតគំនរសម្រាម។ បន្ទាប់ពីបានដឹងអំពីមូលហេតុបង្ក និងផលប៉ះពាល់មួយចំនួន ដូចរៀបរាប់ខាងលើ ក្នុងខណៈនេះ ដើម្បីធ្វើការឆ្លើយតបទៅនឹងការបំពុលទាំងនោះ តើយើងគួរមានវិធានការដូចម្តេចខ្លះដើម្បីការពារ ទប់ស្កាត់ កាត់បន្ថយ ឬលុបបំបាត់នូវការបំពុលទាំងនោះ។

- ជាក់ស្តែងនៅក្នុងខណ្ឌដូនពេញយើងបានឃើញថា អភិបាលនៃគណៈអភិបាលខណ្ឌក៏ដូចជាថ្នាក់ដឹកនាំបាននាំកម្លាំងចុះទៅធ្វើ សកម្មភាពដែលពាក់ព័ន្ធនឹងសណ្តាប់ធ្នាប់សោភ័ណភាព និងបរិស្ថានជាច្រើនដូចជា៖ ការចុះទៅត្រួតពិនិត្យការទុកដាក់សម្រាម និងសណ្តាប់ធ្នាប់ក្នុង ផ្សារមួយចំនួនដែលស្ថិតក្នុងខណ្ឌដូនពេញ។ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ ក៏បានដឹកនាំកម្លាំងប្រជាការពារខណ្ឌ ចុះប្រមូលសំរាម

[55] ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦, មាត្រា ២

តាមមាត់លូ និងអណ្តូងលូ នៅជុំវិញទីរួមផ្សារកណ្តាលនៅមុនពេល និងពេលកំពុងមានភ្លៀងធ្លាក់ ដើម្បីបញ្ចៀសបាននូវការជន់លិចដោយជំនន់ទឹកភ្លៀង។[56]

- ធ្វើការផ្សព្វផ្សាយដល់កម្លាំងប្រជាការពារ តាមគោលដៅប្រចាំការ និងសង្កាត់ពាក់ព័ន្ធឱ្យប្រមូលសំរាមដែលនៅសេសសល់ក្បែរអណ្តូងលូ មាត់លូ និងបើកគម្របលូ នៅតាមទីតាំងសំខាន់ៗ រួមមាន តីរវិថីព្រះស៊ីសុវត្ថិ ជុំវិញរមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ ជុំវិញបរិវេណផ្សារកណ្តាល ផ្លូវលេខ៤៧ និងផ្លូវលេខ១៩ ជាដើម។ ដើម្បីឱ្យទឹកហូរលឿនជៀសវាងការលិចលង់។[57]
- ដឹកនាំកម្លាំងប្រជាការពារខណ្ឌ បានបន្តចុះរៀបចំសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងចុះប្រមូលគំនរដី សំរាម និងសំណល់លូនៅតាមបណ្តោយផ្លូវមួយចំនួនក្នុងមូលដ្ឋាន ខណ្ឌដូនពេញ ដើម្បីបង្កលក្ខណៈងាយស្រួលដល់រថយន្តបូមលូរបស់រដ្ឋបាលរាជធានីភ្នំពេញ ធ្វើការបូមលូ និង បាញ់លាងសំអាតផ្ទាល់។
- ការប្រមូលជនអនាថាតាមទីសាធារណៈក្នុង តំបន់ខណ្ឌដូនពេញ និងជាពិសេសនៅតាមដងមាត់ទន្លេដែលជា កន្លែងសម្រាប់ភ្ញៀវទេសចរណ៍ដ៏សំខាន់មួយ។ រដ្ឋបាលខណ្ឌបានដឹកនាំកម្លាំងចុះទៅប្រមូលជនអនាថានេះគឺ ក្នុងគោលបំណងធ្វើការអប់រំណែនាំ និងបង្ហាត់បង្រៀនទៅ តាមវិជ្ជាជីវៈដោយស្ម័គ្រចិត្តរៀងៗខ្លួន និងជាងនេះទៅទៀតគឺដើម្បីរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់សាធារណៈឱ្យមានរបៀបរៀបរយ។[58]
- អាជ្ញាធរខណ្ឌបានចុះទៅត្រួតពិនិត្យផ្ទាល់ ក៏ដូចជាសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធស្វែងរកដំណោះស្រាយភ្លាមៗ ចំពោះបញ្ហាដែលបង្កឱ្យប៉ះពាល់ដល់សោភ័ណភាព ឬការបំពុលបរិស្ថានផ្សេងៗ។ វិធានការដែលចុះទៅអនុវត្តទាំងនោះមានដូចជា អប់រំប្រជាពលរដ្ឋឱ្យយល់ដឹងអំពីការថែរក្សាបរិស្ថាន ការវេចខ្ចប់ និងការទុកដាក់សម្រាម ការរៀបចំប្រព័ន្ធលូបង្ហូរទឹកស្អុយ ដោយធ្វើការជួសជុលលូដែលមានសភាពចាស់ទ្រុឌទ្រោមឡើងវិញ និងស្តារមាត់លូ ប្តូរប្រព័ន្ធលូថ្មី រៀបចំដាក់លូថ្មីដែលមានមុខកាត់ធំងាយស្រួលឱ្យទឹកហូរបានលឿន។

[56] គេហទំព័រ http://www.khmerthmey.com/2018/06/politics/4988/ ដកស្រង់នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩

[57] គេហទំព័រ http://www.khmerthmey.com/2018/06/politics/4988/ ដកស្រង់នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩

[58] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩

ថ្វីត្បិតជាមានការចុះពិនិត្យការបំពុលទឹក ដី ខ្យល់ សម្លេង និងសំណល់រឹង រាវផ្សេងៗក៏ពិតមែន ប៉ុន្តែបញ្ហាក៏នៅតែកើតមាន នោះគឺបណ្តាលមកពីប្រជាលរដ្ឋមួយចំនួនខ្វះការយល់ដឹង ឬមានការយល់ដឹងហើយតែបែរជានៅបន្ត ប្រព្រឹត្តនូវអំពើខុសថែមទៀតផងៗ ដូចនេះដើម្បីដោះស្រាយទៅនឹងបញ្ហាប្រឈមទាំងអស់នេះឱ្យទាន់សភាពការណ៍គឺ ត្រូវតែរកវិធានការដំណោះស្រាយឱ្យបានល្អ និងមានប្រសិទ្ធភាពខ្ពស់ៗ

### ២.២.២.១. វិធានការដោះស្រាយការបំពុលទឹក

នៅព្រះរាជាណាចក្រកម្ពុជា មុននឹងឈានដល់ដំណោះស្រាយ ក្រសួងបរិស្ថានដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញនូវសំណល់រាវ ត្រូវពិនិត្យគុណភាពនៃទឹក និងស្វែងរកប្រភពនៃការបំពុលជាមុនសិន មុនឈានដល់ការចេញនូវដំណោះស្រាយពាក់ព័ន្ធៗ[59] ការត្រួតពិនិត្យទៅលើការបំពុលទឹក គឺទប់ស្កាត់ និងកាត់បន្ថយនូវការបំពុលដើម្បីការពារដល់សុខភាពមនុស្សៗ[60] ការត្រួតពិនិត្យ និងស្វែងរករាល់ប្រភពបំពុល ក៏ដូចជាសកម្មភាពទាំងឡាយណាដែលបង្កឱ្យមានការបំពុលទឹកនៅ តាមតំបន់សាធារណៈ គឺជាដំណោះស្រាយចម្បងមួយដែលប្រសើរបំផុតដើម្បីធ្វើឱ្យបរិស្ថានទឹកចៀសផុតពីការបំពុល ហើយជាពិសេស គឺជួយកែលម្អសោភ័ណភាព និងប្រកបទៅដោយផាសុខភាពល្អក្នុងការរស់នៅប្រចាំថ្ងៃៗ វិធានការដោះស្រាយសំខាន់ៗដែលគួរតែអនុវត្តន៏ឱ្យមានប្រសិទ្ធិភាព និងបានត្រឹមត្រូវមានដូចជា៖

- **វិធានការសម្រាប់សាធារណៈ**៖ គឺជាកត្តាចាំបាច់បំផុតដែលបំផុសគំនិតអប់រំតាមរយៈការផ្សព្វផ្សាយគ្រប់មធ្យោបាយ និងបង្កើនគំនិតឱ្យមាន ការយល់ដឹងផ្នែកថែរក្សាគុណភាពទឹកស្អាត ដើម្បីតម្រូវការប្រចាំថ្ងៃ និងចៀសផុតពីការគ្រោះថ្នាក់ដោយការបំពុលទឹកជាដើមៗ[61]
- **វិធានការសម្រាប់រោងចក្រ សហគ្រាស សិប្បកម្ម**៖ គឺមានន័យថាគ្រប់រោងចក្រ សហគ្រាស សិប្បកម្ម និងគ្រប់បណ្តាក្រុមហ៊ុននានា ត្រូវតែអនុវត្តការគ្រប់គ្រងកាកសំណល់ឱ្យបានត្រឹមត្រូវ និងដាច់ខាតមិនត្រូវបង្ហូរកាកសំណល់សារធាតុរាវដែលមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម ចូលទៅប្រភពទឹកនោះទេៗ គ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ត្រូវចាត់វិធានការឱ្យរោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនផ្សេងៗដែលបញ្ចេញនូវកាកសំណល់ជាសារធាតុរាវ ឬសារធាតុគីមីពុល ត្រូវមានការធ្វើ

[59] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា១៨ និង ១៩

[60] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា១

[61] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ដកស្រង់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩

ប្រព្រឹត្តកម្មនូវសំណល់ជាសារធាតុពុលទាំងនោះជាមុន សិនមុននឹងបង្ហូរចូលទៅក្នុងទឹក ឬក៏រៀបចំឱ្យមានអាងស្តុកកាកសំណល់សារធាតុពុល។

- **ការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់៖** ការដែលមានភាពធូរលុងផ្នែកច្បាប់ចំពោះការត្រួតពិនិត្យសារធាតុពុល និងការត្រួតពិនិត្យក្នុងការគ្រប់គ្រងសំណល់ជាសារធាតុពុល វានាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ជាហេតុនាំឱ្យការបំពុលទឹកនៅតែមានបន្តបន្ទាប់។ ហេតុដូចនេះថ្នាក់ដឹកនាំ និងក្រសួងស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ត្រូវចាត់វិធានការតឹងរ៉ឹងចំពោះគ្រប់មធ្យោបាយដែលបង្ហូរកាកសំណល់ជាសារធាតុពុលទៅក្នុងប្រភពទឹក។

### ២.២.២.២. វិធានការដោះស្រាយការបំពុលខ្យល់

ជាទូទៅបញ្ហាក្នុងការបំពុលខ្យល់ត្រូវបានចាត់ចែង និងគ្រប់គ្រងដោយក្រសួងបរិស្ថានដែលមានតួនាទីក្នុងការត្រួតពិនិត្យ និងអនុញ្ញាតទៅលើការបញ្ចេញខ្យល់ដែលអាចផ្តល់ផលប៉ះពាល់ទៅដល់បរិស្ថាន។ បន្ថែមពីនេះទៅទៀត គុណភាពរបស់ខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានត្រួតពិនិត្យ និងតាមដានជាប្រចាំដោយក្រសួងបរិស្ថាន។[62] ហើយកត្តាបំពុលខ្យល់ជាទូទៅត្រូវបង្កើតឡើងភាគច្រើនដោយសារមនុស្សជាកត្តាចម្បង ដូច្នេះដំណោះស្រាយអាចមានដូចតទៅ៖

- **កត្តារដ្ឋាភិបាល** ៖ រាជរដ្ឋាភិបាលគឺជាកត្តាមួយដែលសំខាន់ចម្បងមួយក្នុងការចូលរួមកាត់បន្ថយការបំពុលខ្យល់ ដោយត្រូវគ្រប់គ្រងឱ្យបាននូវការបញ្ចេញនូវឧស្ម័នពុល ឬការបញ្ចេញនូវផ្សែងនានាដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនទាំងអស់ឱ្យមានកម្រិតស្តង់ដារ ឬជំរុញឱ្យមានម៉ាស៊ីនបន្សុទ្ធខ្យល់មុនពេលបញ្ចេញខ្យល់ដែលមានសារធាតុពុលទាំងនោះនៅក្នុងខ្យល់។ ចេញវិធានការឱ្យបញ្ឈប់ការដុតកាកសំណល់ និងផ្លាស្ទិចគ្រប់ប្រភេទព្រោះការដុតកាកសំណល់ពិតជាធ្វើឱ្យមានការបំពុលខ្យល់ធ្ងន់ធ្ងរដល់ផ្លូវដង្ហើម។ បញ្ឈប់ការបូជាសពក្នុងវត្តអារាមដែលនៅក្នុងក្រុង ដោយបញ្ហាខ្យល់ពុល ដែលបញ្ចេញពីឈាបនដ្ឋាន គឺជាខ្យល់ដែលពោរពេញទៅដោយមេរោគ បាក់តេរី និងជាតិពុលដែលចេញពីសរីរាង្គកាយមនុស្ស។ រដ្ឋាភិបាលក៏គួរតែរៀបចំឱ្យមាន មធ្យោបាយដឹកជញ្ជូនសាធារណៈឱ្យបានច្រើន ជាជាងប្រើប្រាស់យានយន្តផ្ទាល់ខ្លួនច្រើននាំឱ្យផ្សែងដែល ចេញពីយានយន្តមានបរិមាណច្រើន លើសលុប។ ជាងនេះទៅទៀតគួរតែតំឡើងពន្ធនាំចូលយានយន្តចាស់ៗ ហើយបន្ថយពន្ធលើការនាំចូលរថយន្តថ្មី ជំរុញឱ្យប្រជាជនប្រើប្រាស់យានយន្តថ្មីដើម្បីកាត់បន្ថយការបំពុលខ្យល់។

---

[62] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០, មាត្រា ២៦

- **កត្តាប្រជាជន** ៖ ប្រជាជនជាកត្តាមួយដែលចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារបរិស្ថាន ដោយកាត់បន្ថយនូវ ការប្រើប្រាស់អូស.ធ្យូង សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃឱ្យបានតិចបំផុត។ បញ្ឈប់ការដុតកាកសំណល់ ហើយងាកមកកែច្នៃ ឬប្រើប្រាស់ឡើងវិញ នូវកាកសំណល់ទាំងនោះ ចៀសវាងការដុតដែលនាំឱ្យមាន ឧស្ម័នបំពុលខ្លាំងប៉ះពាល់ដល់ស្រទាប់អូហ្សូន។ ប្រជាជនគួរតែងាកមកប្រើប្រាស់ សេវាដឹកជញ្ជូនសាធារណៈវិញ ជាជាងប្រើប្រាស់រថយន្តផ្ទាល់ខ្លួន ដើម្បីកាត់បន្ថយយានយន្តនៅតាមដងផ្លូវក៏ដូចជាកាត់បន្ថយនូវផ្សែងបំពុលផងដែរ។[63]

### ២.២.២.៣. វិធានការដោះស្រាយការបំពុលដោយសម្លេង

វិធានការក្នុងការដោះស្រាយការបំពុលដោយសម្លេង គឺត្រូវអប់រំដល់ប្រជាពលរដ្ឋឱ្យបានយល់នូវបញ្ហាផលប៉ះពាល់ និងធ្វើការផ្សព្វផ្សាយច្បាប់តាមគ្រប់មធ្យោបាយ ដើម្បីឱ្យប្រជាជនមានការយល់ដឹង ព្រមទាំងចូលរួមកាត់បន្ថយការបំពុលដោយសម្លេង។

ជាមួយគ្នានេះការបញ្ចេញសម្លេងពីប្រភពយានយន្ត ទីតាំងផលិតកម្មផ្សេងៗ ការប្រើប្រាស់ម៉ាស៊ីនភ្លើង សម្លេងរំខានដែលចេញពីការដ្ឋានសំណង់នានា សម្លេងដែលចេញពីក្លឹបកម្សាន្ត ខារ៉ាអូខេ ផុងបាស និងការប្រើប្រាស់ឧបរណ៍បំពងសម្លេងគ្រប់ប្រភេទ ជាពិសេសសម្លេងរំខានដែលកើតចេញពីការកែច្នៃបំពង់ស៊ីម៉ាំងខុសពីបច្ចេកទេស ដែលបង្កឱ្យមានការបំពុលដោយសម្លេង គឺត្រូវធ្វើការហាមឃាត់ឱ្យបាន។ ហើយគប្បីកម្រិតស្តង់ដារនៃ ការបញ្ចេញសម្លេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកម្រិតស្តង់ដារសម្លេងអតិបរមាសម្រាប់ ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន។[64]

### ២.២.២.៤. វិធានការដោះស្រាយការបំពុលដី

ចំណែកឯការបំពុលដីវិញ គឺជាការបំពុលដែលកើតឡើងជាទូទៅតាមរយៈការបំពុលដោយសម្រាម ការបំពុលដោយការបង្ហូរសារធាតុគីមី និងការប្រើប្រាស់ជីគីមីទៅលើដី។ វិធានការក្នុងការគ្រប់គ្រងទាក់ទងទៅនឹងការបំពុលដីមានដូចជា៖

- ធ្វើការប្រើប្រាស់វត្ថុដែលងាយរំលាយក្នុងរយៈពេលខ្លី ឬសម្ភារៈដែលអាចប្រើប្រាស់ ឬកែច្នៃម្តងទៀតបាន។
- អប់រំប្រជាពលរដ្ឋឱ្យយល់ដឹងក្នុង ការគ្រប់គ្រង និងការវេចខ្ចប់ទុកដាក់សម្រាមដោយបែងចែកសម្រាមស្ងួត និងសម្រាមរាវ។

---

[63] គេហទំព័រ http://googlegalaxyscience.com/air-pollution/?lang=km ដកស្រង់នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩

[64] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងរំខានដោយសម្លេង, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០, មាត្រា ៧

- ចាត់ចែងឱ្យមានកន្លែងសម្រាប់ទុកដាក់សម្រាមឱ្យ បានត្រឹមត្រូវដើម្បីងាយស្រួលក្នុងការប្រមូលផ្តុំសម្រាមចៀសវាងពីការចោលសម្រាមពាសវាលពាសកាល។

### ២.២.២.៥. វិធានការដោះស្រាយការបំពុលដោយសំណល់រឹង និងរាវ

ក្នុងព្រះរាជាណាចក្រកម្ពុជា ការគ្រប់គ្រងសំណល់រឹងក៏ត្រូវបានរៀបចំ និងអនុវត្តន៍ដោយបន្ថែមអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង ដែលបានចែងទាក់ទងទៅនឹងការគ្រប់គ្រងសម្រាមទាំង ២ប្រភេទ៖ គឺសម្រាមធម្មតា និងសម្រាមដែលប្រកបដោយគ្រោះថ្នាក់។ ក្នុងនោះដែរ ការរៀបចំ និងចាត់ចែងសម្រាមទាំង ២ប្រភេទនេះត្រូវស្ថិតនៅក្រោមការសម្រេចរបស់ក្រសួងបរិស្ថាន ក្នុងការពិនិត្យលើការអនុវត្តន៍ រៀបចំ ប្រមូល បោះចោល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយ និងការចាក់ចោលសម្រាម។[65] សំណល់រឹងជាបញ្ហាមួយដែលរដ្ឋាភិបាលកំពុងប្រឈមមុខនឹងបញ្ហានេះ។

នាពេលបច្ចុប្បន្ននេះសំណល់រឹងជាច្រើន ត្រូវបានគេយកមកកែច្នៃជាថ្មីសម្រាប់ប្រើប្រាស់ឡើងវិញ និងប្រើក្នុងគោលដៅថ្មីផ្សេងទៀត។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាល និងក្រសួងបរិស្ថានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងជម្រុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំណល់រឹងនៅក្នុងទីក្រុង ព្រមទាំងមានភារកិច្ចដូចជា៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ជាមួយក្រសួងស្ថាប័ន និងដៃគូដែលពាក់ព័ន្ធ។
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថកិច្ចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការគ្រប់គ្រងសំណល់រឹង។
- គាំទ្រ និងលើកកម្ពស់ការអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ ព្រមទាំងធ្វើការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំណល់រឹង ដែលប្រកបដោយសុវត្ថិភាពបរិស្ថាន។
- ណែនាំអំពីការកាត់បន្ថយការបង្កើត ការប្រើប្រាស់ថង់ប្លាស្ទិច ក៏ដូចជាសំណល់រឹងផ្សេងៗទៀតដែលអាចយកមកប្រើប្រាស់ឡើងវិញ ឬក៏អាចកែច្នៃបាន។
- លើកកម្ពស់សម្ភារៈដែលកើតឡើងពីការប្រើប្រាស់ឡើងវិញ ឬកើតចេញពីការច្នៃប្រឌិតដែលចេញពីសំណល់រឹង។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងក្នុងទីប្រជុំជន។[66]

[65] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង,លេខ ៣៦ អនក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩,មាត្រា៦
[66] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥, មាត្រា៥

ចំពោះបញ្ហាសំណល់ជាសារធាតុរាវ ជាទូទៅមានប្រភពចម្បងមកពីរោងចក្រ លំនៅដ្ឋាន សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនផ្សេងៗ។ ចំពោះការគ្រប់គ្រងសំណល់រាវយើងគប្បីដឹងអំពីវិធានការក្នុងការអនុវត្តន៍មួយចំនួនដូចជា៖

- ហាមឃាត់ដាច់ខាត រាល់ការចាក់ចោល ឬការបង្ហូរចេញនូវសំណល់ដែលជាសារធាតុរាវ ចេញពីប្រភពណាមួយដែលមិនបាន ឆ្លងកាត់ការអនុវត្តន៍តាមកម្រិតស្តង់ដារនៃការបញ្ចេញសំណល់ជាសារធាតុរាវដូចមាន ចែងក្នុងអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក។
- ក្រសួងបរិស្ថាន ត្រូវរៀបចំកម្រិតស្តង់ដារនៃការបញ្ចេញសំណល់រាវដូចមានចែងក្នុងមានចែងក្នុងមាត្រា៤ និងមាត្រា៥នៃអនុក្រឹត្យនេះ។[67]
- ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពី ប្រភពបំពុលទៅកន្លែងដទៃក្នុងគោលបំណងណាមួយ ត្រូវមកសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន។[68]
- ក្រសួងបរិស្ថាន ត្រូវយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញចោលរបស់ប្រភពបំពុល។ ម្ចាស់សិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីក្រសួងបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស។[69]

ចំពោះផែនការយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថានក្នុងការគ្រប់គ្រងសំណល់រឹង និងរាវ គឺមានការរៀបចំគោលនយោបាយជាតិសម្រាប់ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន រួមជាមួយផែនការមេស្តីពី វិធានការចម្រុះនូវការគ្រប់គ្រងសំណល់រឹង និងរាវប្រកបដោយនិរន្តភាព។ ក្នុងនោះដែរក្រសួងបរិស្ថានក៏ព្យាយាមពង្រឹងទៅលើការអនុវត្តច្បាប់ លើកកម្ពស់ការអនុវត្តន៍កម្មវិធីកែច្នៃ និងការប្រើប្រាស់ឡើងវិញនៃសំណល់។ បង្កើតកម្មវិធីកាត់បន្ថយបរិមាណសំណល់ និងបង្កើតទីលានចាក់សម្រាមប្រកបដោយបច្ចេកទេស និងមានអនាម័យ។[70]

[67] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា ៦
[68] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា ១០
[69] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា ១៩
[70] គេហទំព័រសុខភាពកម្ពុជា http://www.healthcambodia.com/p7901/ ដងស្រង់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ការរៀបចំទីក្រុង ឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព គឺជាកត្តាមួយដែលសំខាន់ដើម្បីសម្រេចបាននូវទិសដៅនៃ ការអភិវឌ្ឍន៍ប្រកបដោយជោគជ័យ។ ដោយឡែកខណ្ឌដូនពេញក៏បានចូលរួមចំណែក ក្នុងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងរាជធានីភ្នំពេញប្រកបដោយលក្ខណៈស្តង់ដានៃនគរូបនីយកម្ម និងដើម្បីធានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យមានសន្តិសុខ និងសុវត្ថិភាព។ ជាមួយគ្នានេះ រដ្ឋបាលខណ្ឌដូនពេញ បានគិតគូរទៅដល់ សុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ទាំងសុវត្ថិភាពផ្លូវកាយ និងសុវត្ថិភាពចិត្ត។ ពោលគឺ រក្សាឱ្យបាននូវ ការអនុវត្តន៍នូវគោលនយោបាយ ភូមិ.ឃុំ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល។ បន្ថែមពីនេះទោះបីជាមានការអភិវឌ្ឍន៍ក៏ពិតមែន ប៉ុន្តែភាពខ្វះចន្លោះនៅតែមាន គឺខណ្ឌដូនពេញបានធ្វើការរៀបចំហេដ្ឋារចនាសម្ព័ន្ធបានច្រើនដូចជាការរៀបចំឱ្យមាននូវ ប្រព័ន្ធលូ បង្គោលភ្លើងបំភ្លឺតាមដងផ្លូវបានរៀបចំបំពាក់នូវប្រព័ន្ធកាមេរ៉ាសុវត្ថិភាពគ្រប់ភ្លើងស្តុប និងតាមផ្លូវផងដែរ។

លើសពីនេះទៅទៀត កត្តាជម្រុញឱ្យមានការអភិវឌ្ឍន៍ មិនថាក្រោមរូបភាពជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នោះទេ។ គឺរមែងកើតចេញពី កំណើនប្រជាសាស្ត្រ សេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងកត្តាផ្សេងទៀត ដែលជាដើមចងជម្រុញដល់ការអភិវឌ្ឍន៍ ប្រកបដោយ និរន្តរភាព និងចីរភាព។ ជាងនេះទៅទៀត ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវចំពោះអាជីវករមួយចំនួនដែលប៉ះពាល់ ដល់សណ្តាប់ធ្នាប់ និងសោភ័ណភាពនោះ។ នាពេលបច្ចុប្បន្ន រដ្ឋបាលខណ្ឌដូនពេញបានចុះទៅធ្វើការណែនាំ និងធ្វើការហាមឃាត់រាល់សកម្មភាពដែល ប្រើប្រាស់ចំណីផ្លូវសម្រាប់ទីតាំងអាជីវកម្មរបស់ខ្លួន។

សរុបសេចក្តីមកអាចសន្និដ្ឋានបានថា ការរៀបចំទីក្រុង ក៏ជាខណ្ឌមួយ គឺពិតជាមានសារៈសំខាន់ណាស់។ ពីព្រោះកាលណាយើងរៀបចំបានតាម លក្ខណៈបច្ចេកទេសនៃនគរូបនីយកម្ម និងត្រឹមត្រូវតាមផែនការ ឬប្លង់គោល គឺទីក្រុង ក៏ដូចជាខណ្ឌនឹងមានសណ្តាប់ធ្នាប់ របៀបរៀបរយ និងសោភ័ណភាព។ ការរៀបចំនេះ អាចប្រព្រឹត្តទៅដោយរលូនបានត្រូវមានការចូលរួមរវាងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ និងសមត្ថកិច្ច ដើម្បីផ្តល់នូវសោភ័ណភាពដល់ទីក្រុង និងការបង្កើនគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ។

# អនុសាសន៍

## អនុសាសន៍

យោងតាមការពិនិត្យមើលអំពីស្ថានភាពជាក់ស្តែងនៅក្នុងខណ្ឌដូនពេញ គឺសង្កេតឃើញថាមានការអភិវឌ្ឍន៍ និងរីកចម្រើនខ្លាំងគួរឱ្យកត់សម្គាល់ ដោយក្នុងនោះរួមមាន សួនច្បារវិមានឯករាជ្យ សួនច្បារមុខព្រះបរមរាជវាំង សួនច្បារវត្តបុទុមវត្តី ផ្សាររាត្រី ព្រមទាំងហោដ្ឋារចនាសម្ព័ន្ធផ្សេងៗដទៃទៀត។ ទោះបីជាយ៉ាងនេះក្តី ក៏មានបញ្ហាមួយចំនួនទៀតដែលរដ្ឋបាល អាជ្ញាធរខណ្ឌបានអនុវត្ត ប៉ុន្តែហាក់បីដូចជាពុំសូវទទួលបានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរនៅឡើយ ។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ យើងខ្ញុំសូមសេចក្តីអនុញ្ញាតបញ្ចេញនូវមតិដូចតទៅៈ

- ស្នើរសុំដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលខណ្ឌដូនពេញ សុំមេត្តាពង្រឹងច្បាប់ និងអនុវត្ត នូវគោលនយោបាយ ភូមិ.ឃុំ មានសុវត្ថិភាព ឱ្យបានតឹងរឹង ដើម្បីធានាដល់សុវត្ថិភាពរស់នៅរបស់ប្រជាពលរដ្ឋ។
- ស្នើរសុំដល់ថ្នាក់ដឹកនាំ ឬអាជ្ញាធរមានសមត្ថកិច្ច មេត្តាស្វែងរកវិធានការដែលមានប្រសិទ្ធភាពខ្ពស់ ក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពដូចជា រៀបចំការចងនូវបណ្តាញខ្សែភ្លើង ខ្សែបណ្តាញផ្សេងៗដែលនៅលើបង្គោលឱ្យបានត្រឹមត្រូវ ដើម្បីធានាដល់ការរៀបចំសោភ័ណភាព។ បន្ថែមពីនេះ ត្រូវធ្វើការទប់ស្កាត់នូវការប្រើប្រាស់ចំណីផ្លូវសាធារណៈសម្រប់អាជីវកម្មរបស់ខ្លួន ដែលប៉ះពាល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។
- ទន្ទឹមនឹងការអភិវឌ្ឍន៍នេះ បញ្ហាមួយដែលជាបញ្ហាចំបងចំពោះមុខ និងផ្តល់ផលប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋផងនោះគឺ ការធ្វើដំណើរឆ្លងកាត់ផ្លូវ របស់អ្នកដំណើរថ្មើរជើង។ ដើម្បីដោះស្រាយនឹងបញ្ហានេះ ស្ពានឆ្លងកាត់សម្រាប់អ្នកដំណើរថ្មើរជើង គួរតែសាងសង់ឡើង ដើម្បីបញ្ចៀសគ្រោះថ្នាក់ដែលអាចកើតឡើង។ ផ្អែកតាមលទ្ធផលដែលទទួលបានតាមរយៈ ការសាងសងនូវស្ពានឆ្លងកាត់សម្រាប់អ្នកដំណើរថ្មើរជើង ត្រង់ទីតាំងចំណុច ផ្សារដម្កូវន្តែ នៅលើផ្លូវជាតិលេខ៤ គឺបានផ្តល់ភាពងាយស្រួល និងសុវត្ថិភាពដល់អ្នកដំណើរថ្មើជើងឆ្លងកាត់។
- ស្នើរសុំដល់និស្សិត និងអ្នកដែលបានអានលើសារណានេះទាំងអស់ សូមមេត្តាចូលរួមចំណែកចែករំលែកចំណេះដឹងលើបញ្ហានេះ និងចូលរួមជម្រុញឱ្យមានការអភិវឌ្ឍន៍ថ្មីៗបន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ,លេខ នស/រកម/០៥០៨/០១៧
- ច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦
- ច្បាប់ ស្តីពី ផ្លូវថ្នល់, លេខ នស/រកម/០៥១៤/០០៨
- ច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦
- អនុក្រឹត្យលេខ ០៣ អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ ស្តីពី ការបង្កើតខណ្ឌបឹងកេងកង
- អនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី៨ ខែ មករា ឆ្នាំ២០១៩ ស្តីពី ការបង្កើតខណ្ឌកំបូល
- អនុក្រឹត្យលេខ ៥៤៧ អនក្រ.បក, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតខណ្ឌច្បារអំពៅ
- អនុក្រឹត្យលេខ ៥៧៩ អនក្រ.បក, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតខណ្ឌជ្រោយចង្វារ
- អនុក្រឹត្យលេខ ៥៤៨ អនក្រ.បក, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតខណ្ឌព្រែកព្នៅ
- អនុក្រឹត្យលេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង
- អនុក្រឹត្យលេខ ៣៦ អនក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការគ្រប់គ្រង សំណល់រឹង
- អនុក្រឹត្យលេខ ២៧ អនក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការត្រួតពិនិត្យ ការបំពុលទឹក
- អនុក្រឹត្យលេខ ១១៣ អនក្រ.បក, ស្តីពី ការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន
- អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- ផែនការណែនាំលេខ ០២០ ផក, ស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព
- គោលនយោបាយជាតិ ស្តីពី លំនៅដ្ឋាន ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤
- សេចក្តីណែនាំ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ ០១៣/១៨ សណន ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៨

- សេចក្តីជូនដំណឹង ស្តីពី ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈតាមបណ្តោយមហាវិថីព្រះនរោត្តម, លេខ ២២០/១៩ សជណ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៩

## ២. សៀវភៅតែខនិពន្ធ

- សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា
- វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជជួនណាត
- នីតិរដ្ឋបាលទូទៅ, ឯកឧត្តម បណ្ឌិត ថេង ច័ន្ទសង្វារ
- នីតិរដ្ឋបាលទូទៅ, លោកសាស្ត្រាចារ្យ ហៀង សាង
- សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ
- ឆ្នាំ ២០១៣
- បរិស្ថានសៀវភៅជំនួយស្មារតី ឆ្នាំ២០០៥
- អត្ថបទ National Reporting Guidelines for CDS-14/15 Thematic Areas, Ministry of Environment
- មូលដ្ឋានគ្រឹះនៃបរិស្ថាន ដោយលោក ស្តាន់ វិន

## ៣. គេហទំព័រ

- គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/
- គេហទំព័រ https://sopheaksrey.wordpress.com/2017/02/28/khan-in-phnompne-2017/
- គេហទំព័រ http://worldpopulationreview.com/countries/cambodia-population/
- គេហទំព័រ https://www.realestate.com.kh/km/news/daun-penh-district-phnom-penh/
- គេហទំព័រនៃក្រសួងសាធារណការ និងដឹកជញ្ជូន http://www.mpwt.gov.kh/kh/post/5863
- គេហទំព័រ http://www.phnompenhreporter.com/article/46828
- គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com
- គេហទំព័រ https://www.postkhmer.com/
- គេហទំព័រ www.youtube.com (land pollution)
- គេហទំព័រ https://audiopse.blogspot.com/2017/02/blog-post_25.html!?m=1
- គេហទំព័រ https://seylanote.wordpress.com
- គេហទំព័រ http://www.maciejdakowicz.com/features/stung-meanchey-garbage-dump-phonm-penh-cambodia/

- គេហទំព័រ http://www.phnompenhpost.com/scavengers-linger-long-dead-dump-site
- គេហទំព័រ http://www.khmerthmey.com/2018/06/politics/4988/
- គេហទំព័រ http://googlegalaxyscience.com/air-pollution/?lang=km

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ


## ១. ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌដូនពេញ

ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់ៗនៅក្នុងខណ្ឌដូនពេញ និងសោភ័ណភាពរបស់ខណ្ឌដូនពេញ

ឧបសម្ព័ន្ធទី៣៖ សកម្មភាពរបស់រដ្ឋបាលខណ្ឌដូនពេញ

## ២. ឧបសម្ព័ន្ធគតិយុត្ត

ឧបសម្ព័ន្ធទី១៖ ប្លង់គោលប្រើប្រាស់ដី រាជធានីភ្នំពេញ ២០៣៥

ឧបសម្ព័ន្ធទី២៖ ច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៩ ស្តីពី ការបង្កើតខណ្ឌបឹងកេងកង

ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៩ ស្តីពី ការបង្កើតខណ្ឌកំបូល

ឧបសម្ព័ន្ធទី៥៖ អនុក្រឹត្យ ស្តីពី ការទទួលស្គាល់សមាសភាព ក្រុមប្រឹក្សាខណ្ឌដូនពេញ លេខ ៦៦៦ អនក្រ.តត

ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យ ស្តីពី ការគ្រប់គ្រង សំណល់រឹង, លេខ ៣៦ អនក្រ/បក

ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យ ស្តីពី ការត្រួតពិនិត្យ ការបំពុលទឹក, លេខ ២៧ អនក្រ/បក

ឧបសម្ព័ន្ធទី៨៖ អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក

ឧបសម្ព័ន្ធទី៩៖ អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ ៤២ អនក្រ.បក

ឧបសម្ព័ន្ធទី១០៖ អនុក្រឹត្យ ស្តីពី ការតែងតាំងមន្ត្រីរាជការ លេខ ១១៧៥ អនក្រ.តត

ឧបសម្ព័ន្ធទី១១៖ សេចក្តីជូនដំណឹង ស្តីពី ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ តាមបណ្តោយមហាវិថីព្រះនរោត្តម, លេខ ២២០/១៩ សជណ

ឧបសម្ព័ន្ធទី១២៖ ផែនការណែនាំ ស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព

ឧបសម្ព័ន្ធទី១៣៖ សេចក្តីណែនាំ ស្តីពីការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវក្នុងភូមិសាស្ត្រ រាជធានីភ្នំពេញ

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌដូនពេញ



ផែនទីរដ្ឋបាលរាជធានីភ្នំពេញ




ផែនទីរដ្ឋបាលខណ្ឌដូនពេញ

ប្រភព៖ www.phnompenh.gov.kh

# ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់ៗក្នុងខណ្ឌដូនពេញ និងសោភ័ណភាពរបស់ខណ្ឌ



ទីតាំង៖ សាលារាជធានីភ្នំពេញ




ទីតាំង៖ សាលាខណ្ឌដូនពេញ





ទីតាំង៖ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍





ទីតាំង៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC




ទីតាំង៖ អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងយុត្តិធម៌




ទីតាំង៖ ធនាគារជាតិនៃកម្ពុជា, តុលាការកំពូល





ទីតាំង៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




ទីតាំង៖ ស្ថានីយ៍រាជាយស្មយាន, សារមន្ទីរជាតិ






ទីតាំង៖ វិទ្យាល័យព្រះស៊ីសុវត្ថិ, សាលាបឋមសិក្សាចតុមុខ





ទីតាំង៖ វត្តឧណ្ណាលោម, វត្តបុទុមវត្តី





ទីតាំង៖ Raffle Hotel le Royal, Hotel Cambodiana




ទីតាំង៖ អគារវឌ្ឍនៈ វិមានកាណាឌីយ៉ា ផ្សារធំថ្មី




ទីតាំង៖ វិមានឯករាជ្យ សួនច្បារវិមានឯករាជ្យ ព្រះបរមរាជវាំង




ទីតាំង៖ សួនច្បារមុខព្រះបរមរាជវាំង ព្រះអង្គដងកើ វត្តភ្នំ




ទីតាំង៖ ស្ថានីយ៍រំដោះទឹកជំនន់ នៅខាងមុខផ្សាររាត្រី




ប្លង់នៃការរៀបចំមហាវិថីព្រះនរោត្តម



ការរៀបចំគូសគំនូសសម្រាប់អ្នកថ្មើរជើង និងផ្លូវសម្រាប់ការជិះកង់
មហាវិថីព្រះនរោត្តម

ប្រភព៖ https://www.construction-property.com/khread-news-1202/

# ឧបសម្ព័ន្ធទី៣៖ សកម្មភាពផ្សេងៗរបស់រដ្ឋបាលខណ្ឌដូនពេញ






សកម្មភាព៖ ប្រមូលសំរាម និងលាងសំអាតផ្លូវនៅក្នុងខណ្ឌដូនពេញ





សកម្មភាព៖ ការរៀបចំប្រព័ន្ធកែលម្អបំពុងលូថ្មី





សកម្មភាព៖ ជួសជុលកែលម្អផ្លូវមួយចំនួន







សកម្មភាព៖ ចុះរៀបចំសណ្តាប់ធ្នាប់តាមចំណីផ្លូវក្នុងខណ្ឌដូនពេញ







សកម្មភាព៖ ចុះស្តាប្រព័ន្ធលូបង្ហូរទឹក





សកម្មភាព៖ រដ្ឋបាលខណ្ឌដូនពេញចុះណែនាំ និងរៀបចំសណ្តាប់ធ្នាប់

លើមហាវិថីព្រះនរោត្តម

# ឧបសម្ព័ន្ធគតិយុត្ត

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ

# ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥
# Land Use Master Plan of Phnom Penh City 2035

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការរៀបចំទឹកដី នគរូបនីយ៍កម្ម និងសំណង់

ព.ស ២៥៣៨ គ.ស ១៩៩៤

# ច្បាប់
## ស្តីពី
## ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
## ជំពូកទី ១
# កម្មវត្ថុ

**មាត្រា ១.-**

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានកម្មវត្ថុជំរុញអោយមានការរៀបចំកែលំអទីក្រុង និងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេស ក្នុងស្មារតី :

-គោរពប្រយោជន៍រួម និងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផង និងត្រួតពិនិត្យការសាងសង់ផង ។

-ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុង និងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រ និងលក្ខណៈពិសេសនៃជនបទនីមួយៗ ។

-ធានាលើតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ និងរក្សាបាននូវគុណភាពបរិដ្ឋាន ។

**មាត្រា ២.-**

ច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នេះ ត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន ។ ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែ ឬផ្លាស់ប្តូរ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នឹងត្រូវកែច្នៃអោយស្របទៅតាមច្បាប់ភូមិបាលនេះដែរ ។

**មាត្រា ៣.-**

ដើម្បីសំរេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតអោយមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដែលមានសមាជិក និងសំណើការតែងតាំង និងរៀបចំដោយអនុក្រឹត្យ ។

ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់សំរាប់ក្រុងភ្នំពេញមួយត្រូវបង្កើត ។ គណៈកម្មាធិការនេះដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេស ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ សំរាប់ក្រុងភ្នំពេញត្រូវកំរិតដោយអនុក្រឹត្យ ។

ចំពោះខេត្ត ក្រុងនានា ត្រូវបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដែលដឹកនាំដោយអភិ

បាលខេត្ត ក្រុង និងអង្គភាពបច្ចេកទេសខេត្ត ក្រុង ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផង ។ សមាសភាពច្បាស់លាស់ ព្រមទាំងដំណើរការនៃអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក្រោយពីមានការយល់ព្រមរបស់គណៈកម្មាធិការ ជាតិនេះ ។

## ជំពូកទី ២

## ឯកសារទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

### មាត្រា ៤.-

ឯកសារទាំងឡាយ ដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗ ឱ្យ សមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដី ខេត្ត ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិដ្ឋានការ ពារធនធានធម្មជាតិ ព្រមទាំងធានាដល់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

### មាត្រា ៥.-

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូប នីយកម្ម និងសំណង់ ខេត្ត ក្រុងនីមួយៗ ត្រូវគូសប្លង់គោល ដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍នៃរាជធានី ខេត្ត ក្រុង របស់ខ្លួន ។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងកំណត់ ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិដ្ឋាន និងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែល គណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ មានភារៈរៀបចំប្លង់គោលសំរាប់ តំបន់ពិសេស នោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ។

## ជំពូកទី ៣
## ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់

**មាត្រា ៦.-**

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ត្រូវរៀបចំឡើងសំរាប់រាជធានី ខេត្ត ក្រុង ។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជនក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។

**មាត្រា ៧.-**

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាល និងបរិក្ខាសាធារណៈ ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់ ។

**មាត្រា ៨.-**

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

**មាត្រា ៩.-**

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់សំរាប់រាជធានី និងខេត្ត ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានី ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ទៀត។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងដែរ ។

**មាត្រា ១០.-**

រាជរដ្ឋាភិបាលរៀបចំបទបញ្ញត្តិពិសេស និងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតម្លៃរមណីដ្ឋាន ឬអចលនវត្ថុណាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព ឬបច្ចេកទេស ។ បញ្ជីអចលនវត្ថុ ឬរមណីដ្ឋានទាំងនោះនឹងកំណត់ដោយអនុក្រឹត្យ ។ ការរុះរើ ការផ្លាស់ប្តូរទ្រង់ទ្រាយ និងការគ្រប់គ្រងអចលនវត្ថុ និងរមណីដ្ឋានទាំងនោះ ត្រូវកំណត់ដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

បទបញ្ញត្តិពិសេស និងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតម្លៃរមណីយដ្ឋាន ឬអចលនវត្ថុដែលផ្តល់ផលប្រយោជន៍ដល់ផ្នែក បុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព ឬបច្ចេកទេសត្រូវចារឹកក្នុងប្លង់គោលរៀបចំទឹកដី នគរូបនីយកម្ម និងអភិវឌ្ឍន៍ និងចារឹកក្នុងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ។

រាជរដ្ឋាភិបាលកំណត់ដោយអនុក្រឹត្យនូវបញ្ជីអចលនវត្ថុដែលមានប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព និងបច្ចេកទេស ដើម្បីធានាការគ្រប់គ្រងអចលនវត្ថុទាំងនោះ តាមបញ្ញត្តិច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

# ជំពូកទី ៤
## ការងារ និងសំណង់

**មាត្រា ១១.-**

រាល់ការកកាយរុករក ឬការស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យា ចាំបាច់ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចអោយបានជ្រាបភ្លាមៗ ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់ផ្អាកសំណង់ជាបន្ទាន់ ។

**មាត្រា ១២.-**

រាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជា អាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនអោយសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ :

- ទីបំរុងទុកទឹក និងទំនប់ទឹក
- ទីបំរុងជីករ៉ែ និងតំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិវឌ្ឍន៍
- ដីបំរុងទុកសំរាប់ផ្លូវ បំរុងសំរាប់ចំណីផ្លូវ និងដីបំរុងទុកសំរាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹងព្រមទាំងឆ្នេរច្រាំង
- ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឱ្យសង់ ។

លក្ខខណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខណ្ឌសំណង់ ឬតាំងទីលំនៅធុនស្រាល បណ្តោះអាសន្ន អនុញ្ញាតបានដោយអនុក្រឹត្យ ។

**មាត្រា ១៣.-**

ការងារសាងសង់ និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ គោរពតាមប្លង់គោលដែលមានចែងក្នុងមាត្រា ៤ និង ៥ នៃច្បាប់នេះ ។

**មាត្រា ១៤.-**

រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាព ឬការកែប្រែការប្រើប្រាស់សំណង់ណាមួយ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

ពាក្យស្នើសុំអនុញ្ញាតសាងសង់ត្រូវមានឯកសារ និងប្លង់ចាំបាច់ ។ នីតិវិធីក្នុងការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៥.-**

ឯកសារ និងប្លង់ចាំបាច់សំរាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់សំណង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករខ្មែរមានសញ្ញាប័ត្រ ឬជនណាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ។

លក្ខខណ្ឌដែលទាមទារអំពីសញ្ញាប័ត្រ និងទាមទារការទទួលស្គាល់ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៦.-**

ពាក្យសុំអនុញ្ញាតសាងសង់ត្រូវយកមកដាក់សុំដោយម្ចាស់កម្មសិទ្ធិដី ឬអ្នកបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ។ ពាក្យសុំអនុញ្ញាតនេះត្រូវមានភ្ជាប់មកជាមួយផងនូវឯកសារបញ្ជាក់អំពីកម្មសិទ្ធិរបស់ម្ចាស់ដី ។

**មាត្រា ១៧.-**

មិនអនុញ្ញាតអោយសាងសង់នូវសំណង់ណាក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោល ឬប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ។

មិនអនុញ្ញាតអោយសាងសង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិដ្ឋាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ ឬអចលនវត្ថុដែលមានសារប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រវប្បធម៌ សោភ័ណភាពបច្ចេកទេស ឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ ។

មិនអនុញ្ញាតអោយសាងសង់ បើសិនជាពុំមានការរៀបចំអោយមានហេដ្ឋារចនាសម្ព័ន្ធ ឬបរិក្ខាសាធារណៈអោយបានគ្រប់គ្រាន់ និងគំរោងសំណង់ដែលសុំ ។

**មាត្រា ១៨.-**

ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ អាជ្ញាធរខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មការដើម្បីពិនិត្យពាក្យសុំ និងចេញលិខិតអនុញ្ញាតសាងសង់ ។

**មាត្រា ១៩.-**

ចំពោះគំរោងសំណង់រដ្ឋបាល អង្គភាពដែលស្នើសុំសាងសង់ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ។

ការអនុញ្ញាតនោះអាចផ្តល់បានតែចំពោះសំណង់ណាដែលមានលក្ខណៈចាំបាច់សំរាប់ដំណើរការផ្នែករដ្ឋបាល ។

ការអនុញ្ញាតនេះមិនអាចនាំអោយមានការផ្លាស់ប្តូរនូវការប្រើប្រាស់ដីធ្លីដែលបានកំណត់មកហើយ ហើយក៏មិនអាចកែប្រែនូវលក្ខណៈសាធារណៈ និងអត្ថប្រយោជន៍ទូទៅនៃតំបន់នេះឡើយ ។

**មាត្រា ២០.-**

សំណង់ទាំងឡាយណាដែលអ្នកវិនិយោគទុនឯកជនបានសាងសង់នៅលើដីរបស់រដ្ឋស្របតាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកអោយរដ្ឋវិញពេលផុតកំណត់ចែងក្នុងកិច្ចសន្យានោះ ។

**មាត្រា ២១.-**

បើគ្មានមូលហេតុត្រឹមត្រូវដែលបានបញ្ជាក់ក្នុងច្បាប់នេះ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យពាក្យសុំ

សាងសង់ ឬចេញលិខិតអនុញ្ញាតសាងសង់ ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលមួយយ៉ាងយូរ ៤៥ថ្ងៃទេនោះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ក៏ត្រូវផ្តន្ទាទោសផងដែរ ចំពោះភ្នាក់ងារណាដែលបានពិនិត្យគំរោងសាងសង់ និងចេញលិខិតអនុញ្ញាតសាងសង់ដែលមិនស្រប និងបទបញ្ញត្តិ ។

ភ្នាក់ងារត្រួតពិនិត្យលើសំណង់ដែលពុំបានជំទាស់ ពេលដែលខ្លួនឃើញសំណង់លើការដ្ឋានណាមួយមិនគោរពតាមគំរោងដែលបានអនុញ្ញាត ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ទណ្ឌកម្មផ្នែករដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារដែលមានកំហុសដូចបានរៀបរាប់ខាងលើនេះ ត្រូវកំណត់ដោយច្បាប់រដ្ឋបាល ។

ចំណែកឯអ្នកសាងសង់ដែលមិនគោរពលិខិតអនុញ្ញាតសាងសង់ទេនោះ នឹងត្រូវទទួលបង្គាប់អោយរុះរើកែសំណង់ឱ្យស្របតាមលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ គឺចាប់ពីថ្ងៃទទួលលិខិតបញ្ជាផ្លូវការ ។

មន្ត្រីរាជការណាដែលរួមគំនិត នឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ ។

នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថាហេតុ សម្ភារៈ និងឧបករណ៍សំណង់នៅទីនោះ ត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងទៅតុលាការទារជម្ងឺចិត្ត ។

**មាត្រា ២២.-**

ម្ចាស់សំណង់ មុនពេលវាយកំទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកំទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតអោយរុះរើវាយកំទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈដែលការរុះរើវាយកំទេចសំណង់នោះមានការទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេស និងបេតិកភណ្ឌ ដែលរដ្ឋបានកត់ត្រា ។

**មាត្រា ២៣.-**

បទបញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុន ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ ច័ន្ទ ទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៤ នាសម័យប្រជុំ
រដ្ឋសភា លើកទី ២ នីតិកាលទី ១ ។

ភ្នំពេញ.ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៤

**ប្រធានរដ្ឋសភាស្តីទី**

**ឡូយ ស៊ីមឈាង**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៦៦៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌដូនពេញ នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៧៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការកំណត់ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៣៧៧ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## **សម្រេច**

**មាត្រា ១.-**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌដង្កោ នៃរាជធានីភ្នំពេញ ក្នុងអាណត្តិ ទី៣ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក **ហែម អាន** | ១៤/០៤/១៩៥៥ | ជាប្រធានក្រុមប្រឹក្សាខណ្ឌ |
| ២- | លោក **អ៊ុច សារុំ** | ០៥/០៦/១៩៥៩ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៣- | លោក **ឈឹម ឌីណា** | ០១/០៥/១៩៥៨ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៤- | លោក **សុខ គីមហេង** | ០១/០២/១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៥- | លោក **ជឹម សុទ្ធី** | ០៦/១២/១៩៦៤ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៦- | លោកស្រី **ឈឹម ចន្ថី** | ២៩/០៦/១៩៥៨ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៧- | លោក **ប៉ាង សុខុន** | ០៩/០៤/១៩៤៨ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៨- | លោក **ឯម សារឿន** | ២០/០៥/១៩៥៦ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៩- | លោក **គន់ ពន្លក** | ១៥/១២/១៩៧៣ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១០- | លោក **តា គុរុគ័ណ្ឌ** | ០៤/០៤/១៩៧៥ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១១- | លោក **នោម ឈាត** | ១៨/០១/១៩៥១ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១២- | លោក **ផាន់ ណារ៉ាត** | ១៥/០៣/១៩៥៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៣- | លោកស្រី **ចណ្ណា ណារត្រី** | ០៥/០៩/១៩៦៣ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៤- | លោកស្រី **ពេជ្រ សុជាតា** | ០៦/០៦/១៩៧០ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៥- | លោក **គ្រុយ សុវណ្ណ** | ០៥/០១/១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៦- | លោក **អ៊ុក សាកល** | ០៥/១២/១៩៥៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៧- | លោកស្រី **អ៊ុក ស៊ីថា** | ០៥/០៦/១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៨- | លោក **មាស មុនិន្ទ** | ១៣/០៤/១៩៥៩ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៩- | លោកស្រី **ម៉ុត ធិតា** | ២៤/០៦/១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |

**មាត្រា ២.-**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាខណ្ឌ**ដូនពេញ** នៃ**រាជធានីភ្នំពេញ** ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ៣៦ អ.ន.ក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសំណល់រឹង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំនត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក-"**សំណល់រឹង**" គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវឱ្យបោះបង់ចោល ។

ខ-"**សំរាម**" គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

គ-"**សំណល់ប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## ការគ្រប់គ្រងសំរាម

**មាត្រា ៤.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុង របស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេល

មធ្យម និងរយៈពេលវែង ។

**មាត្រា ៥.-**

ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា៥ នេះត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

**មាត្រា ៧.-**

ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៨.-**

ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ៩.-**

ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្មព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

**មាត្រា ១០.-**

ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣

## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ១១.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

**មាត្រា ១២.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី កំរិតស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងសំណល់ប្រ

កបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ១៣.-**

ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្របនឹងមានសុវត្ថិភាព ។

**មាត្រា ១៤.-**

ម្ចាស់សំណល់ ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទង និងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ-វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់ ។

**មាត្រា ១៥.-**

ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

**មាត្រា ១៦.-**

ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិកសម្ភព មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាន និងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តនីវាក្យខ័ណ្ឌទី១ នៃមាត្រា១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពី គោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ១៧.-**

ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ១៨.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-ប្រភពដើមរបស់សំណល់

គ-ការដឹកជញ្ជូនរបស់សំណល់ និងមធ្យោបាយវេចខ្ចប់

ឃ-ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

**មាត្រា ១៩.-**

ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ២០.-**

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩២ ។

**មាត្រា ២១.-**

ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤

## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ២២.-**

ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្មសំអាចជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា២៣ នេះត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២៤.-**

ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ចដល់ទីកន្លែងនោះ ដោយអនុវត្តន៍តាមនីតិវិធី ដែលមានចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។

ខ-ត្រូវធ្វើនៅនឹងកន្លែង នូវកំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-ត្រូវសាកសួរ និងតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។

ឃ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

**មាត្រា ២៦.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ២៧.-**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅតាម មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ២៨.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមសមគំនិត នឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនោះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

**មាត្រា ២៩.-**

កំណត់ហេតុ និងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី ៦

## អវសានបញ្ញត្តិ

**មាត្រា ៣០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន។

**មាត្រា ៣២.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣១

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

## តារាងឧបសម្ព័ន្ធ

## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១-សំណល់សរសៃអំបោះ និងកំទេចក្រណាត់ដែលមានពណ៌ ( ក្នុងករណីយកទៅដុត) ។

២-សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស ។

៣-សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាចសំណល់រាវ និងទឹកល្វ ។

៤-សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម ។

៥-សំណល់ប្លាស្ទិច "ប៉ូលីវីនីក្លរួ" ។

៦-សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល ។

៧-សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីម៉ែប៉ុយទីលីន

៨-សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩-សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០-សំណល់ដែលមានផ្ទុកជាតិបាស

១១-សំណល់លោហៈ និងសមាសធាតុរបស់វារួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម្ញូម (Cd) | ដែក (Fe) | |

១២-លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣-សំណល់អំពូលអគ្គីសនី និងបន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គីសនី

១៤-សំណល់អាគុយ និងថ្មពិល

១៥-សំណល់ថ្នាំលាប និងថ្នាំជ្រលក់ពណ៌ និងសំភារៈវេចខ្ចប់ថ្នាំពណ៌

១៦-សំណល់បានមកពីការផលិត និងការប្រើប្រាស់ទឹកខ្មៅបោះពុម្ព

១៧-សំណល់គ្រឿងផ្ទុះ

១៨-សំណល់ដែលនាំអោយមានការចំលងមេរោគ ឬជំងឺ

១៩-សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសំភារៈវេចខ្ចប់

២០-សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

២១-ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

២២-សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ

២៣-សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤-សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព

២៥-សំណល់ដែលជាសមាសធាតុសរីរាង្គក្លរអរីន

២៦-សំណល់ដែលជាសមាសធាតុស៊ីអានីត

២៧-សំណល់ដែលជាសមាសធាតុអាសបេស្តូស

២៨-សំណល់ដែលជាសមាសធាតុផេណុល ($C_6H_5OH$)

២៩-សំណល់ដែលជាសមាសធាតុអេទែ (R-COO-$R_1$)

៣០-សំណល់ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១-សំណល់ដែលជាសមាសធាតុឌីអុកស៊ីន និងហ្វូរ៉ាន

៣២-សំណល់ធាតុវិទ្យុសកម្ម

៣៣-សារធាតុដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែងពីចំនុចទី១ ដល់ទី៣២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.~**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.~**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ ។

**មាត្រា ៣.~**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"**តំបន់ទឹកសាធារណៈ**" គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ-"**ប្រភពបំពុល**" គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ

គ-"**សំណល់រាវ**" គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ-"**ទឹកលូ**" គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង-"**សំណល់រឹង**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច-"**សំរាម**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ-"**សារធាតុបំពុល**" គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

ជ-"**បរិមាណសារធាតុបំពុល**" គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ-"**សារធាតុប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់
## និងសារធាតុប្រកបដោយគ្រោះថ្នាក់

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។

កំរិតស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៨.-**

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក

សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

**មាត្រា ៩.-**

ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣

## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

**មាត្រា ១០.-**

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១១.-**

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

ក-ប្រភពបំពុលប្រភេទថ្នាក់ទី១ តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។

ខ-ប្រភពបំពុលប្រភេទថ្នាក់ទី២ ចាំបាច់តំរូវអោយមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១២.-**

ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុល ទាំងគំរោងថ្មី និងទាំងគំរោងកំពុងដំណើរការ លើកលែងតែគំរោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុតពីការតំរូវឱ្យសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ។

**មាត្រា ១៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

-អោយបានមុន ៤០ថ្ងៃសំរាប់គំរោងនៅភ្នំពេញ និង ៦០ថ្ងៃ សំរាប់គំរោងនៅតាមខេត្ត ក្រុងនៃការចាប់ផ្តើម

ដំណើរការ សំរាប់ប្រភពបំពុលដែលជាគំរោងថ្មី ។

-អោយបានក្នុងរយៈពេល ៣០ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្ត ក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

**មាត្រា ១៤.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំនត់ដោយក្រសួង បរិស្ថាន ។

**មាត្រា ១៥.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យ សុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

**មាត្រា ១៦.-**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើមដែលបានទទួលការ អនុញ្ញាតពីក្រសួងបរិស្ថានឱ្យបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំនុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួង បរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្ត របស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីមានការជួល ឬកាន់កាប់បន្តនោះ ។

**មាត្រា ១៧.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅឱ្យ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះ យោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្ត ល្មើសធ្ងន់ធ្ងរ និងមាត្រាណាមួយនៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន

**មាត្រា ១៩.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២០.-**

ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២១.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំនូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជូទានបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវ :

ក-ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាតនិងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឱ្យឆ្លើយតបទៅ និងក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ និងក៏រិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

ខ-មានសំភារៈ និងមធ្យោបាយគ្រប់គ្រាន់សំរាប់រារាំង ឬទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈនៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន ។

គ-ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់នូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុលដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវធ្វើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង ។

**មាត្រា ២៤.-**

ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពបំពុលណាមួយ ពុំបានឆ្លើយតបទៅ និងក៏រិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ ឬពុំឆ្លើយតបទៅ និងក៏រិតស្តង់ដារបរិមាណសារធាតុ

បំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់ណាមួយ ប្រសិនបើសកម្មភាពល្មើសនោះមិនទាន់បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូកទី ៥
## ការត្រួតពិនិត្យការបំពុលទឹក
## នៅតាមតំបន់ទឹកសាធារណៈ

### មាត្រា ២៥.-

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹកមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹសាធារណៈ សំរាប់ការពារសុខភាពសាធារណៈមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យនេះ ។

### មាត្រា ២៦.-

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

### មាត្រា ២៧.-

ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៨.-

ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៩.-

ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កអោយមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់

វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី ៦

## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ៣០.~**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមនីតិវិធីដូចចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួន នៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុលដើម្បីអធិការកិច្ច យកគំរូតាង ឬពិនិត្យកត់ត្រា

ខ-កំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣១.~**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កឱ្យមានគ្រោះថ្នាក់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិចូលធ្វើអធិការកិច្ច នៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣២.~**

ក្នុងករណីមានឧប្បទ្វវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្វវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពតិមានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣.~**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឱ្យមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

ខ-ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្សសត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៧

## ទោសបញ្ញត្តិ

### មាត្រា ៣៤.-

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

### មាត្រា ៣៥.-

កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

### មាត្រា ៣៦.-

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិត និងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨
## អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្ដីជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

## តារាងឧបសម្ព័ន្ធ ១

## ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

១-សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គអាឡូសែនទាំងនោះនៅក្នុងបរិស្ថានទឹក

២-សមាសធាតុសរីរាង្គផូស្វ័រ

៣-សមាសធាតុសរីរាង្គទីន

៤-សារធាតុដែលបង្កអោយមានជំងឺមហារីក

៥-បារត និងសមាសធាតុរបស់វា

៦-កាត់ម្ញូម និងសមាសធាតុរបស់វា

៧-សមាសធាតុប្រេងអសរីរាង្គដែលមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

៨-សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតនៅលើផ្ទៃទឹក រឺលិចក្នុងទឹកហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក

៩-សារធាតុវិទ្យុសកម្ម

១០-លោហៈ និងសមាធាតុ របស់វាដូចជា :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |

១១-សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យូម

១២-សមាសធាតុអសរីរាង្គផូស្វ័រ

១៣-សមាសធាតុប្រេងជាអសរីរាង្គបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

១៤-សមាសធាតុស៊ីអានីត និងភ្លុយអរ

១៥-សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែន ដូចជា អាម៉ូញ៉ាក់ នីទ្រីត ។ល។

## តារាងឧបសម្ព័ន្ធ ២

កម្រិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅ

ក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអាចអនុញ្ញាតឱ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈនិងលូ |
| 1 | សីតុណ្ហភាព | $^{0}C$ | <45 | <45 |
| 2 | pH | | 6-9 | 5-9 |
| 3 | $BOD_5$ | mg/l | <30 | <80 |
| 4 | COD | mg/l | <50 | <100 |
| 5 | សារធាតុរឹងអណ្តែតក្នុងទឹក | mg/l | <60 | <120 |
| 6 | សារធាតុរឹងដែលរលាយក្នុងទឹក | mg/l | <1000 | <2000 |
| 7 | ប្រេង ឬខ្លាញ់ | mg/l | <5.0 | <15 |
| 8 | សាប៊ូ | mg/l | <5.0 | <15 |
| 9 | ផេណុល | mg/l | <0.1 | <1.2 |
| 10 | នីត្រាត | mg/l | <10 | <20 |
| 11 | ក្លរក្នុងទំរង់សេរី | mg/l | <1.0 | <2.0 |
| 12 | ក្លរជាអ៊ីយ៉ុង | mg/l | <500 | <700 |
| 13 | ស៊ុលផាត | mg/l | <300 | <500 |
| 14 | ស៊ុលហ្វីត | mg/l | <0.2 | <1.0 |
| 15 | ផូស្វាត | mg/l | <0.3 | <6.0 |
| 16 | ស៊ីអានីត ($CN^{-1}$) | mg/l | <0.2 | <1.5 |
| 17 | បារ្យ៉ូម (Ba) | mg/l | <4.0 | <7.0 |
| 18 | អាសេនិច (As) | mg/l | <0.10 | <1.0 |
| 19 | សំណប៉ាហាំង(Sn) | mg/l | <2.0 | <8.0 |
| 20 | ដែក (Fe) | mg/l | <1.0 | <20 |
| 21 | បរ(B) | mg/l | <1.0 | <5.0 |
| 22 | ម៉ង់កាណែស(Mn) | mg/l | <1.0 | <5.0 |
| 23 | កាត់ម្ញូម(Cd) | mg/l | <0.1 | <0.5 |

| | | | | |
|---|---|---|---|---|
| 24 | ក្រូម$(Cr)^{+3}$ | mg/l | <0.2 | <1.0 |
| 25 | ក្រូម$(Cr)^{+6}$ | mg/l | <0.05 | <0.5 |
| 26 | ទង់ដែង(Cu) | mg/l | <0.2 | <1.0 |
| 27 | សំណ(Pb) | mg/l | <0.1 | <1.0 |
| 28 | បារត(Hg) | mg/l | <0.002 | <0.05 |
| 29 | នីកែល(Ni) | mg/l | <0.2 | <1.0 |
| 30 | សេលេញ៉ូម(Se) | mg/l | <0.05 | <0.5 |
| 31 | ប្រាក់(Ag) | mg/l | <0.1 | <0.5 |
| 32 | ស័ង្កសី(Zn) | mg/l | <1.0 | <3.0 |
| 33 | ប៉ូលីបដែន(Mo) | mg/l | <0.1 | <1.0 |
| 34 | អាម៉ូញាក់$(NH_3)$ | mg/l | <5.0 | <7.0 |
| 35 | អុកស៊ីសែនដែលរលាយក្នុងទឹក | mg/l | >2.0 | >.1.0 |
| 36 | ប៉ូលីក្លរ៉ូ បីផេនីល(PCB) | mg/l | <0.003 | <0.003 |
| 37 | កាល់ស្យូម(Ca) | mg/l | <150 | <200 |
| 38 | ម៉ាញ៉េស្យូម(Mg) | mg/l | <150 | <200 |
| 39 | កាបូនតេត្រាក្លរ | mg/l | <3 | <3 |
| 40 | អ៊ិចសាក្លរបង់សែន | mg/l | <2 | <2 |
| 41 | ដេដេតេ | mg/l | <1,3 | <1,3 |
| 42 | អង់ឌ្រីន | mg/l | <0,01 | <0,01 |
| 43 | ឌីអលឌ្រីន | mg/l | <0,01 | <0,01 |
| 44 | អេនឌ្រីន | mg/l | <0,01 | <0,01 |
| 45 | អ៊ីសូឌ្រីន | mg/l | <0,01 | <0,01 |
| 46 | ពែក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 47 | អ៊ិចសាក្លរប៊ុយតាឌីអែន | mg/l | <3 | <3 |
| 48 | ក្លរហ្វម | mg/l | <1 | <1 |
| 49 | 1,2 ឌីក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 50 | ទ្រីក្លរអេទីឡែន | mg/l | <1 | <1 |
| 51 | ទ្រីក្លរបង់សែន | mg/l | <2 | <2 |
| 52 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | mg/l | <2 | <2 |

***កំណត់សំគាល់*** : ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការរៀបចំក៏រិតកំណត់ស្តង់ដារថ្នាំពុលកសិកម្ម ដែលបញ្ចេញពីប្រភពបំពុល ។

## តារាងឧបសម្ព័ន្ធ ៣

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយមានការសុំអនុញ្ញាតិពីក្រសួងបរិស្ថាន
មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ

| ល.រ | ប្រភេទប្រភពបំពុល | កំរិតថ្នាក់ប្រភេទ |
|---|---|---|
| 1 | -ទីតាំងផលិតអាហារ និងសាច់កំប៉ុង | ទី១ |
| 2 | -ទីតាំងផលិតបន្លែ និងផ្លែឈើកំប៉ុង | ទី១ |
| 3 | -ទីតាំងកែច្នៃផលនេសាទ | ទី១ |
| 4 | -ទីតាំងក្លាសេ និងបង្កក | ទី១ |
| 5 | -ទីតាំងផលិតម្សៅមី | ទី១ |
| 6 | -ទីតាំងផលិតស្ករស | ទី១ |
| 7 | -ទីតាំងផលិតទឹកស្អាត | ទី១ |
| 8 | -ទីតាំងផលិតស្នូនរបស់ប្រើប្រាស់ពីដី | ទី១ |
| 9 | -ទីតាំងផលិតភេសជ្ជៈ និងស្រាបៀរ | ទី១ |
| 10 | -ទីតាំងផលិតអាល់កុល និងស្រា | ទី១ |
| 11 | -ទីតាំងផលិតចំណីសត្វ | ទី១ |
| 12 | -ទីតាំងផលិតប្រេង និងខ្លាញ់ | ទី១ |
| 13 | -ទីតាំងផលិតជំបែ និងមេស្រា | ទី១ |
| 14 | -ទីតាំងផលិតនំ និងស្ករគ្រាប់ | ទី១ |
| 15 | -ទីតាំងផលិតបារី | ទី១ |
| 16 | -ទីតាំងកាត់ដេរគ្មានក្រឡុកបោក | ទី១ |
| 17 | -សណ្ឋាគារ | ទី១ |
| 18 | -ភោជនីយដ្ឋាន | ទី១ |
| 19 | -ទីតាំងកសិដ្ឋានចិញ្ចឹមសត្វ | ទី១ |
| 20 | -ទីតាំងសត្តឃាត | ទី១ |
| 21 | -ទីតាំងយានដ្ឋាន និងកន្លែងលាងរថយន្ត | ទី១ |
| 22 | -ទីតាំងមជ្ឈមណ្ឌលលក់ដុំ និងទីផ្សារ | ទី១ |
| 23 | -ទីតាំងមន្ទីរពេទ្យ និងសម្ភព | ទី១ |
| 24 | -ទីតាំងផលិតរបស់ផ្លាស្ទិក-កៅស៊ូកង់ | ទី១ |
| 25 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវលំនៅស្ថាន | ទី១ |
| 26 | -ទីតាំងផលិតជ័រកាវ | ទី១ |
| 27 | -ទីតាំងបង្អក និងកែច្នៃជ័រក្រែប | ទី១ |

| | | |
|---|---|---|
| 28 | -ទីតាំងផលិតកែវ-ដប | ទី១ |
| 29 | -ទីតាំងផលិតស៊ីម៉ងត៍ | ទី១ |
| 30 | -ការដ្ឋានយកថ្ម | ទី១ |
| 31 | -ការដ្ឋានយកគ្រួស | ទី១ |
| 32 | -ទីតាំងផលិតក្តារបន្ទះ | ទី១ |
| 33 | -ទីតាំងផលិត ឬកែច្នៃជីគីមីកសិកម្ម | ទី១ |
| 34 | -ទីតាំងលាយបេតុង និងផលិតសំភារៈសំណង់ជាបេតុង | ទី១ |
| 35 | -នាំវាំដឹកសារធាតុភាវ៍ | ទី២ |
| 36 | -ទីតាំងផលិតអាសេទីឡែន | ទី២ |
| 37 | -ទីតាំងសំលាប់ស្បែក | ទី២ |
| 38 | -ទីតាំងផលិតសាប៊ូ និងផលិតមេសាប៊ូ | ទី២ |
| 39 | -ទីតាំងស្ថានីយ៍ និងឃ្លាំងស្តុកប្រេងឥន្ធនៈ | ទី២ |
| 40 | -ទីតាំងកប់ ឬចាក់ចោលសំណល់រឹង | ទី២ |
| 41 | -ទីតាំងតំបាញ ឬជ្រលក់ពណ៌ | ទី២ |
| 42 | -ទីតាំងកាត់ដេរមានក្រឡុកបោក | ទី២ |
| 43 | -ទីតាំងផលិតក្រដាស និងម្សៅក្រដាស | ទី២ |
| 44 | -ទីតាំងបោះពុម្ពទស្សនាវដ្តី និងឯកសារផ្សេងៗ | ទី២ |
| 45 | -ទីតាំងលាងសំអាតត្បូងថ្ម និងរ៉ែ | ទី២ |
| 46 | -ទីតាំងផលិតថ្មពិល —អាគុយ | ទី២ |
| 47 | -ទីតាំងផលិតថ្នាំពណ៌អសរីរាង្គ | ទី២ |
| 48 | -ទីតាំងផលិត និងតំឡើងគ្រឿងអេឡិចត្រូនិច | ទី២ |
| 49 | -ទីតាំងផលិតជ័រក្រាលថ្ន | ទី២ |
| 50 | -ទីតាំងផលិតហ្វីលថត និងថ្នាំលាងហ្វីល | ទី២ |
| 51 | -ទីតាំងផលិតសារធាតុគីមីសរីរាង្គ | ទី២ |
| 52 | -ទីតាំងផលិតឱសថ | ទី២ |
| 53 | -ទីតាំងផលិតសារធាតុសរីរាង្គប្រើសំរាប់លាង | ទី២ |
| 54 | -ទីតាំងផលិត និងលាយថ្នាំពុលកសិកម្ម | ទី២ |
| 55 | -ទីតាំងផលិត ចំរាញ់ប្រេងកាត | ទី២ |
| 56 | -ទីតាំងផលិតដែក និងដែកថែប | ទី២ |
| 57 | -ទីតាំងផលិតលោហៈធាតុដែលមិនមែនដែក | ទី២ |
| 58 | -ទីតាំងផលិតរបស់របរលោហៈ | ទី២ |

| | | |
|---|---|---|
| 59 | -ទីតាំងក្រូមេ៉របស់លោហៈធាតុដែលមិនមែនដែក | ទី២ |
| 60 | -ទីតាំងដុត រឺកែច្នៃសំណល់រឹង | ទី២ |
| 61 | -ទីតាំងប្រព្រឹត្តកម្មសំអាតដី | ទី២ |
| 62 | -ទីតាំងកែច្នៃសំណល់ប្រេង | ទី២ |
| 63 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវឧស្សាហកម្ម | ទី២ |
| 64 | -មន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលស្រាវជ្រាវ | ទី២ |
| 65 | -រោងចក្រអគ្គិសនី | ទី២ |
| 66 | -ទីតាំងកែច្នៃឈើ | ទី២ |
| 67 | -ការដ្ឋានស្រែបង្គា | ទី២ |

## តារាងឧបសម្ព័ន្ធ ៤

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក

### ១.សំរាប់ទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | $BOD_5$ | mg/l | 1-10 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 25-100 |
| 4 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <5000 |

### ២.សំរាប់បឹង និងអាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | COD | mg/l | 1-8 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 1-15 |
| 4 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 6 | អាសូតសរុប(Total Nitrogen) | mg/l | 0,1-0,6 |
| 7 | ផូស្វរសរុប(Total Phosphorus) | mg/l | 0,005-0,05 |

### ៣.សំរាប់ទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 7,0-8,3 |
| 2 | COD | mg/l | 2-8 |
| 3 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 4 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 5 | សមាសធាតុប្រេង(Oil content) | mg/l | 0 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,2-1,0 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,02-0,09 |

# តារាងឧបសម្ព័ន្ធ ៥

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់ការពារសុខភាពសាធារណៈ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | កាបូនតេត្រាក្លួរ | μg/l | <12 |
| 2 | អ៊ិចសាក្លូរបង់សែន | μg/l | <0,03 |
| 3 | ដេដេតេ | μg/l | <10 |
| 4 | អង់ឌ្រីន | μg/l | <0,01 |
| 5 | ឌីអលឌ្រីន | μg/l | <0,01 |
| 6 | អេនឌ្រីន | μg/l | <0,005 |
| 7 | អ៊ីសូឌ្រីន | μg/l | <0,005 |
| 8 | ពែក្លួរអេទីឡែន | μg/l | <10 |
| 9 | អ៊ិចសាក្លួរប៊ុយតាឌីអែន | μg/l | <0,1 |
| 10 | ក្លួរហ្វម | μg/l | <12 |
| 11 | 1,2ឌីក្លួរអេទីឡែន | μg/l | <10 |
| 12 | ទ្រីក្លួរអេទីឡែន | μg/l | <10 |
| 13 | ទ្រីក្លួរបង់សែន | μg/l | <0,4 |
| 14 | អ៊ិចសាក្លួរស៊ីក្លូអ៊ិចសែន | μg/l | <0,05 |
| 15 | បង់សែន | μg/l | <10 |
| 16 | តេត្រាក្លួរអេទីឡែន | μg/l | <10 |
| 17 | កាត់ម្ញូម | μg/l | <1 |
| 18 | បារតសរុប | μg/l | <0,5 |
| 19 | បារតសរីរាង្គ | μg/l | 0 |
| 20 | សំណ | μg/l | <10 |
| 21 | ក្រូមវ៉ាឡង់ ៦ | μg/l | <50 |
| 22 | អាសេទិច | μg/l | <10 |
| 23 | សេលេញ៉ូម | μg/l | <10 |
| 24 | ប៉ូលីក្លរ៉ូ ប៊ីផេនីល(PCB) | μg/l | 0 |
| 25 | ស៊ីអានីត ($CN^{+}$) | μg/l | <0,005 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៤២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០។

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹកអ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ទនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥.-**

ក៏រិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងក៏រិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦.-**

ក្នុងករណីចាំបាច់ ក៏រិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ នឹងត្រូវពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តងតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.-**

ក៏រិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងក៏រិតកំណត់ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨.-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩.-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំលេង ដែលមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ១០.-**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ួប្រហើរ ត្រូវឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងឧសម្ព័ន្ធ ៨ ។

**មាត្រា ១១.-**

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

**មាត្រា ១២.-**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

## ជំពូកទី ៣
## ការសុំអនុញ្ញាត

**មាត្រា ១៣.-**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១៤.-**

ការសុំអនុញ្ញាតនាំចូលសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណបង់សែន ឬអ៊ីដ្រូកាបួប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

**មាត្រា ១៥.-**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគំរោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ។

**មាត្រា ១៦.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុន ៤០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅភ្នំពេញ
- អោយបានមុន ៦០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅតាមខេត្ត ក្រុង ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧.-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩.-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង ។

**មាត្រា ២០.-**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាងដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១.-**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំនត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំលេង ដើម្បីឱ្យឆ្លើយតបទៅនឹងកំណត់កំរិតស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែ ម្តង ។
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពណាមួយពុំបានឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ នៃអនុក្រឹត្យនេះក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្ដោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន ។

## ជំពូកទី ៥
## ការត្រួតពិនិត្យគុណភាពខ្យល់

**មាត្រា ២៦.-**

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា ។

**មាត្រា ២៧.-**

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨.-**

ក្នុងករណីរកឃើញថា តំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កអោយមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ ។

## ជំពូកទី ៦
## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ២៩.-**

នៅពេលចុះធ្វើអធិការកិច្ចតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថានត្រូវអនុវត្តតាមនីតិវិធីដូចមានចែងខាង ក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬកន្លែងប្រភពបំពុលដើម្បីធ្វើអធិការកិច្ចយកគំរូតាង ឬពិនិត្យកំណត់ត្រា ។

ខ-កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ចដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់ពត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើជាវត្ថុតាង ។

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័របង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣១.-**

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំលេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពតិមានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូក ទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤.-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំង

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ១

## កំរិតកំណត់ស្តង់ដារគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល១ម៉ោង ជាមធ្យម mg/m3 | រយៈពេល៨ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល២៤ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ១ឆ្នាំ ជាមធ្យម$mg/m^3$ |
|---|---|---|---|---|---|
| 1 | កាបូនឌីអុកស៊ីត CO | 40 | 20 | | |
| 2 | អាសូតឌីអុកស៊ីត$NO_2$ | 0,3 | | 0,10 | |
| 3 | ស្ពាន់ធ័រឌីអុកស៊ីត$SO_2$ | 0,5 | | 0,30 | 0,10 |
| 4 | អូសូន $0_3$ | 0,2 | | | |
| 5 | សំណ Pb | | | 0,005 | |
| 6 | សារធាតុរឹងអណ្តែត ក្នុងខ្យល់ TSP | | | 0,33 | 0,10 |

**កំណត់សំគាល់**

-កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។

-វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

-TSP Total Suspended Particulate

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ២

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់

| ល.រ | ឈ្មោះសារធាតុគីមី | រូបមន្តគីមី | កំរិតអតិបរមា ($mg/m^3$) |
|---|---|---|---|
| 1 | អានីលីន | $C_6H_5NH_2$ | 0,03 |
| 2 | អាម៉ូញាក់ | $NH_3$ | 0,2 |
| 3 | អាស៊ីត អាសេទិច | $CH_3COOH$ | 0,2 |
| 4 | អាស៊ីតស៊ុលផួរិច | $H_2SO_4$ | 0,3 |
| 5 | អាស៊ីតនីទ្រិច | $HNO_3$ | 0,4 |
| 6 | បង់សែន | $C_6H_6$ | 1 |
| 7 | បង់ស៊ីឌីន | $NH_2C_6H_4C_6H_4NH_2$ | គ្មាន |
| 8 | កាបូនឌីស៊ុលហ្វិត | $CS_2$ | 0,02 |
| 9 | ក្លរ៉ូហ្វម | $CHCL_3$ | 0,01 |
| 10 | កាបូនតេត្រាក្លរិត | $CCL_4$ | 3 |
| 11 | ភាគល្អិតដែលមាន asbestor | | គ្មាន |
| 12 | ដេ ដេ តេ | $C_8H_{11}CL$ | 0,5 |
| 13 | ហ្វម៉ល់ដេអ៊ីត | $HCOH$ | 0,012 |
| 14 | អ៊ីដ្រូសែន អាសេនិច | $AsH_3$ | 0,002 |
| 15 | អ៊ីដ្រូសែន ស៊ីអានីត | $HCN$ | 0,01 |
| 16 | អ៊ីដ្រូសែន ភ្លុយអរិច | $HF$ | 0,002 |
| 17 | អ៊ីដ្រូសែនស៊ុលហ្វិត | $H_2S$ | 0,001 |
| 18 | ផេណុល | $C_6H_5OH$ | 0,01 |
| 19 | ស៊ីរេន | $C_6H_5CHCH_2$ | 0,003 |
| 20 | តេត្រាក្លរូអេទីឡែន | $C_2Cl_4$ | 0,1 |
| 21 | សំណតេត្រាអេទិល | $Pb(C_2H_5)_4$ | 0,005 |
| 22 | ទ្រីក្លរូអេទីឡែន | $CLCHCCL_2$ | 0,2 |
| 23 | តូលុយអេន | $C_9H_5CH_3$ | 0,4 |
| 24 | វិនិក្លរួ | $CLCHCH_2$ | 0,05 |

| | | | |
|---|---|---|---|
| 25 | អាសេទិច ( សមាសធាតុអសរីរាង្គ) | As | 0,00001 |
| 26 | កាត់ម្ញូម( សមាសធាតុលោហៈ និងអុកស៊ីត) | Cd | 0,003 |
| 27 | ក្រូម( លោហៈ និងសមាសធាតុ) | Cr | 0,0015 |
| 28 | នីកែល ( លោហៈ និងសមាសធាតុ) | Ni | 0,0001 |
| 29 | បារត( លោហៈ និងសមាសធាតុ) | Hg | 0,0001 |
| 30 | ប្រេងសាំង | | 5 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់ ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៣

# កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញ ពីប្រភពអចល័ត ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត | កំរិតអតិបរមានៃការបញ្ចេញ |
|---|---|---|
| 1 | ភាគល្អិតនៅក្នុងផ្សែង បញ្ចេញពីប្រភព : | |
| | -ឡដុត | 400 $mg/m^3$ |
| | -រោងចក្រផលិតលោហធាតុ | 400 $mg/m^3$ |
| | -រោងចក្រស៊ីម៉ង់ត៍ កំបោរ និងថ្មស្អុយ | 400 $mg/m^3$ |
| | -រោងចក្របេតុងអាស្ទាល់ | 500 $mg/m^3$ |
| 2 | ធូលី ដែលមានភ្ជាប់ : | |
| | -សារធាតុ ស៊ីលីកាត $Si0_2$ | 100 $mg/m^3$ |
| | -សារធាតុ Asbetos | 27 $\mu g/m_3$ |
| | -សារធាតុគីមីអសរីរាង្គ : | |
| 3 | អាលុយមីញ៉ូម AL | (ធូលី) ៣00 $mg/m^3$ .·(Al) 50 $mg/m^3$ |
| 4 | អាម៉ូញាក់ $NH_3$ | 100 $mg/m^3$ |
| 5 | អាង់ទីម៉ូន Sb | 25 $mg/m^3$ |
| 6 | អាសេទិច As | 20 $mg/m_3$ |
| 7 | បេរីល្យ៉ូម Be | 10 $\mu g/m_3$ |
| 8 | ក្លរ CL | 20 $mg/m_3$ |
| 9 | អ៊ីដ្រូសែនក្លរីត HCL | 200 $mg/m_3$ |
| 10 | អ៊ីដ្រូសែនភ្លុយអរីត HF | 10 $mg/m_3$ |
| 11 | អ៊ីដ្រូសែនស៊ុលភីត $H_2F$ | 2 $mg/m_3$ |
| 12 | កាត់ម្យ៉ូម Cd | 1 $mg/m_3$ |
| 13 | ទង់ដែង Cu | (ធូលី) ៣00$mg/m_3$ (Cu) 20 $mg/m_3$ |
| 14 | សំណ Pb | (ធូលី) ១00 $mg/m_3$ (Pb) 30 $mg/m_3$ |
| 15 | ស័ង្កសី Zn | 30 $mg/m_3$ |
| 16 | បារត Hg | 0,1 $mg/m_3$ |
| 17 | កាបូនម៉ូណូអុកស៊ីត Co | 1000 $mg/m_3$ |

| | | |
|---|---|---|
| 18 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 500 $mg/m^3$ |
| 19 | អាសូតអុកស៊ីត( គ្រប់ប្រភេទ) NOx | 1000 $mg/m^3$ |
| 20 | អាសូតអុកស៊ីត( ចេញពីការផលិតអាស៊ីត)NOx | 2000 $mg/m^3$ |
| 21 | អាស៊ីតស៊ុលផួរិច $H_2SO_4$ | 35 $mg/m^3$ |
| 22 | អាស៊ីតនីទ្រិច $HNO_3$ | 70 $mg/m^3$ |
| 23 | ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$) | 35 $mg/m^3$ |
| 24 | អាស៊ីតផូស្វ័រិច ($H_3PO_4$) | 3 $mg/m^3$ |
| | <u>សារធាតុគីមីសរីរាង្គ</u> : | |
| 25 | អាសេទីឡែនតេត្រាប្រូមីត $CHBr_2CHBr_2$ | 14 $mg/m^3$ |
| 26 | អាក្រូឡេអ៊ិន $CH_2CHCHO$ | 1,2 $mg/m^3$ |
| 27 | អានីលីន $C_6H_5NH_2$ | 19 $mg/m^3$ |
| 28 | បង់ស៊ីឌីន $NH_2C_6H_4C_6H_4NH_2$ | None |
| 29 | បង់សែន $C_6H_6$ | 80 $mg/m^3$ |
| 30 | ក្លរូបង់ស៊ីល $C_6H_5CH_2Cl$ | 5 $mg/m^3$ |
| 31 | ប៊ុយទីលឡាមីន $CH_3(CH_2)_2CH_2NH_2$ | 15 $mg/m^3$ |
| 32 | ក្រេសូល (O-,m-,P-) $CH_3C_6H_4OH$ | 22 $mg/m^3$ |
| 33 | ក្លរូបង់សែន $C_6H_5Cl$ | 350 $mg/m^3$ |
| 34 | ក្លរ៉ូហ្វម $CHCl_3$ | 240 $mg/m^3$ |
| 35 | ក្លរ៉ូពីគ្រីន $CCl_3NO_2$ | 0,7 $mg/m^3$ |
| 36 | O-ឌីក្លរូបង់សែន $C_6H_4Cl_2$ | 300 $mg/m^3$ |
| 37 | 1.1-ឌីក្លរូអេតាន $CHCl_2CH_3$ | 400 $mg/m^3$ |
| 38 | ឌីមេទីលស៊ុលហ្វាត $(CH_3)_2SO_4$ | 0,5 $mg/m^3$ |
| 39 | ឌីមេទីលអ៊ីដ្រាហ៊ី្សន $(NH_3)_2NNH_2$ | 1 $mg/m^3$ |
| 40 | ឌីនីត្រូបង់សែន (O-,m-,P-) $C_6H_4(NO_2)_2$ | 1 $mg/m^3$ |
| 41 | អេទីឡែនឌីអាមីន $NH_2CH_2$-$CH_2NH_2$ | 30 $mg/m^3$ |
| 42 | អេទីឡែន ក្លរូអ៊ីឌ្រីន $CH_2ClCH_2OH$ | 16 $mg/m^3$ |
| 43 | អេទីឡែន អុកស៊ីត $CH_2OCH_2$ | 20 $mg/m^3$ |
| 44 | ហ្វ័រម៉ាល់ដេអ៊ីដ HCHO | 6 $mg/m^3$ |
| 45 | មេទីលអាគ្រីឡាត $CH_2CHCOOCH_3$ | 35 $mg/m^3$ |
| 46 | មេតាណុល $CH_3OH$ | 260 $mg/m^3$ |
| 47 | មេទីលប្រូមីត $CH_3Br$ | 80 $mg/m^3$ |

| | | |
|---|---|---|
| 48 | ម៉ូណូមេទីលអានីលីន $C_6H_5NHCH_3$ | 9 mg/m$^3$ |
| 49 | នីត្រូបង់សែន $C_6H_5NO_2$ | 5 mg/m$^3$ |
| 50 | នីត្រូគ្លីសេរីន $C_3H_5(NO_2)_3$ | 5 mg/m$^3$ |
| 51 | នីត្រូតូលូអែន $NO_2C_6H_4CH_3$ | 30 mg/m$^3$ |
| 52 | ផេណុល $C_6H_5OH$ | 19 mg/m$^3$ |
| 53 | ផេនីលអ៊ីដ្រាហ៊្សីន $C_6H_5NHNH_2$ | 22 mg/m$^3$ |
| 54 | ពីរីនឌីន $C_5H_5N$ | 30 mg/m$^3$ |
| 55 | ពីរ៉ែន $C_{16}H_{10}$ | 15 mg/m$^3$ |
| 56 | គ្វីណូន $C_6H_4O_2$ | 0,4 mg/m$^3$ |
| 57 | ស្ទីរ៉ែន $C_6H_5CHCH_2$ | 420 mg/m$^3$ |
| 58 | 1,1,2,2-តេត្រាក្លរូអេតាន $Cl_2HCCHCl_2$ | 35 mg/m$^3$ |
| 59 | តេត្រាក្លរូមេតាន $CCl_4$ | 65 mg/m$^3$ |
| 60 | តូលូអែន $C_6H_5CH_3$ | 750 mg/m$^3$ |
| 61 | តេត្រានីត្រូមេតាន $C(NO_2)_4$ | 8 mg/m$^3$ |
| 62 | តូលូអ៊ីឌីន $CH_3C_6H_4NH_2$ | 22 mg/m$^3$ |
| 63 | តូលូអែន 2.4- ឌីអ៊ីសូស៊ីអាណាត $CH_3C_6H_3(NCO)_2$ | 0,7 mg/m$^3$ |
| 64 | ទ្រីក្លរូអេទីឡែន $ClCHCCl_2$ | 110 mg/m$^3$ |
| 65 | ស៊ីលីឌីន $(CH_3)_2C_6H_3NH_2$ | 50 mg/m$^3$ |
| 66 | វីនីលក្លរីត $CH_2CHCl$ | 150 mg/m$^3$ |

## កំណត់សំគាល់

ក៏រិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត

| ល.រ | ប្រភេទយានយន្ត | ប្រភេទ ប្រេងឥន្ធនៈ | កំរិតនៃការបញ្ចេញ | | | | |
|---|---|---|---|---|---|---|---|
| | | | CO (%) | | HC(ppm) | | ផ្សែងខ្មៅ % |
| | | | ក | ខ | ក | ខ | |
| 1 | ទោចក្រយានយន្តដែលមានចំហេះ២វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 3000 | |
| 2 | ទោចក្រយានយន្តដែលមានចំហេះ៤វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 2400 | |
| 3 | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | 4,5 | 4 | 1200 | 800 | |
| 4 | យានយន្តគ្រប់ប្រភេទ | ប្រេងម៉ាស៊ូត | | | | | ៥០ |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញឧស្ម័នពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

ក-គឺសំដៅលើយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេល ៥ឆ្នាំ គិតពីឆ្នាំដែលផលិត ។

ខ-គឺសំដៅទៅលើយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេល ប្រាំឆ្នាំដំបូងគិតចាប់ពីឆ្នាំដែលផលិត ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៥

# កំរិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំលេងនៅលើផ្លូវសាធារណៈ ពីប្រភពយានយន្ត

| ល.រ | **ប្រភេទយានយន្ត** | កំរិតអតិបរមា (dB (A)) |
|---|---|---|
| 1 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)< 125 $Cm^3$ | 85 |
| 2 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)≥ 125 $Cm^3$ | 90 |
| 3 | **ត្រីចក្រយានយន្ត** | 90 |
| 4 | រថយន្តធុនតូច រថយន្តដឹកអ្នកដំណើរ ១២ នាក់ | 80 |
| 5 | រថយន្តដឹកអ្នកដំណើរ ≥ ១២ នាក់ | 85 |
| 6 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ < 3,5 តោន | 85 |
| 7 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ > 3,5 តោន | 88 |
| 8 | រថយន្តដឹកទំនិញដែលមានកំលាំង ≥ 150 kw | 89 |
| 9 | គ្រឿងយន្តផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | 91 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតបញ្ចេញសំលេងពីប្រភពយានយន្តគ្រប់ប្រភេទ ដែលកំពុងធ្វើចរាចរលើផ្លូវសាធារណៈ ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៦

## កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់ សាធារណៈ និងតំបន់លំនៅដ្ឋាន (dB(A))

| ល.រ | **ទីតាំង** | **អំឡុងពេល** | | |
|---|---|---|---|---|
| | | ពីម៉ោង ៦ព្រឹកដល់ ម៉ោង ១៨ល្ងាច | ពីម៉ោង ១៨ល្ងាចដល់ ម៉ោង ២២យប់ | ពីម៉ោង២២យប់ ដល់ម៉ោង ៦ព្រឹក |
| 1 | តំបន់ស្ងប់ស្ងៀម<br>-មន្ទីរពេទ្យ<br>-បណ្ណាល័យ<br>សាលារៀន<br>មតេយ្យសាលា | 45 | 40 | 35 |
| 2 | តំបន់លំនៅដ្ឋាន<br>-សណ្ឋាគារ ទីកន្លែង រដ្ឋបាល<br>-ភូមិគ្រឹះ ផ្ទះល្វែង | 60 | 50 | 45 |
| 3 | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចំរុះ | 70 | 65 | 50 |
| 4 | ឧស្សាហកម្មធន់ស្រាល លាយចំរុះ នៅក្នុងតំបន់លំនៅដ្ឋាន | 75 | 70 | 50 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

# កម្រិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេង

# ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង (dB(A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75<br>80<br>85<br>90<br>95<br>100<br>105<br>110<br>115 | 32<br>16<br>8<br>4<br>2<br>1<br>0,5<br>0,25<br>0,125 | ត្រូវផ្តល់ឧបករណ៏ការពារត្រចៀកដល់អ្នកបំរើការដែលធ្វើការនៅកន្លែងមានសំលេងលើសពី 80dB (A) |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៧

## កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន

## និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម

| ល.រ | សារធាតុចំហេះ | ស្ពាន់ធ័រ(S) | សណ(Pb) | បង់សែន | អ៊ីដ្រូកាប៊ួប្រហើរ |
|---|---|---|---|---|---|
| 1 | ប្រេងខ្មៅ | 1,0% | | | |
| 2 | ប្រេងម៉ាស៊ូត | 0,2% | | | |
| 3 | ប្រេងសាំង | | 0,15 ក្រាម/លីត្រ | 3,5% | 50% |
| 4 | ធ្យូងថ្ម | 1,5% | | | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ត្រួតពិនិត្យជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាតអោយមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **សុខ ពេញវុធ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ៩ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ៖ ០២០ ផ.ក

# ផែនការណែនាំ
## ស្តីពី
## ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ, ឃុំមានសុវត្ថិភាព"

សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងទៀតមានការរីកចំរើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីយើងមានសន្តិភាព ស្ថេរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឲ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ។

នាឱកាសមិទ្ទីញរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ជាច្រើន ដែលក្នុងនោះបានកំណត់យកគោលការណ៍កសាងភូមិ, **ឃុំមានសុវត្ថិភាព** ដើម្បីលើកកំពស់ និងជំរុញចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅគ្រប់ពេល និងគ្រប់ច្រកល្ហក ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លានេះ ក្រសួងមហាផ្ទៃបានកំណត់យក**ភូមិ, ឃុំមានសុវត្ថិភាព** ធ្វើជាគោលនយោបាយអាទិភាពមួយសំរាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឲ្យបានគត់មត់ល្អនៅគ្រប់ភូមិ, ឃុំទូទាំងប្រទេស ។

ដើម្បីអនុវត្តឲ្យបានជោគជ័យគោលនយោបាយខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំចាត់តាំងអនុវត្ត ដែលមានខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

### I-<u>គោលបំណង និងសំណូមពរ ៖</u>

១-បន្តកសាង និងពង្រឹងសេចក្តីសុខសុវត្ថិភាព ជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ, ឃុំ, សង្កាត់ ទូទាំង

ព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រឲ្យកាន់តែបានល្អប្រសើរថែមទៀត ។

២-បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្ត **គោលនយោបាយ ភូមិ, ឃុំមានសុវត្ថិភាព ។**

**II-<u>លក្ខណៈសម្បត្តិ ភូមិ, ឃុំមានសុវត្ថិភាព</u>**

***ភូមិ, ឃុំមានសុវត្ថិភាព គឺភូមិ, ឃុំដែលមានលក្ខណៈសម្បត្តិ ៥យ៉ាង ដូចខាងក្រោម៖***

១-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២-គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣-គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤-គ្មានក្មេងទំនើង

៥-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។

**III-<u>វិធានការ និងផែនការសកម្មភាព</u>**

**ក-<u>វិធានការ៖</u>**

១-ចាត់វិធានការលុបបំបាត់ឲ្យបានបទល្មើសលួច ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការជំនាញ វិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន ។

២-ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឲ្យបានការផលិត ការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ, ឃុំ, សង្កាត់ ដោយអនុវត្តតាមផែនការណែនាំលេខ ០៥២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងជាពិសេសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ចាត់វិធានការលុបបំបាត់រាល់អំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឲ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សា (<u>ឯកសារយោង ផែនការសកម្មភាពលេខ ០២៣ ផ.ក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និង</u>

ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ) ដោយអនុវត្តតាមច្បាប់ដែលមានជាធរមានឲ្យបានម៉ឺងម៉ាត់ ។

៤-ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ (ឯកសារយោង សារាចរលេខ ០៤ស.រ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ ០២១ស.ណ.ន ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៥០៨.ក ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង) ។

៥-ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់អាវុធខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន ។

**ខ-ផែនការសកម្មភាពៈ**

១-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តអោយបាននូវរបបប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យសភាពការណ៍ ដាក់ចេញផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ**ភូមិ, ឃុំមានសុវត្ថិភាព** ក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន (ឯកសារយោង សេចក្តីណែនាំ លេខ០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ) ។

គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវមានសេនាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរអង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

២-នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីយ៉ាងសំខាន់ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹងកងកម្លាំងនេះ ដើម្បីក្លាយទៅជាកំលាំងស្នូលពិតប្រាកដ នៃចលនាការពារ "**ភូមិ, ឃុំ មានសុវត្ថិភាព**" និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយ ៖

-ត្រូវរៀបចំឲ្យមានក្របខ័ណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ

-ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការ និងសិទ្ធិអំណាច ព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល (ឯកសារយោង មេរៀនដកស្រង់ពីក្រុមការងារ ការអនុវត្តសាកល្បងការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍)

-ត្រូវរៀបចំឲ្យមានទីកន្លែងធ្វើការ មធ្យោបាយ ឧបករណ៍សំភារៈសំរាប់បំរើការងារ និងរៀបចំឲ្យមានប្រអប់សំបុត្រ និង

-ត្រូវមានកម្លាំងប្តូរវេនប្រចាំការជាអចិន្ត្រៃយ៍នៅស្នាក់ការនគរបាលប៉ុស្តិ៍រដ្ឋបាលដើម្បីទំនាក់ទំនងជួប និងទទួលព័ត៌មានពីគ្រប់ប្រភព ។ ក្នុងករណីមានសភាពការណ៍បទល្មើស ឬឧប្បទ្ទវហេតុផ្សេងៗកើតឡើង ចាំបាច់ត្រូវកោះហៅប្រមូលផ្តុំកម្លាំងដើម្បីប្រតិបត្តិការណ៍ដោះស្រាយ ។

-ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយកងកម្លាំងមានសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាក្នុងឃុំ សង្កាត់ ភូមិ និង

-ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការនយោបាយ ជំនឿសាសនា ភេទ ឬស្ថានភាពសង្គមនៃប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់ៗរូបស្រឡាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រ សហការ ចូលរួមឲ្យបានទូលំទូលាយប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងចលនា**ភូមិ, ឃុំមានសុវត្ថិភាព** ។

***៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវ៖***

-ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទីនៃនគរបាលថ្នាក់នីមួយៗ ដើម្បីដឹកនាំ ត្រួតពិនិត្យ វាយតម្លៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ, សង្កាត់ជាប្រចាំ ។ ជាមួយនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជាអោយអង្គភាពនគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ, សង្កាត់ នៅពេលមានបទល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់ ។

-មានកម្មវិធីការងារឲ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋាន ដោយត្រូវយក**ភូមិ**ធ្វើជាគោលដៅ ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន ក្នុងន័យទាក់ទាញឲ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតបានជាកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើស រក្សា**សុវត្ថិភាពភូមិ, ឃុំ** ។

៤-ក្រោមការសំរបសំរួលរបស់រដ្ឋបាលឃុំ, សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅតាមភូមិនិមួយៗ ឬកម្រងភូមិត្រូវរៀបចំឲ្យមានវេទិកាសាធារណៈ **ស្តីពីសុវត្ថិភាពភូមិ, ឃុំ** ។ វេទិកានេះធ្វើឡើងយ៉ាងតិច ១ដង ក្នុង ១ត្រីមាស (ឯកសារយោងផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ "**ចលនាប្រជាការពារ**" លេខ ០៣៨ផក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ) ។ ក្នុងវេទិកានេះត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋដែលលើកឡើង ។ ក្នុងករណីដោះស្រាយ

មិនបាន ត្រូវរាយការណ៍ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ឲ្យបានសមស្របជូនប្រជាពលរដ្ឋវិញ ។

៥-ក្រសួងមហាផ្ទៃសូមអំពាវនាវ៖

-ដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទី ភារកិច្ចរបស់ខ្លួន ចេញនូវការណែនាំដល់មន្ត្រី អង្គភាព ក្រោមឱវាទរបស់ខ្លួន ដើម្បីសហការ លើកទឹកចិត្ត ឧបត្ថម្ភ គាំទ្រ ចូលរួមជាមួយក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។

-ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ... ផ្អែកតាមតួនាទី ភារកិច្ច និងលទ្ធភាពរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភ គាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាព ចូលរួមក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។

៦-ត្រូវចាត់តាំងឲ្យមានចលនាប្រឡងប្រណាំង បង្កើតស្នាដៃអបអរសាទរសំរាប់ខួបអនុស្សាវរីយ៍ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជាប្រចាំឆ្នាំនិមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" (ឯកសារយោង សារាចរណែនាំលេខ ០០១ ស.រ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរសាទរមិទ្ទិញខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា១៦ ឧសភា ១៩៤៥) ។

IV-**ការចាត់តាំងអនុវត្ត៖**

១-ក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ ដើម្បី សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ដឹកនាំ និងចាត់តាំងអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព**នេះ ។ (ភ្ជាប់ជាមួយឧបសម្ព័ន្ធ) ។

២-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្រៅពីសេនាធិការរបស់ខ្លួន ត្រូវរៀបចំអោយមានក្រុមការងារចុះតាមមូលដ្ឋានឃុំ សង្កាត់ ដោយយក**ភូមិ**ជាគោលដៅដើម្បីសហការអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព** ។

៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបូកសរុបលទ្ធផលអនុវត្តគោលនយោបាយ "**ភូមិ, ឃុំ មានសុវត្ថិភាព**" ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើរមកលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តាមតារាងទិន្នន័យដែលភ្ជាប់ជាឧបសម្ព័ន្ធនៃផែនការណែនាំនេះ ដើម្បីមានមូលដ្ឋានវាយតម្លៃលទ្ធផល និងស្នាដៃតាមឃុំ សង្កាត់ និមួយៗ ។

៤-គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវចាត់តាំងប្រជុំបូកសរុប ដកពិសោធន៍ និង លើកទិសដៅបន្តក្នុងរយៈពេល ០១ត្រីមាសម្តង ។ សមាសភាពចូលរួមក្នុងអង្គប្រជុំនេះ គឺអ្នក ពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរបស់ខ្លួន និងអាស្រ័យដោយប្រធានគណៈបញ្ជាការ ឯកភាពរដ្ឋបាលសំរេច ។

៥-ដើម្បីទទួលបានបទពិសោធន៍ឈានទៅកែលំអរផែនការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ, ឃុំមានសុវត្ថិភាពនេះ ឲ្យកាន់តែល្អប្រសើរថែមទៀត គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ អាចជ្រើសរើសមូលដ្ឋានមួយ ឬពីរ ដើម្បីអនុវត្តសាកល្បង បន្ទាប់មកទើបធ្វើការផ្សព្វផ្សាយ និង ចាត់តាំងអនុវត្តជាទូទៅ ។

៦-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃ លក្ខណៈសម្បត្តិរបស់ភូមិ, **ឃុំ មានសុវត្ថិភាព** ។ តាមរយៈនេះត្រូវរកឲ្យឃើញអង្គភាព និងបុគ្គល ដែលមានស្នាដៃល្អ ដើម្បីផ្តល់រង្វាន់លើកទឹកចិត្ត ។

៧-អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ត្រូវធ្វើគំរោងថវិកា មធ្យោបាយ សំភារៈ បំរើដល់ ការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ។

ទទួលបានផែនការណែនាំស្តីពីការអនុវត្តគោលនយោបាយភូមិ, **ឃុំមានសុវត្ថិភាព**នេះ ក្រសួង មហាផ្ទៃសង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ គណបក្ស នយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួម អនុវត្ត និងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបានជោគជ័យ ក្នុងការកសាងសេចក្តីសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋយើង ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

ស.ជ.ណ DP-K02

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានីភ្នំពេញ**

**រដ្ឋបាលខណ្ឌដូនពេញ**

លេខ ២២០/១៩ ស.ជ.ណ

# សេចក្តីជូនដំណឹង

## ស្តីពីការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ តាមបណ្តោយមហាវិថីព្រះនរោត្តម

**យោង:** ស្មារតីអង្គប្រជុំរបស់រដ្ឋបាលរាជធានីភ្នំពេញ ។

ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ រដ្ឋបាលខណ្ឌដូនពេញ សូមជូនដំណឹងដល់ម្ចាស់អាជីវកម្ម ស្ថាប័នរដ្ឋ ឯកជន នៅតាមបណ្តោយមហាវិថីព្រះនរោត្តម ដែលបានកំពុងចតរថយន្ត ម៉ូតូ នៅលើចិញ្ចើមផ្លូវ សម្រាប់អ្នកថ្មើរជើង និងសម្រាប់ជនពិការឱ្យបានជ្រាបថា៖ ដើម្បីសោភ័ណ្ឌភាព និងសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋ ក្នុងការធ្វើដំណើរឆ្លងកាត់ ឱ្យជៀសផុតពីការកកស្ទះចរាចរណ៍ រដ្ឋបាលខណ្ឌដូនពេញ សម្រេចដាក់ចេញជាគោលការណ៍ដូចខាងក្រោម៖

១.មិនអនុញ្ញាតឱ្យមានការចតរថយន្ត ម៉ូតូ គ្រប់ប្រភេទនៅលើចិញ្ចើមផ្លូវសាធារណៈ និងផ្លូវសម្រាប់អ្នកថ្មើរជើង (ដែលចំណែកគំនូសពណ៌លឿងមកដល់ជញ្ជាំងផ្ទះប្រជាពលរដ្ឋ ឬរបងស្ថាប័នរដ្ឋ ឯកជន គឺទុកសម្រាប់ជនពិការ ក៏ដូចជារទេះជនពិការធ្វើដំណើរឆ្លងកាត់ និងមួយផ្នែកទៀតពីគំនូសពណ៌លឿងមកដល់ចិញ្ចើមផ្លូវ ត្រូវរក្សាទុក សម្រាប់ប្រជាពលរដ្ឋ ធ្វើដំណើរឆ្លងកាត់)។

២.នៅខាងមុខទីតាំងអាជីវកម្មរបស់ខ្លួន ត្រូវមានចំណតផ្ទាល់ខ្លួន ដែលមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈឡើយ ។

៣.នៅមុខទីតាំងអាជីវកម្មរបស់ខ្លួន រួមទាំងស្ថាប័នរដ្ឋ ឯកជន ត្រូវសំអាតអនាម័យ ឱ្យបានស្អាតជានិច្ច ដើម្បីរួមចំណែកការពារបរិស្ថាន សម្រាប់រាជធានីភ្នំពេញរបស់យើង។

៤.ម្ចាស់ទីតាំងស្ថាប័នរដ្ឋ ឯកជន អាចសុំចតរថយន្ត ម៉ូតូ របស់ខ្លួន តាមគំនូសទីតាំង ដែលមន្ទីរសាធារណការរាជធានីភ្នំពេញបានកំណត់ ។

៥.ក្នុងករណី លោក-លោកស្រី នៅតែមិនអនុវត្តតាមសេចក្តីជូនដំណឹង ក៏ដូចជាការណែនាំរបស់រដ្ឋបាលខណ្ឌដូនពេញទេ នោះរដ្ឋបាលខណ្ឌនឹងចាត់វិធានការ រដ្ឋបាលដោយ ស្ទូចយករថយន្ត ម៉ូតូ មករក្សាទុក នៅរដ្ឋបាលខណ្ឌរយៈពេល ១៥ថ្ងៃ ទើបដោះស្រាយជូន ។

ទទួលបានសេចក្តីជូនដំណឹងនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រី នឹងសហការជាមួយរដ្ឋបាលខណ្ឌដូនពេញ ក្នុងការអនុវត្តន៍ឱ្យមានប្រសិទ្ធភាព ដើម្បីប្រជាពលរដ្ឋ និងសម្រាប់យើងទាំងអស់គ្នា ៕

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក-លោកស្រី មេត្តាចាត់ចែងតាមការគួរ ។

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩

**អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ**

សុខ_ពេញវុធ

**ចម្លងជូន**
- សាលារាជធានីភ្នំពេញ
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ
- ក្រុមប្រឹក្សាខណ្ឌដូនពេញ
- អធិការនគរបាលខណ្ឌដូនពេញ
- មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌដូនពេញ
- សង្កាត់-ប៉ុស្តិ៍ទាំង១១
  "ដើម្បីជូនជ្រាប"
- ឯកសារកាលប្បវត្តិ